ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jun-2013, 14:56
CMS/CFO: Uch Arun

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៤នាទី**

**សវនាការលើកទី១៨៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

កញ្ញា មីរីអ៊ាម ម៉ាហ្វេសាន់ទិ

*(Ms. Miriam MAFESSANTI)*

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី

*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ ដារារស្មី

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ប៉ាស្កាល់ អូប៊ីង
*(Mr. Pascal AUBOIN)*

លោកស្រី បេនី យេ *(Ms. Ms. Beini YE)*

លោក វ៉េន ពៅ

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*

លោក អេមម៉ានូអែល ហ្សាកូមី
*(Mr.Emmanuel JACOMY)*

លោកស្រី នូស៊ីន សាកាវ៉ាទី
*(Ms.Nushin SAKARATI)*

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ល សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ច័ន្ទ តារាវស្ទី | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក សំ សុគង់ | ខ្មែរ |
| លោកស្រី នូស៊ីន សាកាវ៉ាទី | អង់គ្លេស |
| លោក អេមម៉ានូអែល ហ្សាកូមី | បារាំង |
| លោក ខៀវ សំផន | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| លោកស្រី បេ សុផានី (TCCP-4) | ខ្មែរ |
| លោក សឿន សុវណ្ណី (TCCP-145) | ខ្មែរ |
| លោកស្រី សេង ស៊ីវត្ថា (TCCP-141) | ខ្មែរ |

# ឧបសម្ព័ន្ធ

# ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី

## លោកស្រី បេ សុផានី (TCCP-4)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៣
សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី ផ្តើមពី ....................ទំព័រ ៦
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី ....................ទំព័រ ២២
សួរបន្តដោយលោកស្រី នូស៊ីន សាកាវ៉ាទី ផ្តើមពី ....................ទំព័រ ២៩
សួរដោយលោក សុន អរុណ ផ្តើមពី ....................ទំព័រ ៣២

## លោក សឿន សុវណ្ណី (TCCP-145)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៤១
សួរដោយលោក សំ សុគង់ ផ្តើមពី ....................ទំព័រ ៤៤
សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី ....................ទំព័រ ៥៧
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ៦៣

## លោកស្រី សេង ស៊ីវត្ថា (TCCP-141)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៧២
សួរដោយលោក អេម៉ានូអែល ហ្សាកូមី ផ្តើមពី....................ទំព័រ ៧៣
សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី ....................ទំព័រ ៨៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៣៥]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងផលប៉ះពាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប។ ហើយមុននឹងបន្តកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្តាប់ថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងផលប៉ះពាល់ចំពោះខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប អង្គជំនុំជម្រះសូមជម្រាបជូនភាគីទាំងអស់នៃរឿងក្តីនេះបានជ្រាបថា នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ និងថ្ងៃបន្តបន្ទាប់ លោកចៅក្រម យូរ ឧត្តរា ដែលជាចៅក្រមជាតិអវត្តមានដោយគាត់មានបញ្ហាសុខភាព គាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន។ បន្ទាប់ពីយើងខ្ញុំបានពិភាក្សាពិគ្រោះយោបល់មួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងបានសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិជំនួសកន្លែងចៅក្រម យូ ឧត្តរា ដែលបានអវត្តមាន រហូតដល់ពេលណាលោកចៅក្រម យូ ឧត្តរា មានវត្តមាន និងអាចមានលទ្ធភាពបំពេញការងារនៅក្នុងការចូលរួមកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងវិញបាន។

[០៩:០៦:៣២]

ការសម្រេចនេះ ដោយផ្អែកតាមបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បញ្ហាមួយទៀត អង្គជំនុំជម្រះក៏សូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនបានជ្រាបផងដែរថា លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដែលជាចៅក្រមបម្រុងខាងភាគីអន្តរជាតិ លោកស្រីអវត្តមាននៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ និងថ្ងៃបន្តបន្ទាប់ ដោយលោកស្រីមានធុរៈចាំបាច់ផ្ទាល់ខ្លួន។ ហើយក៏សូមជម្រាបជូនដំណឹងផងដែលថា ដោយមានបញ្ហាខុសពេលវេលាគ្នាអំពីពេលវេលានៅកម្ពុជា

និងពេលវេលាសហរដ្ឋអាមេរិក ដែលអង្គជំនុំជម្រះមានបំណង និងមានកាលវិភាគស្តាប់សក្ខីកម្មសាក្សីតាមរយៈប្រព័ន្ធសោតទស្សន៍នៅថ្ងៃស្អែក និងថ្ងៃទី៦, ទី៧ ខែមិថុនា ឆ្នាំ២០១៣ តាមរយៈប្រព័ន្ធសោត-ទស្សន៍នោះ ហើយអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងភាគីនិងសាធារណជនថា ពេលវេលាដែលនឹងចាប់ផ្តើមនៅពេលព្រឹកនៅថ្ងៃស្អែក គឺចាប់ផ្តើមនៅម៉ោងប្រាំបី និងសាមសិបនាទី។ ហើយសម្រាកថ្ងៃត្រង់គឺនៅម៉ោងដប់មួយសាមសិបនាទី។ ហើយចំណែកឯរសៀល គឺយើងប្រព្រឹត្តិទៅពេលវេលាដូចធម្មតា ពីព្រោះនៅពេលរសៀល យើងស្តាប់សក្ខីកម្មសាក្សីនៅចំពោះមុខដែលចូលខ្លួននៅចំពោះមុខអង្គ-ជំនុំជម្រះសាលាដំបូង។

[០៩:០៨:០៦]

លោក ដាវ អានសាន ឡើង -- បាទ សូមបញ្ជាក់ផងដែរថា ដោយឡែកនៅថ្ងៃរសៀល ថ្ងៃសុក្រទី៧ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះនឹងចាប់ផ្តើមសវនាការនៅវេលាម៉ោងមួយរសៀល ហើយនិងសម្រាកនៅម៉ោងបី និងសាមសិបនាទី។

លោក ដាវ អានសាន ឡើងរាយការណ៍អំពីស្ថានភាព វត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

បាទ សូមគោរពជម្រាបលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

[០៩:០៩:០១]

ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីរូប ដែលត្រូវមកថ្លែងទុក្ខសោកនៅថ្ងៃនេះ គឺទី១ ដើមបណ្តឹងរដ្ឋ-ប្បវេណីដែលមានរហស្សនាម TCCP-4, ទី២ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សមាន TCCP-145, ទី៣ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-141។

ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីរូបនេះ មានវត្តមានរួចជាស្រេចនៅបន្ទប់រង់ចាំ ត្រៀមខ្លួនការកោះហៅចូលក្នុងបន្ទប់សវនាការ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់កន្លែងផ្តល់សក្ខីកម្ម

នៅក្នុងបន្ទប់សវនាការនេះ អង្គជំនុំជម្រះសួរទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើនីតិវិធីប្រព្រឹត្តទៅក្នុងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងផលប៉ះពាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប លោកមានសំណូមពរយ៉ាងម៉េចទេ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីរូបនេះ គឺដើមបណ្តឹងរដ្ឋប្បវេណីទី១ TCCP-4 នឹងសួរដោយមេធាវី នូស៊ីន សាកាវ៉ាទី ដែលលោកស្រីមេធាវីបន្ទាប់ពីលោកប្រធានសួរសំណួររួចហើយ លោកស្រីនឹងផ្តើម -- នឹងធ្វើសេចក្តីផ្តើមខ្លី និងបញ្ជាក់ពីឯកសារ បន្ទាប់មកលោកស្រីនឹងសួរទៅដើមបណ្តឹងរដ្ឋប្បវេណី ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយ។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីទី២ គឺ TCCP-145 នឹងសួរដោយលោកមេធាវី សំ សុគង់។ ចំពោះនីតិវិធី គឺដូច -- គឺដើមបណ្តឹងរដ្ឋប្បវេណីថ្លែងអំពីព្យសនកម្ម។ បន្ទាប់មកបើមានសំណួរលោកមេធាវីនឹងសួរបញ្ជាក់បន្ថែម។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីទី៣ នឹងសួរដោយលោកមេធាវីអេមម៉ានូអ៊ែល ហ្សាកូមី។ ចំណែកឯនីតិវិធីគឺមេធាវីផ្តើម និងបញ្ជាក់អំពីឯកសារ រួចមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនឹងសួរដើមបណ្តឹងរដ្ឋប្បវេណី។ បាទ សូមអរគុណលោកប្រធាន។

បាទ សូមៗបញ្ជាក់បន្តិច សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីរូបនេះ គឺសុទ្ធតែមានសំណួរសម្រាប់ជនជាប់ចោទ។

[០៩:១១:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

លោកមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី TCCP-4 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីអាចជម្រាបអំពីឈ្មោះរបស់លោកស្រីបានដែរទេ? តើលោកស្រីឈ្មោះអី?

**លោកស្រី បេ សុផានី៖**

**ឆ៖** ចាស ជម្រាបសួរលោកប្រធានអង្គប្រជុំ នាងខ្ញុំ សុផានី បេ។

**ស៖** លោកស្រី សុផានី តើលោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ចាស លោកប្រធាន ខ្ញុំមានអាយុ៦៧ឆ្នាំហើយ។

[០៩:១៤:១០]

**ស៖** អរគុណ ហើយលោកស្រីអាចប្រាប់ទីកន្លែងកំណើតរបស់លោកស្រីបានទេ តើលោកស្រីកើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំ ស្រុកកំណើតខ្ញុំ ខ្ញុំកើតនៅកំពង់ឆ្នាំង នៅប្រទេសខ្មែរ នៅកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំ។

**ស៖** បាទ អរគុណ។ ហើយចុះទីកន្លែងរស់នៅសព្វថ្ងៃហ្នឹង តើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ចាស លោកប្រធាន ខ្ញុំនៅទីក្រុងសាន្ទូហ្សេ រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក។

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកស្រីគាត់ឈ្មោះអី ហើយនិងម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ចាស លោកប្រធានឪពុកខ្ញុំឈ្មោះ អ៊ុយ ង៉ឹម ហើយម្ដាយខ្ញុំឈ្មោះ សៀង សៀន។

**ស៖** អរគុណ។ ហើយលោកស្រីមានស្វាមីទេ? ហើយតើស្វាមីរបស់លោកគាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់សព្វថ្ងៃនេះ?

**ឆ៖** ចាស លោកប្រធានខ្ញុំមានប្ដី។ ប្ដីខ្ញុំគាត់ឈ្មោះលោក សារិត បេ ចាសហើយខ្ញុំមានកូនបីនាក់។ កូនប្រុសមួយ ស្រីពីរ។ ចាសនៅតូចៗចាស។

[០៩:១៥:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី។ ហើយនៅក្នុងសវនាការនេះ ក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះនឹងផ្ដល់ឱកាសជូនទៅលោកស្រីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ប្រាប់ដល់អង្គសវនាការដែលមានជាអាទិ៍ កើតឡើងចំពោះលោកស្រី ការខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ សម្ភារៈ ការជាព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ ដែលមានពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ន នាំឲ្យលោកស្រីប្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់

ចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ប៉ុន្តែដោយសារនីតិវិធីនៅពេលនេះ គឺដើម -- មេធាវីរបស់លោកស្រីនឹងតាំងសំណួរសួរលោកស្រីជាមុន ហើយនៅក្នុងពេលនោះគឺលោកស្រីអាចថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងអំពីព្យសនកម្ម ឬក៏ផលប៉ះពាល់ចំពោះលោកស្រីផ្ទាល់បាន នៅបន្ទាប់ពីមេធាវីរបស់លោកស្រីតាំងសំណួរ។ នេះជាសិទ្ធិរបស់លោកស្រីនាពេលដំណើរការសវនាការនេះ។

[០៩:១៦:៥៣]

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ អាចតាំងសំណួរដេញដោលចំពោះកូនក្តីរបស់លោកស្រី។

សូមអញ្ជើញ!

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការណែនាំបន្តិច ជាការផ្តើមសេចក្តីបន្តិចមុននឹងខ្ញុំចាប់ផ្តើម។ លោកប្រធាន លោក លោកស្រីចៅក្រម លោកស្រី សុផានី គឺជាជនរងគ្រោះដោយផ្ទាល់នៃការជម្លៀសពីទីក្រុងភ្នំពេញ ហើយគាត់បានដាក់ទម្រង់បែបបទជនរងគ្រោះ គឺឯកសារដែលមានលេខ ២២២/៣៨៥០ ហើយទម្រង់ព័ត៌មានជនរងគ្រោះសរសេរជាខ្មែរ និងអង់គ្លេស ហើយមានលេខ 00571050 រហូតដល់ 75, ភាសាបារាំងមានលេខ 00846057 ដល់ 72, ភាសាខ្មែរគឺលេខ 00865219 ដល់ 26 ហើយភាសាអង់គ្លេសគឺមានលេខ 00867203 ដល់ 11។

[០៩:១៨:១៨]

លោកស្រីត្រូវបានទទួលស្គាល់ជារងគ្រោះនៃការជម្លៀសពីភ្នំពេញ ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ ហើយនៅថ្ងៃនេះគាត់ចង់បង្ហាញអំពីបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហម ហើយនិងផលប៉ះពាល់ដែលទទួលបាន។ ហើយក្នុងនាមគាត់ជាម្តាយនៃកូនដែលទទួលរងគ្រោះការជម្លៀស លោកស្រីមានទារកមួយអាយុ៦ខែ និងកូនពីរនាក់ដែលមានវ័យក្មេងៗ។ ហើយសក្ខីកម្មនៅថ្ងៃនេះគឺនឹងពណ៌នាអំពីការឈឺចាប់ដែលគាត់បានទទួលនៅពេលដែលជម្លៀសពីទីក្រុងភ្នំពេញ ហើយនិងការឈឺចាប់ដែលទទួលពីការបាត់បង់កូនទាំងបីរូបនៅពេលដែលជម្លៀស។

លោកស្រី សុផានី បានចាកចេញពីទីក្រុងភ្នំពេញ ចាកចេញពីប្រទេសកម្ពុជានៅឆ្នាំ៨៣ ហើយបានទៅដល់សហរដ្ឋអាមេរិក។ ទោះបីថាគាត់បានចាកចេញពីប្រទេសកម្ពុជា បានទៅរស់នៅសហរដ្ឋ

អាមេរិកក៏ដោយ ក៏ការឈឺចាប់របស់គាត់នៅតែបន្តរហូតមកដល់ពេលនេះ។ ហើយក្នុងពេលឥឡូវនេះ គាត់មានតួនាទីជាអ្នកផ្តល់ប្រឹក្សាផ្នែកសុខភាពផ្លូវចិត្ត ហើយគាត់ស្នើសុំឱ្យមានកម្មវិធីអប់រំសុខភាពផ្លូវចិត្ត ឬក៏ការជួយសុខភាពផ្លូវចិត្តដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ដើម្បីឱ្យប្រជាជនគាត់ចៀសផុតពីការភ័យរន្ធត់ ឬក៏ជំងឺភ័យខ្លាច។

[០៩:១៩:៣៩]

លោកស្រីគាត់ទទួលរងនូវការឈឺចាប់ ដូចដែលប្រជាជនបានទទួលនៅក្នុងសហគមន៍របស់គាត់ផងដែរ។ ហើយដោយសារតែរបបខ្មែរក្រហមធ្វើឱ្យគាត់បាត់បង់កូន ហើយនិងធ្វើឱ្យបាត់បង់នូវក្រុមគ្រួសារ ហើយគាត់មានអារម្មណ៍ថាគាត់ស្ថិតក្នុងភាពឯកោរស់នៅតែម្នាក់ឯង។

លោកប្រធាន ខ្ញុំសូមលើកសំណួរមួយចំនួនជូនចំពោះដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឱ្យគាត់ធ្វើការឆ្លើយតបទៅនឹងសំណួរដែលខ្ញុំបានលើកឡើងនេះ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី៖**

**ស៖** សូមជម្រាបសួរលោកស្រីសុផានី។ មុនពេលដែលយើងចាប់ផ្តើមនិយាយអំពីបទពិសោធន៍ដែលលោកស្រីបានទទួលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកស្រីអាចរៀបរាប់បានទេ ថាតើការរស់នៅរបស់លោកស្រីមានស្ថានភាពបែបណានៅមុនខែមេសា ឆ្នាំ៧៥?

[០៩:២០:៣៤]

**លោក បេ សុផានី៖**

**ឆ៖** ខ្ញុំសូមជម្រាបសួរលោកស្រីមេធាវី។ ខ្ញុំសូមជម្រាបសួរលោកប្រធានអង្គប្រជុំ ហើយនិងសូមជម្រាបសួរអស់លោកទាំងអស់។ ថ្ងៃនេះខ្ញុំមានវាសនាល្អណាស់ដែលខ្ញុំបានមកពីសហរដ្ឋអាមេរិកមកកាន់ទីនេះគឺមកជួប -- មានសេចក្តីរីករាយមកជួបលោកប្រធានអង្គប្រជុំ ហើយនិងបានថ្លែងសាទុក្ខនូវសេចក្តីទុក្ខសោកវេទនារបស់ខ្ញុំនិងកូនខ្ញុំនៅសម័យខ្មែរក្រហម ប៉ុល ពត ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៨ ចាស។ នៅមុនឆ្នាំ១៧៥ ខែ -- ថ្ងៃ១៧ មេសា ឆ្នាំ៧៥ ខ្ញុំរស់នៅទីក្រុងភ្នំពេញ។ ខ្ញុំជាគ្រូបង្រៀន។ ប្តីខ្ញុំ ជាវរសេនីយ៍ទោ ផ្នែកទ័ពជើងគោកនៃរបបសាធារណរដ្ឋ លន់ នល់។ ហើយគាត់ក៏ត្រូវជាប្អូនប្រុសបង្កើតរបស់ ប្អូនពៅរបស់លោកជំទាវ ខេង ភរិយាដើមនៃលោកសេនាប្រមុខ លន់ នល់។ ខ្ញុំមានកូនបីនាក់ចាស។ កូនប្រុសមួយ កូនស្រីពីរ។ កូនប្រុសខ្ញុំច្បងឈ្មោះ សុផានវង្ស បេ ហៅ ប៉ូល។

កូនស្រីឈ្មោះ បទុម គន្ធា បេ ហៅ ពីន ហើយនិងកូនង៉ែតខ្ញុំអាយុពីរខែឈ្មោះ លីឡាវូដី ហៅ ប៉ុម។ ពេលនោះខ្ញុំរស់នៅជាមួយប្តី និងកូនខ្ញុំ។ នៅចុងឆ្នាំ១៩៧៤ ប្តីខ្ញុំត្រូវរដ្ឋាភិបាល លន់ នល់ បញ្ជូនឲ្យមករៀននៅសហរដ្ឋអាមេរិកនៅជានាយទាហានជាន់ខ្ពស់ នៅ ហ្វត បេនីង កូឡំប៊ីស ចចា្ជ។ ហើយខ្ញុំក៏នៅជាមួយកូនបីនាក់នៅទីក្រុងភ្នំពេញ។

[០៩:២២:៣៩]

**សៈ** សូមអរគុណលោកស្រី។ តើលោកស្រីអាចជម្រាបបានឬទេ ថាមានអ្វីកើតឡើងចំពោះលោកស្រីនៅថ្ងៃ១៧ មេសា ឆ្នាំ៧៥ នោះ?

**ឆៈ** ខ្ញុំសូមជម្រាបលោកប្រធាន និងសូមជម្រាបអង្គប្រជុំក្នុងថ្ងៃនេះ។ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលមកទីក្រុងភ្នំពេញ ហើយបានដើរនៅពេញផ្លូវក្នុងរដ្ឋធានីភ្នំពេញប្រកបដោយឯកសណ្ឋានខ្មៅហើយមានកាន់អាវុធគ្រប់ដៃទាំងស្រីទាំងប្រុស មុខមាំ។ រួចហើយកងទ័ពខ្មែរក្រហម យោធាខ្មែរក្រហមនោះក៏បានចាប់ផ្តើមបាញ់កាំភ្លើងឡើងលើៗ ហើយដេញប្រជាជនឲ្យចេញពីទីក្រុងភ្នំពេញភ្លាមៗ ចេញពីផ្ទះភ្លាមៗ។

ពេលនោះខ្ញុំភ័យ ខ្ញុំរន្ធត់ខ្លាំងណាស់ ខ្ញុំមិនស្មានថា ខ្មែរក្រហមធ្វើយ៉ាងដូច្នេះសោះ ខ្ញុំភ័យណាស់ហើយខ្ញុំរហ័សយ៉ាងឆាប់បំផុតគឺខ្ញុំចាប់កូន កូនង៉ែតខ្ញុំបីហើយខ្ញុំនិងកូនពីរនាក់តូចៗទៀត។ ពេលនោះខ្ញុំគ្មានបានយកអ្វីឲ្យបានគ្រប់គ្រាន់ច្រើនទេ ពីព្រោះខ្ញុំមានតែបីនាក់នឹងកូន។ ដូច្នេះខ្ញុំយកបានតែខោអាវមួយសម្រាប់ម្នាក់សម្រាប់កូន ហើយនិងប្រដាប់ប្រដាសម្រាប់កូនខ្ចីមានទឹកដោះគោ មានដបទឹកដោះគោ ដបទឹកដាក់នៅក្នុងកាតាបខ្មៅមួយដែលខ្ញុំច្រើនតែយកយួរទៅសាលារៀនដាក់សម្ភារៈទៅសាលារៀន។

[០៩:២៤:១៧]

ហើយពេលនោះខ្ញុំត្រូវតែចេញជាប្រញាប់ ពីព្រោះយោធាខ្មែរក្រហមបានបណ្តេញរន្ថាន់ៗថា ឲ្យចេញញឲ្យយ៉ាងឆាប់ ហើយថាសហរដ្ឋអាមេរិក និងមកទម្លាក់គ្រាប់បែកក្នុងពេលឆាប់ៗនេះ។ ត្រូវចេញឲ្យឆាប់ភ្លាមៗក្នុងរយៈ៣ថ្ងៃ។ ខ្ញុំត្រូវតែចេញភ្លាមៗ មិនអាចបង្អង់ទុកយូរបានទេ ពីព្រោះៗអ្វី? ពីព្រោះបើសិនយោធាខ្មែរក្រហមចូលមកដល់ផ្ទះខ្ញុំ នោះខ្ញុំច្បាស់ជាស្លាប់ឬយ៉ាងណាក៏មិនដឹងពីព្រោះនៅផ្ទះរបស់ខ្ញុំសុទ្ធតែរូបថតដែលមានសុទ្ធតែសម្លៀកបំពាក់ឯកសណ្ឋានទាហានរបស់ប្តីខ្ញុំ ហើយនិងរូបថតក្រុមគ្រួសាររបស់ខ្ញុំគឺលោកសេនាប្រមុខ លន់ នល់។

ដូច្នេះ ខ្ញុំប្រញាប់ប្រញាល់ទៅភ្លាម។ រួចហើយខ្ញុំនាំកូនឱបកូនទាំងបីកាន់នឹងដៃ ហើយកាតាប

មួយខ្មៅមួយទៀតដាក់សម្ភារៈ។ ខ្ញុំសំដៅទៅរកបងថ្លៃខ្ញុំដែលនៅទឹកល្អក់ បងស្រីរបស់ប្តីខ្ញុំ ដែលមានប្តីគាត់ជាអនុរដ្ឋមន្ត្រីក្រសួងកំណែនទូទៅ គឺឈ្មោះលោក វ៉ាន់ សារិន។ នៅទឹកល្អក់ ខ្ញុំសំដៅនៅទៅទីនោះទៅជួបជុំបងប្អូន ហើយទៅជួបជុំម្តាយក្មេងខ្ញុំនៅទីនោះ ប៉ុន្តែយោធាខ្មែរក្រហមបានកាត់ផ្លូវមិនឲ្យខ្ញុំចេញ។ ដូច្នេះ ខ្ញុំត្រូវចេញតាមចុងកាំភ្លើងដែលចង្អុល ហើយនិងកាំភ្លើងដែលបាញ់ទៅលើ ថាឲ្យចេញៗទៅ។ ខ្ញុំមិនដឹងថា តើឲ្យខ្ញុំចេញទៅទីណា? ទៅកន្លែងណា? អ្នកទាំងអស់គ្នាក៏មិនដឹងដែរ ថាឲ្យទៅទីណា។ ខ្ញុំក៏ដើរតាមគេតាមឯងជាមួយគេជាមួយឯងទៅ។ តាមផ្លូវ កាត់តាមផ្លូវតូច រួចហើយក៏ដើរទៅតាមផ្លូវធំ។ មនុស្សម្នាច្រើនណាស់ ចង្អៀតណែនណាន់តាន់តាប់ ពិបាកនឹងធ្វើដំណើរខ្លាំងណាស់។ មួយជំហានៗគឺប្រើពេលវេលាយ៉ាងយូរ។ រួចហើយ ខ្ញុំដើរពីផ្លូវតូចហើយ ខ្ញុំដើរទៅតាមផ្លូវធំ គឺផ្លូវធំនៅមុខចំការមន។

[០៩:២៦:១០]

នៅមុខចំការមនខ្ញុំដើរទៅតាមផ្លូវធំតាមយោធាខ្មែរក្រហមចង្អុលថាឲ្យទៅៗ។ ទៅដល់គឺផ្លូវនោះខ្ញុំថាសំដៅទៅក្បាលថ្នល់ ច្បារអំពៅចាស។ នៅតាមផ្លូវថ្នល់ ខ្ញុំសង្កេតឃើញនៅថ្ងៃនោះ គឺទិដ្ឋភាពដែលគួរឲ្យអាណោចអាធ័មអស្ចារ្យ គឺខ្មោចដាប់នៅតាមផ្លូវ។ ខ្មោចយោធា -- ខ្មោចទាហាន លន់ នល់ ខ្មោចមនុស្សចាស់ ខ្មោចកូនក្មេង ខ្មោចស្រីមានផ្ទៃពោះ ស្លាប់ទាំងផ្ទៃពោះនៅក្នុងផ្ទៃពោះ។ ហើយនិងខ្ញុំបានឃើញនូវទិដ្ឋភាពមួយទៀតនូវមនុស្សពិការ មនុស្សដែលកំពុងតែដាក់អ៊ុកស៊ីហ្សែននៅច្រមុះ គឺចេញមកហើយប្រជ្រៀតគ្នាយ៉ាងណែនណាន់តាន់តាប់ ហើយមានសភាពក្តៅណាស់ក្នុងរយៈខែនោះ គឺខែក្តៅណាស់។

ខ្ញុំក៏ធ្វើដំណើរទៅតាមការដេញរបស់យោធាខ្មែរក្រហម ដែលដេញ ដែលបាញ់កាំភ្លើងទៅឡើងលើឲ្យទៅៗ។ ខ្ញុំធ្វើដំណើរបន្តិចមួយជំហានៗយ៉ាងៗពិបាក ហើយយ៉ាងក្តៅស្អុះស្អាប់ជាមួយកូនខ្ញុំទាំងបី។ ខ្ញុំក្រៀកយ៉ាងជាប់ ព្រោះខ្ញុំខ្លាចបាប់កូនខ្ញុំ ពីព្រោះមនុស្សច្រើនណាស់ណែនណាន់តាន់តាប់។

ខ្ញុំដើរទៅតាមផ្លូវក្បាលថ្នល់ រួចហើយដើរកាត់ទៅតទៅមុខទៀត ទៅច្បារអំពៅ ហើយឆ្លងទៅផ្លូវ ទៅសំដៅទៅផ្លូវមួយដែលដើរទៅ គេហៅថាផ្លូវទៅត្រើយស្លាៗ។

[០៩:២៧:៤៩]

ក្នុងការធ្វើដំណើររបស់ខ្ញុំនេះ គឺថាធ្វើដំណើរជាច្រើនថ្ងៃ ទម្រាំបានចេញផុតពីទីក្រុងភ្នំពេញ។ ខ្ញុំត្រូវដេកផ្លូវ ដេកសំណាក់នៅផ្ទះទទេៗ ផ្ទះចិន គ្រង់ចិនដាំស្ពៃជាដើម ហើយគ្រង់ផ្ទះណាដែលគ្មានមនុស្ស

នៅ ទៅជ្រកទៅសម្រាកដូចជាប្រជាជនដទៃទៀតដែរ។

នៅតាមផ្លូវទៅៗកន្លែងដែលគេថាគេឲ្យទៅៗៗហ្នឹងអ៊ីចឹងទៅ ហើយមានកន្លែងមួយដែលមានដើមស្វាយច្រើនណាស់ ហើយពេលនោះ ថ្ងៃមួយនោះភ្លៀងធ្លាក់ខ្លាំង ខ្ញុំគ្មានអ្វីការពារខ្ញុំ ការពារកូនខ្ញុំទេ។ ខ្ញុំគ្មានអ្វីទេ ដូច្នេះខ្ញុំទៅជ្រកនៅក្រោមដើមស្វាយ។ ភ្លៀងធ្លាក់ជោកជាំ ទាំងយប់ ខ្ញុំទទឹកជោក កូនខ្ញុំទាំងបីក៏ទទឹកដែរ ពីព្រោះខ្ញុំយកកូនខ្ញុំដាក់ក្រោមទ្រូងខ្ញុំ ហើយខ្ញុំឱន ហើយភ្លៀងធ្លាក់មក ហើយនៅក្រោមដើមស្វាយគឺទទឹក។

[០៩:២៨:៥២]

ព្រឹកឡើង យោធាខ្មែរក្រហមបណ្តេញខ្ញុំទៀត បង្ខំឲ្យចេញទៅៗទៀត។ ខ្ញុំក៏ធ្វើដំណើរទៅមុខទៀត។ ចាប់ពីថ្ងៃនោះមក កូនៗស្រីខ្ញុំពៅ កូនង៉ែតចាប់ឈឺតែម្តង ព្រោះក្នុងការធ្វើដំណើរទៅ ដេញដែលយោធាខ្មែរក្រហមដេញចេញទៅនេះ គឺកូនស្រីខ្ញុំត្រូវក្តៅផង ត្រូវភ្លៀងផង។ ដូច្នេះក៏ចាប់ឈឺភ្លាម។ ចាប់ឈឺគឺក្តៅខ្លួន ហើយការក្តៅខ្លួននោះ គឺមិនមែនមានតែកូនខ្ចីទេ កូនតូចពីរនាក់ទៀតក៏ក្តៅខ្លួន រីឯខ្លួនខ្ញុំហ្នឹងក៏ក្តៅខ្លួនដែរ ស្រៀវឆ្អឹងខ្នង។ ប៉ុន្តែដោយខ្មែរយោធាខ្មែរក្រហមចេះតែបណ្តេញទៅៗ ខ្ញុំក៏ចេះតែដើរទៅៗដោយមិនដឹងថា តើត្រូវឈប់នៅទីណាទេ។ រហូតមកដល់ត្រើយស្លា កូនខ្ញុំកាន់តែឈឺខ្លាំង កាន់តែក្តៅខ្លួនខ្លាំងហើយ ខ្ញុំមិនអាចតដំណើរទៅមុខទៀតបានទេ។ ខ្ញុំត្រូវសម្រេចចិត្តនៅភូមិត្រើយស្លានេះព្រោះកូនខ្ញុំឈឺ ឈឺខ្លាំង។

[០៩:២៩:៥៤]

ពេលនោះ ខ្ញុំទៅជ្រកនៅក្រោមផ្ទះអ្នកប្រជាជន គេហៅថាអ្នកមូលដ្ឋាន ប្រជាជនចាស់។ ខ្ញុំទៅជ្រកក្រោមផ្ទះគេជាមួយកូនទាំងបីនាក់។ ប្រជាជនចាស់ អ្នកមូលដ្ឋានឃើញខ្ញុំ គាត់អាណិតៗដោយសារឃើញខ្ញុំមានកូនខ្ចីរខិករខាក គាត់បានឲ្យម្ហូបអាហារខ្ញុំ ឲ្យកូនខ្ញុំបរិភោគ តែយោធាខ្មែរក្រហមប្រាប់អ្នកមូលដ្ឋានឲ្យឈប់ឲ្យម្ហូបចំណីកូនខ្ញុំ ឲ្យឈប់ឲ្យចំណីខ្ញុំ ហើយបណ្តេញខ្ញុំកុំឲ្យនៅជិតអ្នកមូលដ្ឋានត្រូវចេញឲ្យឆ្ងាយឲ្យផុតពីគេ ព្រោះអ្នកឯងមានវណ្ណៈខុសគ្នា។ គឺបានន័យថា ខ្ញុំជាប្រជាជនថ្មី ប្រជាជន ១៧ មេសា ហើយអ្នកភូមិគេជាប្រជាជនចាស់ ជាអ្នកមូលដ្ឋាន។ ដូច្នេះ យោធាខ្មែរក្រហមបណ្តេញខ្ញុំឲ្យចេញទៅរកទីកន្លែងខ្លួនឯង ដោយចង្អុលប្រាប់ថា ទៅឲ្យឆ្ងាយ ទៅឲ្យចុងភូមិ។ ទៅចុងភូមិមានតែដីទទេ ហើយត្រូវអ្វីខ្លួនឯងធ្វើទៅដើម្បីនឹងជ្រក។

[០៩:៣១:១១]

ពេលនោះ កូនខ្ញីខ្ញុំកំពុងតែឈឺខ្លាំង ហើយកូនពីរនាក់ទៀតក៏ឈឺ ខ្លួនខ្ញុំហ្នឹងក៏ឈឺដែរ គ្រុនដែរ តែខ្ញុំដោយការបង្ខំ យោធាខ្មែរក្រហម ខ្ញុំចូលទៅក្នុងព្រៃជាមួយកូនពីរនាក់ បីនាក់ទាំងកូនខ្ចី ទៅអូសៗស្លឹកត្នោតដែលជ្រុះនៅដី។ កូនតូចពីរនាក់ទៀតក៏ខំជួយអូសស្លឹកត្នោត ខំអូសយ៉ាងលំបាក ពីព្រោះគ្នានៅតូចៗណាស់។ បានស្លឹកត្នោតហើយ ខ្ញុំក៏ខ្ចីកាំបិតគេជីក ជីកមែកឈើ កាត់មែកឈើតូចៗ យកមកទៅសំដៅទៅ ដែលគេហៅថា ដីដែលគេឲ្យខ្ញុំទៅនោះ។ រួចហើយខ្ញុំជីកដីហ្នឹងដោតៗឈើទៅ ហើយគ្រាន់តែយកស្លឹកត្នោតមកបាំងៗ ដើម្បីនឹងកំដៅថ្ងៃតែប៉ុណ្ណោះ។ តែខ្ញុំមិនអាចនៅទីនោះបានទេ ព្រោះកូនស្រីខ្ញុំឈឺខ្លាំងណាស់។

[០៩:៣២:០៥]

ពេលនោះ ខ្ញុំនៅចិញ្ចៀនពេជ្រមួយដែលជាចិញ្ចៀនពេជ្រដែលជាចំណងដៃរបស់បងថ្លៃស្រីខ្ញុំ លោកជំទាវ លន់ នល់ ឲ្យខ្ញុំនៅពេលខ្ញុំរៀបការ។ ខ្ញុំយកទៅចិញ្ចៀនពេជ្រនោះទៅដូរនឹងអ្នកស្រុក អ្នកភូមិនៅនោះ ដើម្បីនឹងសុំដូរយកថ្នាំគេ គឺអាស្ពៀរីន -- អ៎! ដូរយកអង្ករគេ មុនដំបូងយកអង្ករគេ។ គេឲ្យ២៥កំប៉ុងទឹកដោះគោ។ ក្នុង២៥កំប៉ុងនេះ ខ្ញុំត្រូវយកអង្ករទៅដូរយកថ្នាំពេទ្យ។ ដូច្នេះខ្ញុំយកអាស្ពៀរីន ខ្ញុំដូរយកអាស្ពៀរីន១០គ្រាប់ ហើយនិងហ្គានីដង់១០គ្រាប់ៗ សម្រាប់ឲ្យកូនខ្ញុំ កូនខ្ចីខ្ញុំ កូនខ្ញុំ ហើយនិងខ្ញុំញ៉ាំខ្លះ។ តែថ្នាំប៉ុណ្ណេះ មិនអាចទប់ទល់នឹងជំងឺរបស់កូនខ្ញុំបានទេ កូនពៅ កូនស្រីតូចរបស់ខ្ញុំ ឈឺខ្លាំងណាស់ គឺក្ដៅខ្លួនហើយរាកៗ គឺថាដាក់អ្វីចូលក្នុងមាត់ គឺចេញតាមគូទអស់។ មិនទទួលអាហារ ក្រពះមិនទទួលអាហារ។ ខ្ញុំភ័យស្លន់ស្លោ ខ្ញុំដឹកដៃកូនពីរ ទាំងពីរដើរសួររកអ្នកណាដែលអាចជួយ ពេទ្យ ឬក៏យ៉ាងណាដែលអាចជួយកូនខ្ញុំ ជីវិតកូនខ្ញុំបាន។ អ្នកស្រុកមានដឹង គេថាគេមិនដឹង គេមិនស្គាល់។ តែទីបំផុតមានអ្នកស្រុកម្នាក់ប្រាប់ខ្ញុំថា "ត្រូវឲ្យធ្វើដំណើរប្រហែលជា៤-៥គីឡូម៉ែត្រពីទីភូមិនេះ នោះ អ្នកនឹងឃើញកន្លែងមន្ទីររបស់គេហើយ យោធា មន្ទីរពេទ្យយោធាខ្មែរក្រហម"។

[០៩:៣៣:៣៤]

ខ្ញុំក៏ទៅតាម។ ពរកូន ហើយកូនពីរនាក់ទៀតទៅ ទៅរក។ ទៅដល់កន្លែងនោះ ខ្ញុំក្រឡេកឃើញ យោធាប្រុសម្នាក់។ អ្នកស្រុកប្រាប់ថា "ហ្នឹងហើយ គាត់ហ្នឹងពេទ្យយោធាខ្មែរក្រហម"។ ខ្ញុំសំពះយោធា នោះ ខ្ញុំថា "សូមលោកជួយមេត្តាជួយកូនខ្ញុំផង កូនខ្ញុំឈឺខ្លាំងណាស់។ កូនខ្ញុំក្ដៅខ្លួន ហើយរាក ឈឺខ្លាំងណាស់ ទទួលអាហារអត់បានទេ។ ឥឡូវនេះដាក់តែពីមាត់ចូល ចេញតាមគូទវិញអស់"។ យោធានោះ គ្មានមាត់មួយម៉ាត់ ប្រាប់ខ្ញុំថា "យកមក យកកូនមក"។ ខ្ញុំក៏បីកូនទៅ សំដៅទៅកន្លែងមួយដែលមានតែ

គ្រែចំនួនពីរបីប៉ុណ្ណោះ។ មានមនុស្សដេកនៅក្នុងនៅលើគ្រែហ្នឹងពីរបីប៉ុណ្ណោះ។ យោធាឲ្យខ្ញុំដាក់កូនខ្ញុំ កូនខ្លីខ្ញុំនៅលើគ្រែ រួចហើយទៅយកថ្នាំ មិនដឹងជាថ្នាំអ្វីខ្ញុំមិនដឹងដែរ ស្រាប់តែចាក់ក្បាលកូនខ្ញុំ យកៗ សីរាំង យកថ្នាំមកចាក់ក្បាលកូនខ្ញុំ។ ខ្ញុំនឹកឆ្ងល់ថា ចុះយោធាពេទ្យនេះ ហេតុអ្វីក៏មកចាក់ក្បាលកូនខ្ញុំ ម៉េចក៏មិនចាក់សាច់ ចាក់ដៃ បានទៅចាក់ក្បាល។ តែខ្ញុំមិនហ៊ានសួរ។ គ្រាន់តែដកម្ជុលភ្លាម កូនខ្លីខ្ញុំ ប្រកាច់ស្លាប់មួយរំពេច។ កូនខ្លីខ្ញុំស្លាប់មួយរំពេច។ ខ្ញុំស្រែកទ្រហោយំខ្លាំងៗ ពីព្រោះជាលើកទី១ ដែល ខ្ញុំជួបប្រទះនូវហេតុរបៀបនេះនៅក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំឱបកូនយំ កូនពីរនាក់ទៀតក៏យំទាំងអស់គ្នា។

[០៩:៣៥:១៣]

ដល់ពេលរសៀល ខ្ញុំបីកូនខ្ញុំយកទៅកប់នៅក្នុងព្រៃ ខ្ញុំបីខ្លួនខ្ញុំ យកកូនខ្ញុំទៅព្រៃទៅកប់ខ្លួនឯង ដោយគ្រាន់តែមានមនុស្សពីរនាក់ជួយជីករណ្តៅប៉ុណ្ណោះ ហើយខ្ញុំដាក់កូនខ្ញុំទៅក្នុងរណ្តៅ រួចហើយខ្ញុំ យកមែកឈើដោតពីរនៅមុខផ្នូរខ្មោចកូនដើម្បីជាទីចំណាំដែលខ្ញុំមករកមើលឡើងវិញ។ ខ្ញុំធ្លាក់ខ្លួនមាន ទុក្ខសោកវេទនាខ្លាំង ខ្ញុំវង្វេង ខ្ញុំមិនដឹងថាខ្ញុំជ្រុះបាត់ខ្សែ បាត់ក្រវិល ឬបាត់អីមិនដឹងខ្លួនទាល់តែសោះ។ ខ្ញុំត្រូវពួកយោធាខ្មែរក្រហមបង្ខំឲ្យធ្វើការជាទម្ងន់តាំងពីព្រឹកព្រលឹមរហូតដល់ព្រលប់ គឺដាំពោតៗ។ រីឯ កូនខ្ញុំពីរនាក់តូចៗ គឺនៅផ្ទះគ្មានអ្នកណាមើល គ្មានអាណាព្យាបាល គ្មានអ្នកណាមើលទេ គឺទុកនៅផ្ទះ ចោល។ ចំណែកខ្ញុំម្តាយត្រូវទៅធ្វើការនៅកន្លែងដាំពោត។

ដល់ខ្ញុំត្រឡប់មកផ្ទះវិញ ខ្ញុំមិនឃើញកូនទាំងពីរនាក់សោះ ខ្ញុំភ័យស្លន់ស្លោ ខ្ញុំដើររកកូន ខ្ញុំខ្លាច បាត់កូនពីរនាក់ទៀត។ មួយសន្ទុះកូនខ្ញុំទាំងពីរក៏ដើរមករកខ្ញុំវិញ ដោយមានមែកឈើនៅដៃមួយៗម្នាក់ ហើយកូនស្រី ពីន ដែលបានសម្តីជាងគេរាយរាប់ប្រាប់ខ្ញុំថា “ម៉ែ កូនទៅជីកៗ យកឈើនេះជីករណ្តៅ ជីកៗមើល ប៉ុម តែកូនអត់ឃើញ ប៉ុម ទេ”។ កូនខ្ញុំទាំងពីរធ្វើយ៉ាងនេះរាល់ថ្ងៃ ពេលខ្ញុំទៅធ្វើការ គឺកូន រត់ទៅក្នុងព្រៃទៅមើលប្អូនរបស់ -- ផ្នូរប្អូនរបស់វា ហើយវាប្រាប់ រាយរាប់ប្រាប់សព្វគ្រប់ដល់ខ្ញុំរបៀប នេះ ធ្វើឲ្យខ្ញុំចង់ឆ្កួត។ ខ្ញុំត្រូវសម្រេចចិត្តចេញពីទីហ្នឹង លែងនៅទីហ្នឹងទៀតហើយ ព្រោះខ្លាចកូនពីរ នាក់ខ្ញុំបាត់ទៀត។

[០៩:៣៧:១៧]

ខ្ញុំសម្រេចចិត្តចេញពីទីនេះចំនួនពីរដង ខ្ញុំមិនបានសម្រេចពីយោធាខ្មែរក្រហមចាប់បាន ហើយ សួរខ្ញុំមកពីណា ហើយប្រាប់ថា “ត្រូវទៅកន្លែងដើមវិញ។ បើមិនដូច្នេះទេ ខ្ញុំនឹងសម្លាប់ៗអ្នកឯង!”។ ដូច្នេះលើកទី១។ លើកទី២ មិនបានសម្រេច។ លើកទី៣ គឺបានសម្រេច។ ខ្ញុំមកបានសម្រេច ខ្ញុំឆ្លងទូក

មកបានសម្រេច។ រួចហើយខ្ញុំមកជាមួយចិនៗកាត់ខ្មែរខ្លះ ដែលគេប្រាប់ថា យោធាខ្មែរក្រហមយកគេទៅដាំបន្លែនៅជិតភ្នំពេញ។ ពេលនោះ ខ្ញុំឡើងឡានមកជាមួយចិនៗ។ ចិនៗសួរថា "អ្នកឯងទៅធ្វើអ្វី បើមិនមែនចិនទេ? ខ្ញុំថា ខ្ញុំទៅៗរកបងប្អូន"។ ហើយក៏ជិះក្នុងឡានទាំងអស់គ្នាមក។

មកដល់ជិតភ្នំពេញ ដល់កន្លែងដាំស្លែ ចិនដាំស្លែ យោធាខ្មែរក្រហមមិនឲ្យយើងចុះទេៗ។ ខ្ញុំឆ្ងល់ អ្នកទាំងអស់គ្នាឆ្ងល់ថា ចុះហេតុម្ដេចបានជាមិនឲ្យចុះ មកដល់កន្លែងដាំស្លែហើយមិនឲ្យចុះ? ផ្ទុយទៅវិញយោធាខ្មែរក្រហម គេដឹកឡានពួកខ្ញុំយកទៅវត្តទួលស្លែង។ ទួលស្លែងជិតកំពង់កន្ទួតៗ ទីនោះគឺជាកន្លែងយោធា ដែលគេហៅថា កងវរសេនាតូចលេខ៤០៧ ដែលមានសុទ្ធតែយោធាខ្មែរក្រហមប្រកបដោយសម្លៀកបំពាក់ខ្មៅ ស្ពាយអាវុធ មកស្វាគមន៍ទទួលពួកយើងចុះពីឡាន រួចហើយគេនាំយើងទៅដាក់នៅក្នុងផ្ទះមួយទំនេរយ៉ាងចង្អៀត យ៉ាងច្រើនគ្នាបំផុត។ ចង្អៀតបំផុត គឺពេលសម្រាន្តទៅដូចស្និតចេក ដេកទល់ជើងគ្នា ចង្អៀតណាស់។

[០៩:៣៩:០៧]

នៅទីនោះ យោធាខ្មែរក្រហមបានបង្ខំខ្ញុំ និងអ្នកដែលដទៃទៀតដែលមកជាមួយហ្នឹង ឲ្យទៅកាប់ព្រៃ គេចែកកាំបិតវែងៗយ៉ាងនេះ ឲ្យទៅកាប់ព្រៃ ព្រៃឈើធំៗ កាប់ព្រៃដើម្បីយកដីធ្វើស្រែ។ ខ្ញុំធ្វើយ៉ាងវេទនាបំផុត សត្វខាំ សត្វទិចក៏នៅតែធ្វើដោយគេបង្ខំ កាប់ឈើធំៗ។ យើងធ្វើនៅទីនោះរហូតដល់បានដីហើយធ្វើជាស្រែ។ ពេលធ្វើស្រែយោធាខ្មែរក្រហមបង្ខំឲ្យយើងធ្វើការដូចជាសត្វ។ គេមិនប្រើគោ ឬក្របីទេ គេមិនប្រើសត្វគោទេ តែគេប្រើមនុស្សធ្វើជំនួសសត្វ ថ្លាកដីៗ ភ្ជួរដីធ្វើស្រែ គឺគេប្រើមនុស្សសុទ្ធសាធ។ អ្នកណាដែលទៅ ដែលយឺតយ៉ាវ មិនចុះស្រែទាន់ គឺយកកាំភ្លើងបុកទ្រូងរហូតដល់មានធ្លាក់ក្អួត ធ្លាក់ឈាមក៏មាន បុកដើមទ្រូង។ ខ្ញុំនៅធ្វើការទីនោះ ធ្វើស្រែនៅទីនោះ។ នៅទីកន្លែងនោះហើយដែលកូនប្រុសខ្ញុំ ដែលឈ្មោះ ប៉ូល – សុផានុវង្ស ហៅ ប៉ូល នោះ។ ពេលថ្ងៃមួយកូនប្រុសខ្ញុំយំតាមខ្ញុំទៅធ្វើការ មិនចង់នៅផ្ទះ យំតាមខ្ញុំទៅធ្វើការ តែពួកយោធាខ្មែរក្រហមមិនឲ្យកូនខ្ញុំទៅតាមខ្ញុំទេ មិនឲ្យកូនទៅតាមម្ដាយទៅទេ។ វា យោធាខ្មែរក្រហមពីរនាក់មកឃាត់កូនខ្ញុំ ហើយយកកាំភ្លើង កាំភ្លើងវែងយកចុងកាំភ្លើងដាក់មាត់កូនខ្ញុំ កូនខ្ញុំស្រែកយំៗយ៉ាងខ្លាំង ហើយអត់ទឹកភ្នែកទេ អត់មានទឹកភ្នែក គឺស្រែកយក់ៗ។ ពេលនោះយោធាខ្មែរក្រហមបានប្រាប់ខ្ញុំថា កូនអ្នកឯងមិនមែនជាកូនខ្មែរទេ កូនអ្នកឯងជាកូនអាមេរិកាំង ឬកូនបារាំង មើលវាយំអត់ស្រក់ទឹកភ្នែកទេ។

[០៩:៤១:០៥]

រួចហើយខ្ញុំសួរទៅយោធាខ្មែរក្រហមនោះវិញថា "តើអ្នកឯងសម្លាប់កូនខ្ញុំឬ? យោធាខ្មែរក្រហមឆ្លើយប្រាប់ខ្ញុំថា ខ្ញុំមិនសម្លាប់ទេ តែខ្ញុំធ្វើឲ្យខ្លាច កុំឲ្យយំ កុំឲ្យតាមអ្នកឯង អ្នកឯងត្រូវទៅធ្វើការ។ យោធាពីរនាក់យកកាំភ្លើងមកភ្ជង់នៅក្រោយខ្នងខ្ញុំថា "ទៅធ្វើការភ្លាម បើមិនទៅទេ ខ្ញុំនឹងសម្លាប់កូនអ្នកឯង សម្លាប់អ្នកឯងហើយ"។ ដូច្នេះខ្ញុំប្រាប់ថា "កុំសម្លាប់កូនខ្ញុំ បើចង់សម្លាប់កូនខ្ញុំ សម្លាប់ខ្ញុំមក"។ រួចហើយខ្ញុំក៏ដើរទៅ។ យោធាខ្មែរក្រហមដោះក្រមាយកមកចងដៃកូនខ្ញុំ ហើយកូនខ្ញុំស្រែកៗអត់ទឹកភ្នែក ចេះតែពីស្រែកយក់ៗអត់ទឹកភ្នែក រួចហើយបែកញើសជោក។ យោធាខ្មែរក្រហមដោះអាវខោកូនខ្ញុំចេញអស់ ហើយលើកកូនខ្ញុំទៅដាក់នៅក្នុងទឹក នៅក្នុងគ្រលុកមួយដែលមានទឹកដែលមានទឹកនៅក្នុងនោះ។ កូនខ្ញុំ កូនប្រុសខ្ញុំនៅតែស្រែកអត់ឈប់ឈរ នៅតែស្រែកយក់ៗអត់ឈប់ឈរ។ ចំណែកកូនស្រីខ្ញុំមិនតាមខ្ញុំទេ គឺទៅតាមបងគេ គឺទៅឈរមើល ទៅតាមបងជាមួយបង។ ខ្ញុំដើរបណ្តើរបានបន្តិច ខ្ញុំដើរបណ្តើរខ្ញុំងាកក្រោយមើល ពីព្រោះក្រែងយោធាខ្មែរក្រហមសម្លាប់កូនខ្ញុំ ឬយ៉ាងម៉េច។

[០៩:៤២:១៩]

ខ្ញុំឃើញយោធាខ្មែរក្រហមពីរនាក់ជក់បារីនៅក្រោមដើមឈើ ពេលនោះកូនប្រុសខ្ញុំរត់ចេញពីក្នុងទឹកយ៉ាងលឿនជាមួយកូនស្រីមករកខ្ញុំយ៉ាងលឿន រត់យ៉ាងលឿនមកដល់ខ្ញុំ មកដល់ខ្ញុំ ដួលព្រួសនៅក្បែរជើងខ្ញុំ។ កូនប្រុសអត់មាននិយាយអីអ្វីបានទេ ពីព្រោះវាស្រែកខ្លាំងអស់សំឡេងហើយ និយាយអត់បានទេ គឺដួលព្រួសនៅជើងខ្ញុំ តែកូនស្រីរាយរ៉ាប់ប្រាប់ខ្ញុំ។ ខ្ញុំស្រាយចំណង ចំណងដៃក្រមាដែលខ្មែរយោធាដែលយោធាខ្មែរក្រហមហ្នឹងចងដៃកូនខ្ញុំ ខ្ញុំស្រាយចេញ ស្នាមចំណងហើយដែលកូនខ្ញុំរើនេះឡើងចង់ចេញឈាម។ ខ្ញុំអាណិតកូនខ្លោចចិត្ត ហួសចិត្ត អ្នកដទៃទៀតឃើញដូច្នេះក៏ហួសចិត្តដែរ អាណិតខ្លោចចិត្ត។ តាំងពីពេលនោះមកកូន ប៉ូល កូនប្រុសខ្ញុំចាប់ឈឺ គឺមានជំងឺហើម ហើមខ្លួនៗ។ កូនខ្ញុំឈឺចាប់តាំងពីនោះមក ហើយពេលនោះយើងក៏អត់ -- ខ្មែរក្រហមក៏អត់មានឲ្យចំណីអាហារឲ្យយើងបរិភោគទេ។ ខ្ញុំរាល់ថ្ងៃ ខ្ញុំបានទទួលតែបបររាវៗមួយកា គឺមួយកាដែលទាហានគេប្រើ ហ្នឹងចំពោះមនុស្សចាស់ ចំណែកកូនក្មេងវិញគឺបានកន្លះកា ហើយម្ហូបអាហារច្រើនតែជាមួយអំបិល។

[០៩:៤៣:៤៤]

ពេលនោះដោយខ្ញុំនៅនាឡិកាដៃមួយម៉ាកសេកូ ដែលប្តីខ្ញុំបានទៅប្រទេសអូស្ត្រាលី ហើយទិញឲ្យខ្ញុំ ខ្ញុំបានលាក់ទុកនៅក្នុងខ្សែ -- នៅក្នុងៗខ្លួនខ្ញុំហ្នឹង ខ្ញុំបានលាក់ទុកនៅចង្កេះខោខ្ញុំ ខោខ្លីខ្ញុំហ្នឹង ខ្ញុំលាក់ រួចហើយខ្ញុំយកនាឡិកាដៃនោះ ម៉ាកសេកូនោះទៅលួចដូរជាមួយនឹងប្រជាជននៅក្នុងភូមិនោះ ដែលគេ

មានថ្នាំពេទ្យគឺបានវីតាមីនបេអង – វ៉ាយថាមីនបេអង – បេវ៉ែន។ ខ្ញុំបានប្រាំបីគ្រាប់។ នាឡិកាសេកូមួយ បានប្រាំបីគ្រាប់ វីតាមីនបេអង។ ហើយខ្ញុំយកថ្នាំមកព្យាបាលឲ្យកូនខ្ញុំ ក៏ប៉ុន្តែកូនខ្ញុំឈឺហើមខ្លួនខ្លាំងណាស់ តាំងពីវាស្រែកខ្លាំង តាំងពីគេធ្វើបាបនៅកន្លែង៤០៧ហ្នឹងមក រហូតគឺកូនខ្ញុំឈឺខ្លាំងណាស់។

[០៩:៤៤:៤៣]

ខ្ញុំសូមនិយាយថា ដល់ខ្ញុំនៅ៤០៧ហើយ យោធាខ្មែរក្រហមបញ្ជូនខ្ញុំមកទៀត ឲ្យនៅកន្លែងយោធាមួយទៀតដែលឈ្មោះ៣២០ ឈ្មោះលេខ៣២០។ ហើយនៅទីកន្លែងនោះយោធាខ្មែរក្រហមបានបង្ខំខ្ញុំឲ្យធ្វើការជាទម្ងន់រែកដី ជាន់ឡើងៗណែនហើយរែកដីៗដើម្បី គេថាគេធ្វើទំនប់។ ខ្ញុំនៅទីនោះបាន៣ខែ ទើបគេបញ្ជូនខ្ញុំនិងកូនខ្ញុំឲ្យមកកន្លែងថ្មីទៀតដោយខ្ញុំមិនដឹងថាទៅទីណា? នៅពេលឡើងឡានយោធាខ្មែរក្រហមមកកត់ប្រវត្តិរូបខ្ញុំទៀត។ ខ្ញុំសរសេរថាខ្ញុំជាគ្រូបង្រៀន។ តែយោធាខ្មែរក្រហមនោះមិនជឿខ្ញុំសម្លក់ខ្ញុំ ភ្នែកយ៉ាងមាំ យ៉ាងមុតសម្លក់ខ្ញុំថា អ្នកឯងមិនមែនជាគ្រូបង្រៀនទេ អ្នកឯងជាអ្នកនិយាយទូរទស្សន៍ជាតិសម័យ លន់ នល់។

គឺចាប់តាំងពីថ្ងៃនោះមក យោធាខ្មែរក្រហមតាមដានខ្ញុំជាប់ទាំងយប់ទាំងថ្ងៃៗ។ រហូតមកដល់គេយក គេនាំខ្ញុំ កូនខ្ញុំនិងអ្នកផ្សេងទៀត រហូតមកដាក់នៅក្នុងភ្នំជីសូក្បែរភ្នំជីសូរគឺរ៉ៃថ្ម នៅភ្នំជីសូយ៉ាងមហាវេទនាបំផុត។ ខ្ញុំរស់នៅដូចជាសត្វនៅក្នុងទ្រុងរហែកៗគ្មានគ្រែគ្មានអីទាំងអស់។ រហែកៗជាមួយកូននៅក្បែរជើងភ្នំជីសូឲ្យរ៉ៃថ្ម។ ខ្ញុំរ៉ៃថ្មទាំងថ្ងៃទាំងយប់។ ថ្មើរម៉ានក៏ដោយ កណ្តាលអធ្រាត្រក៏ដោយឲ្យតែខ្មែរក្រហមត្រូវការគឺថាត្រូវតែទៅរ៉ៃថ្មហើយ លើកថ្មដាក់ឡាន។

[០៩:៤៦:២៩]

នៅទីកន្លែងនោះហើយដែលកូនប្រុស ប៉ូល ខ្ញុំកាន់តែឈឺខ្លាំងឡើង ហើយខ្ញុំមិនអាចនឹងព្យាបាលគ្មានថ្នាំអ្វីនឹងព្យាបាលកូនទៀតទេ។ រួចហើយពេលដែលឈឺខ្លាំងមែនទែនគឺនៅពេលដែលខ្មែរក្រហមបង្អត់បាយពួកខ្ញុំ បង្អត់បាយខ្ញុំ បង្អត់បាយអ្នកដែលទៅដូចខ្ញុំដែរចំនួន២ថ្ងៃ។ ខ្ញុំមានតែស្លឹកឈើទេដែលយកមកស្ងោរ ស្ងោរឲ្យកូនញ៉ាំ ហើយនិងកន្ទក់ដែលខ្ញុំបានសុំគេយ៉ាងលួចលាក់បំផុត និងអ្នកដែលគេធ្វើអង្ករគឺបានកន្ទក់បន្តិចសម្រាប់យកមកលាយជាមួយនឹងត្នោតទុំដែលខ្ញុំរើសបាននោះ យកមកធ្វើឲ្យកូនខ្ញុំដែលហើមខ្លួននោះញ៉ាំតែមិនបានអ្វីទាំងអស់ ព្រោះកូនកាន់តែឈឺខ្លាំងឡើង យកដៃទ្រុឌទៅគឺទ្រុឌចុះមួយគន្លាក់ម្រាមដៃ។

នៅពេលនោះ យប់នោះគឺយប់ដែលយើងអត់អ្វីហូបសោះ យើងហូបស្លឹកឈើ។ ខ្ញុំដេកឱបកូនៗ

ឈឺនឹងកូនមួយទៀត ខ្ញុំមិនបានដឹងថាកូនប្រុសខ្ញុំស្លាប់នៅពេលថ្មើរម៉ានសោះ។ ព្រោះដេកយប់ទៅមិនដឹងថាកូនស្លាប់ថ្មើរម៉ានផង។

[០៩:៤៧:៤៨]

ព្រលឹមឡើងខ្ញុំមើលទៅកូនធ្មេចភ្នែក ខ្ញុំយកដៃទៅបើកមាត់បើកភ្នែកតែកូនធ្មេចភ្នែកជិត ហើយសាច់ត្រជាក់ស្រុងទាំងអស់ ខ្ញុំដឹងថាកូនខ្ញុំស្លាប់ហើយ។ ខ្ញុំស្រែកទ្រហោយំយ៉ាងខ្លាំង កូនស្រីខ្ញុំក៏យំទាំងអស់គ្នាដែរ។ គឺយើងយំសោកសង្រេងនឹងកូនដែលស្លាប់ដោយអាណោចអធ័មនៅពេលអត់អាហារ នៅពេលដែលបរិភោគស្លឹកឈើ។

ថ្ងៃរសៀលខ្ញុំយកកូនខ្ញុំនឹងទៅកប់ទៀត។ ខ្ញុំបីកូនខ្ញុំខ្លួនឯងទៀត។ គ្មានអ្នកណាបីកូនខ្ញុំទេ គឺខ្ញុំបីកូនខ្ញុំខ្លួនឯងទៀត។ គ្រាន់តែមានមនុស្សទៅជួយជីករណ្តៅដើម្បីកប់កូននៅក្បែរភ្នំជីសូ។ ខ្ញុំយកកូនខ្ញុំទៅកប់នៅក្បែរភ្នំជីសូ រួចហើយខ្ញុំយកថ្ម ហើយយកចំណិតថ្ម ខ្ញុំចារឈ្មោះកូនខ្ញុំ ប៉ូល ដាក់នៅមុខផ្នូរខ្មោច ដើម្បីឲ្យខ្ញុំត្រឡប់មកវិញមកមើលផ្នូរខ្មោចកូន។ ខ្ញុំត្រលប់ទៅផ្ទះវិញយ៉ាងសោកសង្រេងបំផុតជាមួយកូនស្រីខ្ញុំ។

[០៩:៤៩:០០]

កូនស្រីខ្ញុំចាប់ឈឺខ្លាំងទៀត គឺរាកឈាមស្គមនៅតែស្បែកនិងឆ្អឹង។ រាកឈាមធ្លាក់សាល់គូទរាកមកឈាមៗ។ ពេលនោះ ពេលកូនស្រីឈឺនោះ ខ្ញុំអស់អ្វីហើយ ខ្ញុំអស់អ្វីនឹងដូរដោះហើយ អស់រលីងអត់មានថ្នាំអត់មានសង្កូវអីទាំងអស់។ កូនស្រីចាប់ឈឺខ្លាំងណាស់។ បាន១ខែក្រោយមក កូនប្រុសបងស្លាប់បាន១ខែហើយកូនស្រីក៏ស្លាប់ទៀត។ តែមុននឹងស្លាប់កូនស្រី ពីន ខ្ញុំជាកូនស្រីដែលឆ្លាតហើយសម្តីណាស់។ គេនិយាយរកខ្ញុំរហូតដល់គេបិទភ្នែកជិត។ កូនស្រីដែលមានអាយុទើបតែ៥ឆ្នាំប៉ុណ្ណោះ។ កូនស្រីនិយាយថា “សូមម៉ែយក ពីន ទៅឲ្យពេទ្យមើល។ សូមម៉ែរកថ្នាំឲ្យ ពីន ញ៉ាំផង។ ពីន ចង់រស់នៅជាមួយម៉ែ។ បន្តិចក៏និយាយទៀតថា “ម៉ែ ពីន អត់រស់ទេ ពីន ងាប់ហើយ។ តើថ្ងៃណាលោកឪពុកត្រឡប់ពីសហរដ្ឋអាមេរិកវិញ? ម៉េចក៏ទៅអាមេរិកយូរម្ល៉េះ? ម៉ែត្រូវតែរកពុកឲ្យឃើញ”។ រួចហើយកូនស្រីដកចង្កាមាន់ស្លាប់មួយរំពេច។

[០៩:៥០:២៣]

ខ្ញុំ ដល់កូនស្រីនេះស្លាប់ ខ្ញុំយំបោកខ្លួន ខ្ញុំក្លាយទៅជាមនុស្សឆ្កួត។ ខ្ញុំពាក់អាវខុសរាល់ថ្ងៃ ខ្ញុំវង្វេងទាំងអស់។ នេះជាលើកចុងក្រោយដែលខ្ញុំអស់រលីង អស់កូនរលីងពីខ្លួន។ ខ្ញុំដូចជាមនុស្សឆ្កួត ខ្ញុំពាក់អាវ

ខុស ខ្ញុំមិននិយាយជារកអ្នកណា អ្វីជាមួយអ្នកណាទាំងអស់។ ព្រោះខ្ញុំចង់ស្លាប់ជាមួយកូន។ កូនខ្ញុំស្លាប់អស់ហើយ។ ស្លាប់អស់ហើយកូនខ្ញុំ។ ក្រោយពីនោះមក ជីវិតខ្ញុំក្លាយទៅដូចជាមនុស្សឆ្កួត ឬអ្នកខ្លះគេនាំគ្នាហៅខ្ញុំថាជានាងបដាចារ។

នេះជាជីវិតទុក្ខសោករបស់កូនខ្ញុំទាំងបីដែលបានបាត់បង់ទៅដោយការធ្វើបាប ដោយការសម្លាប់ពីពួកខ្មែរក្រហម ពីយោធាខ្មែរក្រហម។ សូមលោកប្រធានមេត្តាជ្រាប! ហើយសូមអស់លោកក្នុងអង្គប្រជុំនេះមេត្តាជ្រាបពីជីវិតដ៏សោកសៅរបស់ខ្ញុំនេះជាមួយកូន។

[០៩:៥១:៣៤]

**ស៖** សូមអរគុណច្រើនលោកស្រី សុផានី។ លោកប្រធាន លោក លោកស្រីចៅក្រម នៅក្នុងពេលនេះខ្ញុំចង់បង្ហាញរូបថតទៅលើអេក្រង់ គឺនៅក្នុងសំណុំរឿងដែលមានលេខ E285.1.1 គឺមានលេខ ERN 00910047។ លោកស្រី សុផានី តើលោកស្រីស្គាល់រូបថតនេះដែរឬទេ?

**ឆ៖** អារូបថត ចាស! នេះហើយៗ គឺរូបថតកូនស្រីពៅរបស់ខ្ញុំឈ្មោះ លីឡាវ៉ូដី ហៅ ប៉ុម។ ខ្ញុំក៏មានយកមកជាមួយខ្ញុំដែរចាស។ យកជាប់មកជាមួយខ្ញុំដែរ។ នេះជាកូនស្រីពៅរបស់ខ្ញុំដែលត្រូវខ្មែរក្រហមចាក់ថ្នាំក្បាលស្លាប់នៅមុខគេបង្អស់។

**ស៖** តើលោកស្រីធ្វើយ៉ាងណាបានដឹងថា អ្នកដែលយកថ្នាំមកចាក់ក្បាលកូនស្រីហ្នឹងគឺជាខ្មែរក្រហម? តើលោកស្រីធ្វើយ៉ាងម៉េចដឹងថាគេហ្នឹងជាខ្មែរក្រហម?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោកស្រី!

ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិន។

[០៩:៥៣:១៤]

**លោកស្រី បេ សុផានី៖**

**ឆ៖** ពីព្រោះអ្នកស្រុកបានប្រាប់ខ្ញុំថានេះជាពេទ្យខ្មែរក្រហមហើយ។

**សួរដោយលោកស្រី ទូស៊ីន សាកាវ៉ាទី៖**

**ស៖** សូមអរគុណលោកស្រី។ តើលោកស្រីមានរូបថតកូនលោកស្រីដទៃទៀតទេ នៅថ្ងៃនេះ?

**ឆ៖** ចាស ខ្ញុំអត់មានទេ ខ្ញុំមានតែរូបថតមួយនេះហើយ ដែលខ្ញុំបានផ្ញើមកប្ដីខ្ញុំមុនខ្មែរក្រហមចូលទីក្រុងភ្នំពេញចំនួន១អាទិត្យ។ ខ្ញុំផ្ញើរូបថតនៅពេលដែលកូនស្រីខ្ញុំចេះក្រឡាប់ ខ្ញុំផ្ញើមកប្ដីខ្ញុំនៅសហ-

រដ្ឋអាមេរិក។ ដូច្នេះហើយបានសល់តែរូបថតមួយនេះ រីឯរូបថតកូនពីរនាក់ទៀត គឺគ្មានទេ។ ពួកខ្មែរក្រហមកម្ទេចគ្មានសល់អ្វីឡើយ។

[០៩:៥៤:១០]

**ស៖** សូមអរគុណច្រើនលោកស្រី សុផានី។ នៅពេលចុងបញ្ចប់ នៅពេលដែលបញ្ចប់របបហ្នឹង តើគ្រួសារលោកស្រីមានគ្នាប៉ុន្មាននាក់ដែលនៅរស់រានមានជីវិត?

**ឆ៖** នៅពេលដែលរបបខ្មែរក្រហមបានដួលរលំហើយ គឺខ្ញុំគ្មានសេសសល់អ្វីទេ។ ខ្ញុំបានទៅរកឪពុកម្ដាយខ្ញុំនៅទីរួមខេត្តកំពង់ឆ្នាំង តែគ្មានទាល់តែសោះ ឃើញតែដីទទេ និងដើមត្នោតដែលម្ដាយខ្ញុំបានដាំប៉ុណ្ណោះ។ អ្នកភូមិបានប្រាប់ថា ពួកខ្មែរក្រហមបានសម្លាប់គ្រួសារខ្ញុំទាំងមូលហើយ សម្លាប់ឪពុកខ្ញុំមុនគេបង្អស់។ ខ្ញុំខំរកគ្រួសារខាងប្ដីទៀត តែគ្មានសល់អ្វីទាំងអស់ គឺសម្លាប់ទាំងអស់មួយពូជទាំងខ្ញុំ ទាំងខាងខ្ញុំ ទាំងខាងប្ដីខ្ញុំ អស់មួយពូជ។ ខ្ញុំគ្មានសេសសល់អ្វីឡើយ សូម្បីតែក្មួយបង្កើតមួយក៏អត់ដែរសព្វថ្ងៃនេះ។ ខ្ញុំនៅសល់តែប្ដីខ្ញុំម្នាក់ដែលនៅសហរដ្ឋអាមេរិក។

**ស៖** សូមអរគុណច្រើនលោកស្រី សុផានី។ ខ្ញុំចង់សួរសំណួរបន្ថែមពីរបីទៀត។ ទាក់ទងទៅនឹងបទពិសោធន៍នៃភាពរន្ធត់--

**ប្រធានអង្គជំនុំ៖**

ពេលវេលារបស់សម្រាប់នៅសល់តែ៤នាទីទៀតទេ សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ទាំងគិតសរុបទាំងការសួរសំណួរទៅជនជាប់ចោទ និងការឆ្លើយតបរបស់ជនជាប់ចោទផង។

**លោកស្រី ទូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន។

[០៩:៥៥:៥១]

**សួរដោយលោកស្រី ទូស៊ីន សាកាវ៉ាទី៖**

**ស៖** តើលោកស្រីអាចពណ៌នាអំពីបទពិសោធន៍លោកស្រី ថាតើបទពិសោធន៍ដែលលោកទទួលបានពីរបបខ្មែរក្រហមហ្នឹង ប៉ះពាល់ដល់សុខភាពលោកស្រីយ៉ាងដូចម្ដេចដែរ?

**លោកស្រី បេ សុផានី៖**

**ឆ៖** ចាស ខ្ញុំសូមជម្រាបលោកប្រធាន និងជម្រាបអង្គប្រជុំ។ ពេលដែលខ្ញុំជួបជាមួយប្ដីខ្ញុំហើយនៅឆ្នាំ១៩៨៣ ក្នុងសភាពប្ដីខ្ញុំជាជនពិការ។ គឺថាដោយសារការទុក្ខព្រួយទុក្ខសោកពីរបប ប៉ុល

ពត នេះហើយ ដែលធ្វើឱ្យខ្ញុំមានវិបត្តិផ្លូវចិត្ត មានជំងឺនៅក្នុងខ្លួន។ ឧទាហរណ៍ឧបមាដូច ឧទាហរណ៍ដូចជាឈឺក្បាល វិលមុខ យល់សប្តិអាក្រក់ មិនដែលយល់សប្តិល្អទេ។ ចួនកាលខ្ញុំដេកមមើមមាយស្រែកនៅពេលយប់។ ខ្ញុំភ័យ ខ្ញុំមានការតក់ស្លុតដោយសារការដែលខ្ញុំទទួលទុក្ខសោកពីរបបខ្មែរក្រហមនេះហើយ រហូតមកដល់សព្វថ្ងៃនេះ ក៏ខ្ញុំនៅតែមានជំងឺមមើមមាយ ដេកយល់សប្តិអាក្រក់ពីសង្គម ប៉ុល ពត ឃើញតែពួកយោធាខ្មែរក្រហម ប៉ុល ពត ដេញតាមចាប់ ដេញតាមសម្លាប់ខ្ញុំគ្មានឈប់ឈរ។

[០៩:៥៧:១៦]

**លោកស្រី ទូស៊ីន សាកាវ៉ាទី៖**

លោកប្រធាន ខ្ញុំគិតថាយើងមានពេលវេលា១ម៉ោងកន្លះបន្ថែមទៀត។ ដូច្នេះ តើខ្ញុំអាចចោទសំណួរបន្តិចទៅលើសាក្សីបន្ថែមទៀតបានដែរឬទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេ! ព្រោះនៅពេលវេលាគាត់ត្រូវសួរសំណួរ ហើយនិងឆ្លើយតបនឹងសំណួរទៀតព្រោះស្រីប្រើប្រាស់ពេលវេលាមិនមានប្រសិទ្ធភាពប៉ុន្មានទេ។

**លោកស្រី ទូស៊ីន សាកាវ៉ាទី៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធានថា សូមសួរសំណួរខ្លីតូចមួយទេ ហើយសូមឱ្យលោកស្រី សុផានី គាត់ឆ្លើយដោយខ្លី។ តើលោកប្រធានអនុញ្ញាតដែរទេ?

**សួរដោយលោកស្រី ទូស៊ីន សាកាវ៉ាទី៖**

**ស៖** លោកស្រី សុផានី--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះដូចមិនទាន់អនុញ្ញាតផងអំមិញ! យើងអនុញ្ញាត តែមួយសំណួរចុងក្រោយ។

**លោកស្រី ទូស៊ីន សាកាវ៉ាទី៖**

លោកប្រធាន បន្ទាប់ពីខ្ញុំចោទសំណួរហើយគឺថាលោកស្រី សុផានី គាត់មានសំណួរពីរបន្ថែមដើម្បីសួរទៅកាន់ជនជាប់ចោទទៀត។ តើលោកប្រធានអនុញ្ញាតឱ្យគាត់សាកសួរទៅជនជាប់ចោទដែរឬទេ?

[០៩:៥៨:៤៩]

**ប្រធានអង្គជំនុំ៖**

លោកស្រី តាំងសំណួរទៅ បើលោកស្រីតវ៉ារបៀបនេះ ពេលវេលានឹងអស់ហើយ។ យើងបានជម្រាបហើយអំមិញ។ យើងលៃពេលវេលាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនេះតាំងសំណួរចំពោះជនជាប់ចោទ និងស្តាប់ការឆ្លើយតបរបស់ជនជាប់ចោទទៅនឹងសំណួរដែលដើមបណ្តឹងរដ្ឋប្បវេណីនឹងសួរ។ នេះជាពេលដ៏សំខាន់ យើងយល់ថាចាំបាច់ត្រូវតែផ្តល់លទ្ធភាពនេះជូនគាត់។ អ៊ីចឹងហើយបានជាយើងបានជម្រាបលោកស្រីថា គប្បីប្រើប្រាស់ពេលវេលាឲ្យអស់ ឲ្យមានប្រសិទ្ធភាពតាមពេលវេលាដែលអង្គជំនុំជម្រះបានកំណត់។

**លោកស្រី ទូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទូស៊ីន សាកាវ៉ាទី៖**

**ស៖** លោកស្រី សុផានី សូមលោកស្រីពណ៌នាដោយសង្ខេបអំពីរោគសញ្ញា ឬក៏ផលវិបាកដទៃទៀតដែលលោកស្រីទទួលក្រោយពេលចប់របបខ្មែរក្រហម? សូមលោកស្រីរៀបរាប់ដោយសង្ខេប។

[០៩:៥៩:៤៩]

**លោកស្រី បេ សុផានី៖**

**ឆ៖** ដូចខ្ញុំធ្លាប់បានជម្រាបហើយដែរថា ក្រោយរបបខ្មែរក្រហមនេះ គឺខ្ញុំមានជំងឺវិបត្តិផ្លូវចិត្ត។ ផ្លូវកាយក៏ខ្ញុំមានដែរ ពីព្រោះខ្ញុំមានស្លាកស្នាមដែលរបួសដោយថ្ម យោធាខ្មែរក្រហមបង្ខំខ្ញុំឲ្យរែថ្ម។ ខ្ញុំមានរបួសនៅជើងខ្ញុំ ហើយខ្ញុំជំងឺ មិនសុខភាពខ្ញុំមិនដូចមុនទេ។ អស់កម្លាំងឈឺក្បាល វិលមុខ យល់សប្តិអាក្រក់ យល់សប្តិមមើមមាយ ដេកយប់ស្រែក។ នេះជាជំងឺរបស់ខ្ញុំក្រោយពីរបប ប៉ុល ពត មកនេះ។

**លោកស្រី ទូស៊ីន សាកាវ៉ាទី៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរសំណួរបន្ថែមមួយទៀតទៅដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកប្រធានអនុញ្ញាតដែរទេ?

[១០:០០:៤២]

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេ។ ដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរអ្វីសួរដល់ជនជាប់ចោទដែរទេ? បើមានសំណួរចង់សួរដល់ជនជាប់ចោទ សូមអញ្ជើញ!

**លោកស្រី បេ សុផានី៖**

ចាស លោកប្រធាន ខ្ញុំសូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរដែលចង់សួរទៅលោកខាងចុងចោទ ចាស។ ខ្ញុំមានសំណួរបី លោកប្រធាន។

សំណួរទី១របស់ខ្ញុំ ខ្ញុំចង់សួរលោកថា លោក ខៀវ សំផន លោក នួន ជា លោកជាមេដឹកនាំប្រទេស ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ របបខ្មែរក្រហម តើលោកមានដឹងទេ ថាខ្មែរក្រហមសម្លាប់កូនក្មេង សូម្បីតែកូនក្មេងខ្ចីតូចដែលមិនដឹងអ្វីក៏សម្លាប់ដែរ ដូចជាកូនខ្ញុំនេះជាដើម។

សំណួរទី២ តើលោកមានដឹងដែរឬទេ ថាខ្មែរក្រហម យោធាខ្មែរក្រហមដើរវើ ដើរធ្វើបាបកូនក្មេង សួរចម្លើយកូនក្មេង បង្ខំឲ្យកូនក្មេងឆ្លើយ ឲ្យប្រាប់ពីរឿងឪពុក ពីរឿងម្ដាយ តើលោកមានដឹងទេ? ហើយលោកមានបង្គាប់ឲ្យខ្មែរក្រហមធ្វើយ៉ាងដូច្នេះទេ?

សំណួរទី៣របស់ខ្ញុំ បើលោកមិនបានដឹង មិនបានឮ មិនបានបង្គាប់ឲ្យយោធាខ្មែរក្រហមធ្វើដូច្នេះទេ តើអ្នកណាធ្វើ? តើអ្នកណាបង្គាប់? តើអ្នកណាធ្វើឲ្យធ្វើយ៉ាងនេះ? ក្នុងនាមលោកជាអ្នកដឹកនាំប្រទេស ខ្ញុំសូមលោកជម្រាបប្រាប់ខ្ញុំរឿងនេះបានដែរឬទេ? ចាស សូមអរគុណ។

[១០:០២:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ ជាគោលការណ៍ គឺសួរតាមរយៈប្រធាន ប៉ុន្តែអំមិញគឺសួរដោយសារលោក ខៀវ សំផន នៅទីនេះ។ អ៊ីចឹងគឺសូមអង្គជំនុំជម្រះសូមបញ្ជូននូវសំណួរដែលសួរដោយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ទាំងបីសំណួរ ជូនទៅលោកជនជាប់ចោទដើម្បីឆ្លើយតបទៅនឹងសំណួរទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ហើយជាដំបូងនេះ ជូនទៅលោក ខៀវ សំផន មុនលោក នួន ជា។

សូមអញ្ជើញ លោក ខៀវ សំផន!

**លោក ខៀវ សំផន៖**

សូមគោរពលោកប្រធាន។ សូមគោរពអស់លោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។ សូមគោរពបងប្អូនរួមជាតិទាំងអស់ដែលនៅទីនេះ។

សូមជម្រាបសួរលោកស្រី បេ សុផានី។ ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោកស្រី។

[១០:០៣:៤៤]

ទី១ ខ្ញុំសូមជម្រាបលោកស្រីថា ខ្ញុំមិនមែនជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ។ ពិតមែនតែខ្ញុំ

មានស្លាកជាប្រមុខរដ្ឋ។ ស្លាកធំណាស់ ក៏ប៉ុន្តែខ្ញុំគ្មានអំណាចអីទេ។ តើខ្ញុំដឹងទេថាកូនក្មេងត្រូវបានយោធាខ្មែរក្រហមសម្លាប់។ ខ្ញុំសូមទោសលោកស្រី ខ្ញុំមិនដឹងទាល់តែសោះ។ អានេះជាការពិតលោកស្រី។ ខ្ញុំមិនដឹងមែនទាល់តែសោះតែម្តង។

សំណួរទី២ តើហេតុអីបានគេកូនក្មេងទៅវ៉ៃដំ សួរចម្លើយយ៉ាងនេះ? តើទាហានខ្មែរក្រហមបានទទួលបញ្ជាឲ្យធ្វើយ៉ាងនេះ? ឬយ៉ាងណា? ឬយ៉ាងម៉េច? ចំពោះសំណួរទី២នេះ ក៏ខ្ញុំអត់ដឹងដែរលោកស្រី។ តាមខ្ញុំដឹង ខ្ញុំដូចជាគ្មានបញ្ជាអីឲ្យទៅធ្វើយ៉ាងនេះទាល់តែសោះ។

ឥឡូវសំណួរទី៣ ហើយ -- អ៊ូ! ខ្ញុំសូមថែមនឹងសំណួរទី២ ហើយខ្ញុំផ្ទាល់ខ្លួនក៏ខ្ញុំមិនបានបញ្ជាឲ្យយោធាទៅធ្វើយ៉ាងនេះទាល់តែសោះ។ ខ្ញុំគ្មានសិទ្ធិអំណាចលើកងទ័ព សូម្បីតែមួយក្រុមតូចក៏គ្មានដែរលោកស្រី។ ដូច្នេះ ខ្ញុំមិនអាចមានសិទ្ធិអីទៅបញ្ជាយ៉ាងនេះទេ។ ហើយជាផ្ទាល់ខ្លួនខ្ញុំមិនមែនមនុស្សសាហាវឃោរឃៅ ល្ងង់ខ្លៅរបៀបនេះទេ។ ហ្នឹងខ្ញុំសូមថែមសំណួរទី២ តែប៉ុណ្ណឹង។

[១០:០៦:២៨]

សំណួរទី៣ បើខ្ញុំមិនដឹង តើអ្នកណាធ្វើ? តាមដែលខ្ញុំស្តាប់លោកស្រី លោកស្រីថាបានអញ្ជើញទៅត្រើយស្លា បើត្រើយស្លាវាមានន័យថា អ្នកដែលទទួលខុសត្រូវតំបន់នោះគេធ្វើហើយ គេអ្នកចាត់ចែងហើយ។ តាមខ្ញុំយល់។ ដូច្នេះខ្ញុំប្រឆាំងដាច់ខាតនឹងអំពើឃោរឃៅឆ្គួតលីលាបែបនេះ ប៉ុន្តែសោក -- ខ្ញុំសោកស្តាយណាស់ដែលត្រូវតែជម្រាបលោកស្រីថា ខ្ញុំវាអត់ដឹង ខ្ញុំសូមទោសលោកស្រី។ សូមជម្រាបតែប៉ុណ្ណឹងបាទ។ ខ្ញុំអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តនេះអង្គជំនុំជម្រះសូមបញ្ជូននៅសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះជូនទៅលោក នួន ជា ដើម្បីមានឱកាសឆ្លើយតបទៅនឹងសំណួរ។

លោក នួន ជា? ស្តាប់បានទេលោក នួន ជា តើលោកឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី សុផានី ដែរឬទេ?

[១០:០៨:៣៤]

**លោក នួន ជា៖**

សូមគោរពអង្គសវនាការទាំងមូល សូមគោរពលោកប្រធាន។ ខ្ញុំ នួន ជា សូមគោរពទៀតចំពោះលោកស្រី សុផានី នេះ បើខ្ញុំចាំមិនខុស។ ខ្ញុំសូមសម្តែងនូវមរណទុក្ខ សោកស្តាយចំពោះការ

បាត់បង់អាយុជីវិតរបស់ក្រុមគ្រួសាររបស់លោកស្រី ដូចលោកស្រីបានពណ៌នាមកហើយនេះ។ ខ្ញុំសូមចូលរួមមរណទុក្ខជាមួយលោកស្រីផងដែរ ខ្ញុំមិនបានដឹងទេរឿងនេះ ហើយខ្ញុំសូមបញ្ជាក់ម្តងទៀតថា កម្ពុជាប្រជាធិបតេយ្យមិនមានគោលនយោបាយឯណាទៅសម្លាប់ប្រជាជនឯងនោះទេ។

[១០:០៩:៣៥]

ផ្ទុយទៅវិញមានតែគោលនយោបាយជួយស្រោចស្រង់ អប់រំកសាងឲ្យទៅជាពលរដ្ឋល្អទាំងអស់គ្នា ជាអ្នកស្នេហាជាតិ ស្នេហាប្រជាជន ស្នេហាក្រុមគ្រួសារទាំងអស់គ្នា។ ដូច្នោះយ៉ាងណាមិញ វាដូចជាកូនចៅរបស់លោកស្រីក៏ដោយ ក៏កម្ពុជាប្រជាធិបតេយ្យគ្មានគោលនយោបាយណា ដើម្បីទៅសម្លាប់កុមារ សម្លាប់កូនក្មេងទេ។ នេះខ្ញុំសូមបញ្ជាក់ម្តងហើយម្តងទៀត។ ហើយខ្ញុំម្តងទៀត ខ្ញុំសូមចូលរួមមរណទុក្ខចំពោះក្រុមគ្រួសាររបស់លោកស្រី។ សូមអស់ សូមគោរពលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

បាទ មានពេលវេលា១០នាទី។

[១០:១០:៤០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរលោកប្រធាន ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរលោកស្រី បេ សុផានី យើងមានពេវេលាខ្លីណាស់ ក៏ប៉ុន្តែរឿងរ៉ាវរបស់លោកគឺវែងឆ្ងាយ ហើយមានព័ត៌មានសំខាន់ៗជាច្រើន។ ដូច្នេះ ខ្ញុំផ្តោតទៅលើតែសំណួរបន្ថែមមួយចំនួនតែប៉ុណ្ណោះ ព្រោះខ្ញុំមានពេលខ្លី។ ហើយខ្ញុំធ្វើយ៉ាងណាកុំឲ្យលោកស្រី -- បន្ថែមការឈឺចាប់ទៅលើលោកស្រីថែមទៀត។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នៅក្នុងឯកសាររបស់លោកស្រី ជាពិសេសនៅក្នុងសំបុត្រដែលលោកស្រីសរសេរទៅលោកអាល់សាន់តូលី លោកស្រីបានបញ្ជាក់ថាលោកស្រីបានបាត់បង់សមាជិកគ្រួសារសាច់ថ្លៃជាច្រើន ហើយលោកស្រីដឹងថាមានការនាំទៅទន្លេបាទីដើម្បីសម្លាប់ចោល។

ខ្ញុំចង់ដឹងថាហេតុអ្វីបានជាលោកស្រីដឹងរឿងនេះ? ហើយលោកស្រីដឹងទេថាគេសម្លាប់នោះដោយសារគេដឹងអត្តសញ្ញាណរបស់គាត់ ដែលថាជាប់សាច់ញាតិជាមួយនឹងលោក លន់ នល់ នោះ តើអ៊ីចឹងមែនទេ?

[១០:១១:៥៨]

**លោកស្រី បេ សុផានី៖**

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំបានព័ត៌មាននេះពីអ្នកស្រុក អ្នកស្រុលដែលមានស្រុកកំណើតម្ដាយក្មេកខ្ញុំ ហើយពេលដែលខ្មែរក្រហមបណ្ដេញប្រជាជនចេញពីផ្ទះទៅ គឺឪពុកខ្ញុំក្មេកខ្ញុំ ម្ដាយក្មេកខ្ញុំ បងថ្លៃខ្ញុំទាំងគ្រួសារគឺសំដៅទៅភូមិកំណើត គឺភូមិរុន ក្នុងខេត្តតាកែវ។ ដូច្នេះ អ្នកភូមិគេស្គាល់ច្បាស់ គេដឹងទាំងអស់ គេដឹងប្រវត្តិក្រុមគ្រួសារទាំងអស់ គេដឹងថាឪពុកក្មេកខ្ញុំជាឪពុកក្មេក លន់ នល់ គេដឹងច្បាស់ គេដឹងរហូតដល់បងថ្លៃខ្ញុំធ្វើអ្វីទៀត គេដឹងទាំងអស់។ ជម្រាបលោកសូមជម្រាបថាស។

**ស៖** តើសមាជិកគ្រួសារសាច់ថ្លៃរបស់លោកស្រីហ្នឹង សុទ្ធតែជាកងទ័ពដែលជាកម្មាភិបាលកងទ័ព លន់ នល់ មែនទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោក គ្រួសារខាងប្ដីខ្ញុំគឺជាអ្នករដ្ឋការទាំងអស់ ភាគច្រើន ហើយធ្វើជាមន្ត្រីធំៗទៀត។ ដូច្នេះហើយបានជាផលវិបាកធ្លាក់មកហើយគ្រួសារ លន់ នល់ នេះជាខ្លាំងក្លាបំផុត រហូតដល់គ្រួសារឪពុកម្ដាយខ្ញុំបង្កើតដែលនៅទីរួមខេត្តកំពង់ឆ្នាំង ក៏ខ្មែរក្រហមសម្លាប់ទាំងអស់ ដោយសារមានខ្សែរយៈទាក់ទងដែលជាដន្លង ឪពុកម្ដាយខ្ញុំជាដន្លងរបស់ឪពុកក្មេក លន់ នល់។ ដូច្នេះ ខ្មែរក្រហមដឹងទាំងអស់ ព្រោះទៅស្រុកកំណើតរបស់ខ្លួន។

[១០:១៣:៤៦]

**ស៖** សូមអរគុណ។ លោកស្រីក៏បានរៀបរាប់ផងដែរថា មិត្តភក្តិមួយចំនួនដែលជាប្ដីរបស់លោកស្រី ដែលជាទាហាន លន់ នល់ នោះក៏បានស្លាប់ក្នុងរបបខ្មែរក្រហមផងដែរ។ បើតាមការសង្កេតឃើញរបស់លោកស្រីនោះ តើមន្ត្រីយោធា និងកម្មាភិបាលរបស់ទាហាន លន់ នល់ ត្រូវបានស្វែងរកចាប់ខ្លួនដោយទាហានខ្មែរក្រហមនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មែនដែរឬទេ?

**ឆ៖** រឿងនេះគឺថាខ្ញុំមិនបានច្បាស់លាស់ក្នុងរឿងដែលដេញចាប់នេះទេ ក៏ប៉ុន្តែខ្ញុំដឹងរឿងស្លាប់ដែលយោធាខ្មែរក្រហមសម្លាប់ពួកទាហាន លន់ នល់ ជាពិសេសគឺនាយទាហាន ដែលនៅជំនាន់ប្ដីៗខ្ញុំគឺស្លាប់អស់ច្រើននាក់ណាស់។ សព្វថ្ងៃនៅសល់តែប៉ុន្មាននាក់ប៉ុណ្ណោះ។ ប្រាំប្រាំមួយនាក់ប៉ុណ្ណោះដែលនៅ

រស់នៅសហរដ្ឋអាមេរិកខ្លះ នៅស្រុកខ្មែរខ្លះ។

**ស៖** ឥឡូវនេះខ្ញុំចង់និយាយអំពីការប្រព្រឹត្តចំពោះប្រជាជន ១៧ មេសា នៅក្នុងភូមិនានា ដែលលោកស្រីបានធ្វើការ។ លោកស្រីបានឆ្លើយថានៅពេលដែលអ្នកភូមិឲ្យម្ហូបដល់កូនរបស់លោកស្រីនោះ គឺថាខ្មែរក្រហមបានហាមឃាត់។ តើខ្មែរក្រហមមានបានពន្យល់ប្រាប់ទេ ថាហេតុអីនៅពេលដែលមានការឲ្យម្ហូបអាហារគ្នារវាងប្រជាជនចាស់នឹងប្រជាជនថ្មីហ្នឹងមានការហាមឃាត់? តើហេតុអ្វីបានជាគេបែងចែកប្រជាជន ១៧ មេសា និងប្រជាជនមូលដ្ឋាននោះឲ្យនៅផ្សេងពីគ្នា?

[១០:១៥:៤០]

**ឆ៖** ខ្ញុំសូមជម្រាបលោក នេះជាការពិតណាស់ គឺខ្មែរក្រហមបានប្រាប់ខ្ញុំយ៉ាងជាក់ច្បាស់ថាខ្ញុំមានវណ្ណៈខុសពីអ្នកប្រជាជនចាស់ អ្នកមូលដ្ឋាន គឺវណ្ណៈខុសគ្នា។ គេបានប្រាប់ខ្ញុំថា ខ្ញុំជាប្រជាជនថ្មីជាអ្នក១៧ មេសា។ ចំណែកអ្នកដែលនៅក្នុងភូមិចាស់នោះគឺជាអ្នកមូលដ្ឋាន។ ដូច្នេះមិនអាចទាក់ទងគ្នាបានទេ ព្រោះជាវណ្ណៈខុសគ្នា។

**ស៖** តើប្រជាជនមូលដ្ឋាន និងប្រជាជន ១៧ មេសា នេះត្រូវបានប្រព្រឹត្តស្មើភាពគ្នាដែរឬទេនៅក្នុងភូមិនីមួយៗ? ឧទាហរណ៍ដូចជាម្ហូបអាហារការងារ កន្លែងរស់នៅ ការថែទាំសុខភាព ឬក៏ការបាត់ខ្លួនជាដើមនោះ? តើមានលក្ខណៈដូចគ្នា ឬក៏ខុសគ្នា?

**ឆ៖** ចាស ខ្ញុំសូមជម្រាបលោក គឺថាមានលក្ខណៈខុសគ្នាឆ្ងាយណាស់។ គេអ្នកប្រជាជនចាស់ អ្នកមូលដ្ឋានចាស់ដែលគេហៅថារស់នៅក្នុងតំបន់រំដោះនោះ គឺគេមានប្រៀបជាងប្រជាជនថ្មី គេមានបាយហូបចុកគ្រប់គ្រាន់ខុសពីប្រជាជន ថ្មីអ្នក១៧មេសា ដូចជារូបខ្ញុំនេះជាដើម ដែលមានតែបបររាវៗ មិនទាំងឃើញគ្រាប់អង្ករផង រាវៗ ហើយមានម្ហូបមានតែអំបិល ជួនកាលក៏មានត្រីតិចតួចណាស់ ដែលមានត្រីងៀតតិចតួច ប្រហុកតិចតួច តែភាគច្រើនគឺអំបិល។ មិនតែប៉ុណ្ណោះគេធ្វើបាបគេបង្អត់បាយទៀត។ ដូចដែលខ្ញុំបានជម្រាបមកហើយ ដែលកូនប្រុសខ្ញុំស្លាប់គឺនៅពេលដែលគេអត់ឲ្យអាហារខ្ញុំបរិភោគ អត់ឲ្យហូប។ កូនខ្ញុំស្លាប់ ខ្ញុំគ្មានអ្វី មានតែស្លឹកឈើនៅក្នុងឆ្នាំង ហើយនិងកន្ទក់។ លោកជ្រាបស្រាប់ ហើយតើអ្នកណាគេហូបកន្ទក់? កន្ទក់នេះសម្រាប់តែសត្វជ្រូកទេ តែចំពោះមនុស្សគឺគ្មានទេ។ ប៉ុន្តែខ្ញុំយកកន្ទក់ ហើយហូបស្លឹកឈើនៅពេលដែលកូនប្រុសខ្ញុំស្លាប់នោះ។ ខ្ញុំសូមជម្រាបលោក។

[១០:១៧:៥៩]

**ស៖** នៅក្នុងឯកសារដដែលគឺលេខ D22/3850 ជាឯកសាររបស់លោកស្រីនៅទំព័រជាភាសា

បារាំង 00860741, ជាភាសាអង់គ្លេស 00867208, ជាភាសាខ្មែរ 00571064។ លោកស្រីបានសរសេរថាចំពោះខ្ញុំ ខ្ញុំនៅទីនោះគឺថានៅដូចជាអ្នកទោស ដូចជាឈ្លើយសឹកអ៊ីចឹង។ ហើយនៅវ៉ៃថ្ម ដូចឈ្លើយសឹក។ តើគេប្រើពាក្យថាឈ្លើយសឹកនេះតែចំពោះលោកស្រីទេ ឬក៏ប្រើទូទៅចំពោះប្រជាជន ១៧ មេសាទាំងអស់? ហើយហេតុអ្វី?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា គេចាត់ទុកយើងជាប្រជាជនថ្មី ជាប្រជាជនអ្នក១៧ មេសា ដែលមានវណ្ណៈខុសគ្នាពីប្រជាជនចាស់ពីអ្នកមូលដ្ឋាន។ គឺទៅធ្វើការ គេយកកាំភ្លើងដើរតាមយើងទៅធ្វើការ។ ពេលយប់ក៏ដោយ ពេលថ្ងៃក៏ដោយ គេដើរលបមើលនៅតាមខ្ទមៗ គឺគេតាមដានយើងគ្រប់ជំហាន គ្មានចន្លោះចំពោះអ្នកប្រជាជនថ្មីដូចជារូបខ្ញុំ។ ហើយគេបង្ខំឲ្យធ្វើការឲ្យវ៉ៃថ្ម ដូចជារូបខ្ញុំ។ គេបង្ខំឲ្យវ៉ៃថ្ម ក្នុង ១ថ្ងៃឲ្យបាន បីតៅថ្ម និងកម្ទេចថ្មតូចៗឲ្យបានបីតៅ គេថាគេយកទៅធ្វើផ្លូវថ្នល់។ ហើយដែលខ្ញុំត្រូវរបួសជើងនេះគឺគេបង្ខំឲ្យខ្ញុំវ៉ៃថ្មធំ ផ្ទាត់មកត្រូវរបួសជើងខ្ញុំរហូតដល់សព្វថ្ងៃ។

[១០:១៩:៥៧]

ជម្រាបលោក ជម្រាបបងប្អូន ជម្រាបលោកប្រធាន ខ្ញុំគ្មានថ្នាំអ្វីនឹងព្យាបាលជំងឺខ្ញុំដែលមុតដោយថ្មនេះទេ ក្នុងរយៈពីរ បីខែ គឺដំបៅរីកចង់ចេញដង្កូវ។ រីក ខ្ញុំនៅអូសគូទទៅធ្វើការ បើខ្ញុំមិនទៅទេគឺខ្មែរក្រហម យោធាខ្មែរក្រហមមិនឲ្យបបរខ្ញុំហូបទេ គេផ្តាច់របប មិនឲ្យរបបទេ។ ដូច្នេះខ្ញុំទៅទាំងឈឺទាំងឈឺ ទាំងឈឺ ហើយខ្ញុំគ្មានថ្នាំអ្វីព្យាបាលទាំងអស់ មានតែថ្នាំជក់ ដែលយោធាខ្មែរក្រហមជក់បារី ហើយបោះចោលនូវកន្ទុយបារីនោះ។ ពួកអ្នកស្រុកបានប្រាប់ខ្ញុំថា ឲ្យយកថ្នាំហ្នឹងយកមកបិទជាមួយនឹងស្ករត្នោត ដែលខ្ញុំ -- គេលួចលាក់ឲ្យខ្ញុំស្ករត្នោតយកមកបិទដំបៅខ្ញុំ។ មានតែប៉ុណ្ណឹងទេ។ ជម្រាបលោក។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំមិនមានពេលវេលាច្រើនសួរលោកស្រីទេ។ ខ្ញុំនៅសល់តែពីរសំណួរទៀតទេ។ នៅក្នុងឯកសារដដែលនោះ លោកស្រីបានលើកពីហេតុការណ៍មួយដែលស្ត្រីម្នាក់ត្រូវបានគេវ៉ៃដាក់ទណ្ឌកម្មដោយខ្មែរក្រហម ពីព្រោះថាកូនរបស់គាត់ហ្នឹងមានលួចល្ពៅ។ លោកស្រីបានបញ្ជាក់ថា មេកងហ្នឹងបានមកជួបគាត់។ ហើយបានប្រាប់ថា គេមិនមែនវ៉ៃក្នុងនាមបុគ្គលទេ គឺថារបបទេ អ្នកវ៉ៃនោះ គឺអង្គការៗវ៉ៃរបបសក្តិភូមិ របបចក្រពត្តិ។ តើលោកស្រីមានកត់សម្គាល់ឃើញអំពីការមើលងាយ ឬក៏ការប្រមាថចំពោះប្រជាជនដែលត្រូវបានគេចាត់ទុកថា ជាពួកគហបតី ជាពួកនាយទុនហ្នឹងដែរឬទេ?

[១០:២១:៥០]

**ឆ៖** ជាការពិតណាស់លោក ពីព្រោះគេវ៉ៃអ្នកស្រីម្នាក់ដែលប្ដីមានប្រវត្តិជាទាហាន ហើយ ដែលអង្គុយវ៉ៃថ្មនៅក្បែរខ្ញុំ។ ដោយសារអ្វី? ដោយសារយោធាខ្មែរក្រហមទៅវ៉ៃកូនក្មេងនៅតាមផ្ទះ នៅពេលដែលម្ដាយមកវ៉ៃថ្ម។ យោធាខ្មែរក្រហមដើរវ៉ៃកូនក្មេង ទាំងកូនខ្ញុំ ទាំងកូនគេ វ៉ៃសួរចម្លើយទៅរឿងឪពុកម្ដាយ។ ឪពុកម្ដាយអ្វីអី? ម្ដាយធ្វើអី? ឪពុកធ្វើអ្វី? ម្ដាយដែលលួចគេទេ? គឺសួរយ៉ាងនេះ កូនខ្ញុំជាភស្តុតាង។ ពេលខ្ញុំត្រឡប់មកវិញ ខ្ញុំមើលខ្នងកូនខ្ញុំសុទ្ធតែស្នាម ហើយគេយកផ្សុង -- យោធាខ្មែរក្រហមយកផ្សុងមកគូសលើខ្នងកូនខ្ញុំដែលកំពុងហើមពោរ គូសធ្វើដូចជាល្បែងលេង គូសលើខ្នងកូនខ្ញុំ។ ហើយវ៉ៃកូនខ្ញុំស្នាមរំពាត់នៅលើខ្នងកូនប្រុស កូនស្រីខ្ញុំ ជារាល់ពេល ពេលខ្ញុំត្រឡប់ធ្វើការវិញ។ កូនខ្ញុំយំប្រាប់ខ្ញុំ ហើយបង្ហាញនូវខ្នង ប្រាប់ខ្ញុំថា គេវ៉ៃ គេវ៉ៃកូន គេសួរអំពីឪពុក គេសួរអំពីម្ដាយ។ តើម្ដាយធ្វើការអ្វី? រកស៊ីអ្វី? ឪពុកនៅឯណា ឥឡូវនេះ? ហើយម្ដាយមានដែលលួចគេទេ?

[១០:២៣:០២]

ក៏ប៉ុន្តែខ្ញុំសូមជម្រាបលោក ខ្ញុំបានប្រាប់កូនខ្ញុំទាំងពីរនេះ ថាតើបើអ្នកណាសួរក៏ដោយ សូមកូនកុំឆ្លើយប្រាប់គេថា ឪពុកជាទាហាន ហើយឪពុកនៅសហរដ្ឋអាមេរិកឲ្យសោះ។ កូនត្រូវចាំ ចាំឲ្យជាប់កុំភ្លេច បើសិនជាកូនប្រាប់គេនោះគេនឹងសម្លាប់កូន ហើយសម្លាប់ម៉ែហើយ។ ដូច្នេះ កូនខ្ញុំទាំងពីរ គឺមិនដែលប្រាប់អ្នកណា។ សូម្បីតែយោធាខ្មែរក្រហមមកវ៉ៃកូនខ្ញុំ រាល់ថ្ងៃសួរអំពីឪពុក សួរអំពីរឿងខ្ញុំក៏ដោយ កូនខ្ញុំឆ្លើយថា មិនដឹង។ ហើយខ្ញុំប្រាប់កូនខ្ញុំទៀតថា បើគេនៅតែវ៉ៃកូន ហើយសួរថាពីឪពុកកូនធ្វើអ្វី? សូមកូនឆ្លើយប្រាប់គេថា ឪពុកខ្ញុំធ្វើជាគ្រូបង្រៀនដូចម្ដាយខ្ញុំដែរ ហើយបែកគ្នាមិនដឹងទៅណាទេ។ កូនថាតែប៉ុណ្ណឹងបានហើយ។ ដូច្នេះកូនចាំពាក្យខ្ញុំជាប់ គឺកូនចាំពាក្យសម្ដីខ្ញុំជាប់ មិនដែលប្រាប់ទេ។ ដូច្នេះ ហើយបានជាខ្ញុំមានរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនេះ។

[១០:២៤:០២]

តែអភ័ព្វ ចំណែកដែលអ្នកស្រីដែលគេវ៉ៃនោះ ពួកយោធាខ្មែរក្រហមទៅសាកសួរកូនទាំងពីរនោះដែលនៅក្បែរខ្ទមខ្ញុំនោះ កូនទាំងពីរនោះភិតភ័យខ្លាំងណាស់។ វាក៏ឆ្លើយប្រាប់ទៅយោធាខ្មែរក្រហមនោះថា ពីមុន ពីថ្ងៃមុនម្ដាយមានល្ពៅមួយ។ យោធាខ្មែរក្រហមដើររកល្ពៅមិនឃើញ។ កាប់មែកឈើប្អូនកង់គ្នាប្អូននាក់ទៅវ៉ៃស្ត្រីកំពុងតែវ៉ៃថ្មនៅក្បែរខ្ញុំ។ យើងទាំងអស់គ្នាស្រឡាំងកាំងចាប់ស្ត្រីនោះចងដៃ ហើយលុតជង្គង់ វ៉ៃទាល់តែប្រេះ ប្រេះឡើងដូចទំអាកោ ប្រេះសាច់ វ៉ៃនាង។ ម្នាក់ស្រីនោះថា ខ្ញុំអត់លួចគេទេ តែយោធាខ្មែរក្រហមវ៉ៃ វ៉ៃហើយ វ៉ៃទៀត រាប់ម្ភៃ ជាងម្ភៃរំពាត់យ៉ាងខ្លាំង ហើយយកជើងធាក់ទ្រូងទៀត

យោធាខ្មែរក្រហម -- ស្ត្រីខ្មែរក្រហមម្នាក់យកជើងធាក់ទ្រូង ហើយខ្លួន-- ហើយស្ត្រីខ្មែរក្រហមនោះមានផ្ទៃពោះ ហើយជើងធាក់ទ្រូងអ្នកស្រីនោះឲ្យដួលផ្ងារទៅទៀត ថា -- ជៀលជេរស្ដីយ៉ាងខ្លាំងថាជាៗពួកចក្រសក្តិភូមិ ជាពួកចក្រពត្តិ ជាពួក -- ហើយវ៉ៃធ្វើបាបស្ត្រីនោះមិនមែនទៅវ៉ៃកូននៅចំពោះមុខខ្ញុំទេ វ៉ៃម្ដាយនៅចំពោះមុខខ្ញុំ នៅកន្លែងផ្ទើថ្ម។ មិនតែប៉ុណ្ណោះ យោធាខ្មែរក្រហមបានប្រាប់ពួកខ្ញុំអ្នកវ៉ៃថ្មដូចគ្នាថា ទៅវ៉ៃទៅៗវ៉ៃខ្លាំង នេះខ្លាំងៗទៅវ៉ៃ នាំគ្នាទៅវ៉ៃខ្លាំង។ ខូចដើរលួចៗគេ ដើរលួចរបស់របរគេយកមកហូប។ តើពួកខ្ញុំអ្នកវ៉ៃថ្មទាំងអស់អត់ទៅ ដាក់មុខចុះ សុខចិត្តស្លាប់។ ថាបើយោធាខ្មែរក្រហមសម្លាប់ ខ្ញុំសុខចិត្តស្លាប់ តែខ្ញុំមិនអាចលើដៃទៅវ៉ៃស្ត្រីនោះទៀតទេ ព្រោះស្ត្រីនោះសន្លប់បាត់ស្មារតីទៅហើយ។ នេះគឺជាទារុណកម្មយ៉ាងខ្លាំងក្លាដែលយោធាខ្មែរក្រហមបានធ្វើមកលើប្រជាជនអ្នក១៧មេសា។

[១០:២៦:១៣]

**ស៖** សូមអរគុណលោកស្រី នេះជាសំណួរចុងក្រោយ។ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិចំពោះប្រជាជន១៧មេសា និងជោគវាសនារបស់ពួកគាត់នៅជិត នៅពេលដែលវៀតណាជិតចូល គឺចុងឆ្នាំ៧៨ តាមអនុប្រធានរបស់--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោកមេ -- លោកសហព្រះរាជអាជ្ញាសួរសំណួរឡើងវិញ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា តាំងសំណួរចុងក្រោយរបស់លោកនេះ សួរម្តងទៀត ពីព្រោះសំណួររបស់លោកមិនមានការបកប្រែជាភាសាផ្សេងទេ ព្រោះអ្នកបកប្រែស្តាប់មិនបាន!

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

**ស៖** ខ្ញុំនិយាយអំពីជោគវាសនារបស់ប្រជាជន១៧មេសា និងហេតុការណ៍មួយដ៏សំខាន់ដែលលោកស្រីបានឆ្លើយ បានលើកឡើងនៅក្នុងឯកសាររបស់លោកស្រី។ តើលោកស្រីអាចពន្យល់បានទេថា នៅពេលវៀតណាមជិតចូលមក នៅចុងឆ្នាំ១៩៧៨នោះ តើប្រជាជន -- តើមេៗភូមិរបស់លោកស្រីនោះពន្យល់ -- បានណែនាំឲ្យលោកស្រីនិងប្រជាជន១៧មេសា នោះជីកអ្វី? ខ្ញុំមើលទៅដូចថាមានជីកអីមួយ តែខ្ញុំមិនយល់ ថាតើជីកអ្វីដែរ?

[១០:២៧:៤១]

**លោកស្រី បេ សុផានី៖**

**ឆ៖** ចាស ជម្រាបលោកចាស នៅពេលចុងក្រោយដែលថាមានពួកវៀតណាមចូលមកនេះ គឺយោធាខ្មែរក្រហមបង្ខំឲ្យយើងអ្នក១៧មេសា ពីព្រោះចុងក្រោយនេះ គឺពួកយោធាខ្មែរក្រហមបានបញ្ជូនយើងមកដាក់ភូមិនៅភូមិមួយដែលជាភូមិចុងក្រោយបំផុត ហើយគេដាក់ឈ្មោះថា ភូមិអ្នក១៧មេសា។ យោធាខ្មែរក្រហមបានបង្ខំប្រជាជន១៧មេសា ទាំងអស់ឲ្យជីករណ្ដៅរៀងៗខ្លួនក្នុងមួយគ្រួសារ ជីករណ្ដៅបណ្ដោយពីរម៉ែត្រ ទទឹង -- អ្នកណាមានគ្រួសារច្រើនគឺជីករណ្ដៅជ្រៅ ហើយធំ ចំណែកខ្ញុំដែលខ្ញុំមានតែម្នាក់ឯងគត់ ខ្ញុំបានសួរទៅយោធាខ្មែរក្រហមថា ហេតុអ្វីក៏បានឲ្យខ្ញុំជីករណ្ដៅយ៉ាងដូច្នេះ? យោធាខ្មែរក្រហមបានឆ្លើយថា ជីកដាក់ជី។ ខ្ញុំថាមានជីឯណានឹងដាក់ បើខ្ញុំតែម្នាក់ឯង។ រួចហើយគេបញ្ជូនឲ្យទៅសមរភូមិមុខទៀត។ អ្នកឯងត្រូវតែជីក មួយគ្រួសារត្រូវមានមួយរណ្ដៅ។ ចំពោះរូបខ្ញុំគឺវា គឺយោធាខ្មែរក្រហមបានឲ្យជីកបណ្ដោយ២ម៉ែត្រ ទទឹងកន្លះម៉ែត្រ ជម្រៅកន្លះម៉ែត្រ។ តែជីកមិនទាន់ចប់ ជីកមិនបានចប់ មិនទាន់ហើយទេ ក៏ព្រឹត្តិការណ៍វៀតណាមចូលមកចាស។ ខ្ញុំសូមជម្រាបលោកចាស។

[១០:២៩:១៤]

**លោក វាំងសង់ វ៉ាយ៍ ដេស្មាឯល៖**

សូមអរគុណលោកស្រីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ ខ្ញុំអស់សំណួរហើយ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ!

យ៉ាងម៉េចទៅ? មានបញ្ហាអីទៀត?

[១០:២៩:៤៧]

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

លោកប្រធាន ដោយសារលោកស្រី បេ បានធ្វើដំណើរឆ្ងាយណាស់ពីសហរដ្ឋអាមេរិកមក។ ហើយខ្ញុំសូមលោកប្រធានផ្ដល់ពេលវេលាឲ្យគាត់៥នាទីទៀត ដើម្បីខ្ញុំចោទសំណួរសួរអំពីការឈឺចាប់របស់គាត់។ សូមអស់។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣១:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ! ៥នាទី ណា៎ះ!

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន។

**សួរបន្តដោយលោកស្រី នូស៊ីន សាកាវ៉ាទី៖**

**ស៖** លោកស្រី សុផានី ខ្ញុំសូមសួរលោក លោកបានរៀបរាប់ថា លោកមានរោគសញ្ញាដូចជាសុបិនអាក្រក់។ ថាតើរោគសញ្ញាទាំងអស់ហ្នឹងមានការផ្លាស់ប្តូរទេនៅពេលលោកស្រីចាកចេញពីកម្ពុជាទៅរស់នៅឯសហរដ្ឋអាមេរិកនោះ?

**លោកស្រី បេ សុផានី៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកស្រីថា ជំងឺនេះ គឺអន្ទោលតាមប្រាណខ្ញុំជានិច្ចៗរហូត ទោះបីខ្ញុំមកដល់សហរដ្ឋអាមេរិកនេះហើយក៏ដោយ ក៏ស្រមោលអតីតកាលនៅតែអន្ទោលតាមប្រាណខ្ញុំជានិច្ច។ ញ៉ាំញីអារម្មណ៍ខ្ញុំ។ ព្រោះអ្វី? ព្រោះនៅសហរដ្ឋអាមេរិកដែលខ្ញុំមកដល់ ខ្ញុំឃើញ ក្រឡេកឃើញកូនគេដែលបានទទួលការសិក្សាខ្ពង់ខ្ពស់។ ខ្ញុំនឹកទៅដល់កូនខ្ញុំ ស្រណោះកូនខ្ញុំ ដែលគ្មានវាសនានឹងគេ ត្រូវពួកខ្មែរក្រហមធ្វើបាបសម្លាប់អស់រលីង។ រូបភាពកូនខ្ញុំទាំងប៉ុន្មាន គឺបានថតជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំ។ ខ្ញុំនៅចាំជានិច្ច មុខមាត់ ពាក្យសម្តីកូនខ្ញុំទាំងប៉ុន្មាន គឺខ្ញុំនៅចាំទាំងអស់។

ពេលខ្ញុំនឹករឿងហ្នឹងឡើង ខ្ញុំឈឺចាប់ ខ្ញុំណែនទ្រូង ខ្ញុំអួល-ក ទឹកភ្នែកខ្ញុំនៅតែស្រក់ នៅតែស្រក់នៅឡើយពេលណាដែលខ្ញុំនឹកឃើញរឿងអស់ទាំងនេះ នឹកឃើញពីរឿងកូនខ្ញុំដែលត្រូវសម្លាប់យ៉ាងវេទនាបំផុតដោយសារស្នាដៃខ្មែរក្រហម។

[១០:៣៣:៣០]

**ស៖** តើលោកស្រីមានកូនទៀតទេ ក្រោយពីរបបនោះដួលរលំទៅ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំគ្មានកូនទេក្រោយរបបនោះដួលរលំទៅ ព្រោះថា សុខភាពខ្ញុំបានប្រែប្រួលដូចខ្ញុំជម្រាបហើយ។ កាលខ្ញុំរស់នៅក្នុងរបបខ្មែរក្រហម ខ្ញុំជាស្ត្រី ប៉ុន្តែគ្មានរដូវទេ។ ក្នុងរយៈជិត៤ឆ្នាំនេះ នៅក្នុងរបបខ្មែរក្រហម ខ្ញុំហាក់បីដូចជាមនុស្សប្រុស។ ដូច្នេះសុខភាពខ្ញុំប្រែប្រួលបានជា

ខ្ញុំមិនអាចនឹងមានកូនអ្វីទៀតឡើយ។

**ស៖** លោកស្រី សុផានី លោកស្រីត្រូវការអ្នកទីប្រឹក្សាខាងផ្នែកសុខភាពក៏ដូចជាជនរងគ្រោះរបបខ្មែរក្រហមដទៃទៀតដែរ។ ថាតើក្នុងចំណោមជនរងគ្រោះទាំងអស់ដែលរស់នៅសហរដ្ឋអាមេរិក លោកស្រីធ្លាប់បានព្យាបាលជនរងគ្រោះនៅក្នុងសហរដ្ឋអាមេរិកដោយសាររបបនេះដែរទេ?

**ឆ៖** ជាការពិតណាស់លោក ក្នុងមុខងារដែលខ្ញុំបំពេញរាល់ថ្ងៃនេះ ជាអ្នកជួយប្រជាជន ជួយផ្តល់ឱវាទ ជួយឲ្យយោបល់ ជួយឲ្យឱវាទ ជួយសម្រាលទុក្ខទោសរបស់ប្រជាជន ជនភៀសខ្លួនខ្មែរ។ ជាពិសេសគឺខ្មែរ កម្មវិធីខ្មែរ ជាជនភៀសខ្លួនដែលបានពាំនាំយកមកជាមួយនូវទុក្ខសោកវេទនាពីរបបខ្មែរក្រហម ប៉ុល ពត។ គ្រួសារនីមួយៗគឺមានការបាត់បង់ អ្នកខ្លះបាត់បង់កូន អ្នកខ្លះបាត់បង់ប្តី អ្នកខ្លះបាត់បង់ប្រពន្ធ គឺគ្រួសារនីមួយៗគឺមានបញ្ហា មានការបាត់បង់គ្រប់ៗគ្រួសារ។ ដូច្នេះខ្ញុំជួយប្រជាជនខ្មែរពិសេស គឺបងប្អូនខ្មែរនៅសហរដ្ឋអាមេរិកដែលមានជីវភាពទន់ខ្សោយ មានបៀវត្សតិចតួចស្តួចស្តើង បូករួមនឹងជំងឺផ្លូវចិត្តដែលបានពាំយកមកជាមួយ រួមផ្សំនឹងរឿងថ្មីៗដែលកើតមានឡើងក្នុងជីវិតរបស់គាត់នៅក្នុងសហរដ្ឋអាមេរិកទៀត។ ដូច្នេះជំងឺរបស់គាត់កាន់តែធ្ងន់ធ្ងរខ្លាំងឡើងៗ។

[១០:៣៥:៥៧]

ខ្ញុំជួយប្រជាជនខ្មែរ។ ខ្ញុំស្តាប់គាត់ គាត់រាយរាប់ប្រាប់ខ្ញុំពីរឿងទុក្ខសោករបស់គាត់។ ដូច្នេះទុក្ខសោករបស់បងប្អូនខ្មែរយើង ជនភៀសខ្លួនខ្មែរយើងដែលនៅសហរដ្ឋអាមេរិក ពិសេសគឺអ្នកដែលវ័យចាស់ៗ ចំណាស់ៗ ដែលធ្លាប់ឆ្លងកាត់នូវរបប ប៉ុល ពត – របបខ្មែរក្រហម គឺមានទុក្ខសោកដូចជារូបខ្ញុំដែរ។ គាត់បានជម្រាបខ្ញុំអំពីរឿងដេកមមើមមាយ ស្រែកយល់សប្តិអាក្រក់ ខ្ញុំជឿគាត់ៗ ពីព្រោះខ្លួនខ្ញុំផ្ទាល់ៗនៅមានការដេកមមើមមាយនៅពេលយប់។ ដេកស្រែៗ ហើយមានយល់សប្តិអាក្រក់ មិនដែលយល់សប្តិល្អ មិនដែលយល់សប្តិឃើញជីវិតរុងរឿងថ្កុំថ្កើងនៅសហរដ្ឋអាមេរិកទេ គឺយល់សប្តិតែរឿងខ្មែរក្រហមដេញចាប់ ដេញកាប់ ដេញវ៉ៃ ហើយស្រែករកគេជួយ។

**ស៖** ហើយថាតើការឈឺចាប់ហ្នឹង ថាតើវាប៉ះពាល់ទៅដល់ការរស់នៅរបស់ពួកគាត់យ៉ាងដូចម្តេចដែរនៅសហរដ្ឋអាមេរិកហ្នឹង? ថាគាត់អាចនឹងសម្របសម្រួលការរស់នៅហ្នឹងបានដោយរបៀបណាដែរ?

[១០:៣៧:២០]

**ឆ៖** ចំពោះបងប្អូនប្រជាជនខ្មែរ ឬក៏ចំពោះខ្ញុំផ្ទាល់? ចំពោះខ្ញុំផ្ទាល់ ឬក៏ចំពោះប្រជាជនខ្មែរ? ចាសសូមសួរ។

**ស៖** ទាំងលោកស្រី ទាំងអ្នកដទៃទៀត។

**ឆ៖** ពីព្រោះអ្វី? ពីព្រោះថាគាត់មានជំងឺផ្លូវចិត្តនេះរ៉ាំរ៉ៃជាយូរឆ្នាំមកហើយ។ ដូចលោកប្រធាន បងប្អូនរួមខ្មែរយើងទាំងអស់ អស់លោកទាំងអស់ជ្រាបហើយ របបខ្មែរក្រហម ប៉ុល ពត បានកន្លងទៅ ៣៨ឆ្នាំកន្លងមកហើយ ក៏ប៉ុន្តែជំងឺផ្លូវចិត្ត ជំងឺរ៉ាំរ៉ៃនៅតែមានរហូតចំពោះបងប្អូនជនភៀសខ្លួនខ្មែរ ដែល ធ្លាប់រស់នៅក្នុងរបប ប៉ុល ពត ទាំងរូបគេ ទាំងរូបខ្ញុំ។

**ស៖** សូមអរគុណលោកស្រី សុផានី។ ដោយសារលោកស្រីរស់នៅសហរដ្ឋអាមេរិក ហេតុអ្វី បានជាលោកស្រីដាក់ពាក្យជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះ?

[១០:៣៨:៤០]

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ការឈឺចាប់របស់ខ្ញុំនៅជាប់នៅក្នុងខ្លួនខ្ញុំ ទឹកភ្នែកខ្ញុំនៅស្រក់។ ដូច្នេះ ខ្ញុំដាក់ពាក្យប្ដឹងផ្នែករដ្ឋប្បវេណី ដើម្បីនឹងចង់បាននូវយុត្តិធម៌មួយដ៏ត្រឹមត្រូវ ដ៏ពិតប្រាកដឲ្យកូនខ្ញុំ ឲ្យ ឪពុកម្ដាយ ឲ្យគ្រួសារខ្ញុំដែលត្រូវខ្មែរក្រហមសម្លាប់អស់ទាំងពូជ គ្មានសល់អ្វី គ្មានសេសសល់អ្វីនោះ។ កាលបើខ្ញុំពុំបានឃើញមិនឃើញនូវពន្លឺយុត្តិធម៌នោះ ខ្ញុំស្លាប់ទៅខ្ញុំបិទភ្នែកមិនជិតទេ ព្រោះខ្ញុំមិនបានបំពេញ ភារកិច្ចជាមាតា ជាកូនដែលត្រូវរកយុត្តិធម៌ឲ្យឪពុកម្ដាយ ឲ្យកូនជាទីស្នេហារបស់ខ្ញុំ។ ខ្ញុំសូមយុត្តិធម៌ មួយដ៏ពិតប្រាកដ។ ដូច្នេះហើយថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំមានវាសនាខ្ពស់បានមកជួបលោកប្រធាន ជួបអស់ លោកទាំងអស់ក្នុងអង្គប្រជុំ ដើម្បីយុត្តិធម៌ដែលជាថ្ងៃដែលខ្ញុំទន្ទឹងជាយូរថ្ងៃឆ្នាំខែណាស់មកហើយ ដែល បានមកឃើញក្នុងថ្ងៃនេះ។ ថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំចង់បាន។ សូមជម្រាបលោកប្រធាន និងអស់លោក ទាំងអស់សូមមេត្តាជ្រាប។

**លោកស្រី ទូស៊ីន សាការ៉ាទី៖**

សូមអរគុណលោកស្រី សុផានី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១០:៤០:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រី រដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់ដើមបណ្ដឹងរដ្ឋ- ប្បវេណីរូបនេះនៅក្នុងអំឡុងពេលសម្រាក ហើយឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះ

វិញនៅវេលាម៉ោងដប់មួយ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០ នាទី ដល់ម៉ោង ១១:០០ នាទី)*

[១១:០០:៤០]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពក្រុមប្រឹក្សា សូមគោរពលោកប្រធាន។ សូមជម្រាបសួរលោកស្រី បេ សុផានី។ ខ្ញុំឈ្មោះ សុន អរុណ មេធាវីការពារលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកស្រីនៅព្រឹកនេះ ដោយសារពេលវេលា វាតិចពេក។ ម្ល៉ោះហើយ ខ្ញុំបង្រួមខ្លីៗដើម្បីសួរ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** មុន នៅថ្ងៃ សូមទោស។ នៅថ្ងៃ១៧ មេសា ១៩៧៥ ពេលនុំងអ្នកស្រីនៅកន្លែងណា?

**លោកស្រី បេ សុផានី៖**

**ឆ៖** ខ្ញុំសូមជម្រាបលោក នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គឺខ្ញុំនៅភ្នំពេញនៅជិតចំការមន ជិតផ្ទះលោក អោក សំអាង។

**ស៖** អរគុណ។ ពេលនុំង ថ្ងៃ១៧ មេសាហ្នឹង យោធាខ្មែរក្រហមបានចូលដល់ផ្ទះលោកស្រី។ នៅវេលាម៉ោងប៉ុន្មានដែលចូលដល់ផ្ទះលោកស្រីហ្នឹង?

[១១:០២:៤៤]

**ឆ៖** ខ្ញុំសូមជម្រាបថា នៅថ្ងៃ១៧ មេសា ហ្នឹង។ យោធាមិនទាន់បានចូលមកក្នុងផ្ទះខ្ញុំនៅឡើយទេ។ ប៉ុន្តែយោធាខ្មែរក្រហមបាញ់កាំភ្លើងឡើងលើ បណ្តេញប្រជាជននៅជិតៗផ្ទះហ្នឹងឲ្យចេញពីផ្ទះយ៉ាងឆាប់រហ័សបំផុត គឺគេបាញ់កាំភ្លើងលើថា "ចេញភ្លាមៗក្នុងរយៈបីថ្ងៃ! អាមេរិកមកទម្លាក់គ្រាប់បែកនៅលើទីក្រុងភ្នំពេញនេះហើយ"។ ខ្ញុំឮដូច្នេះខ្ញុំភ័យណាស់ ខ្ញុំស្លន់ស្លោ ខ្ញុំមិនអាចនៅផ្ទះបានទេ ហើយម្យ៉ាងទៀត ខ្ញុំបានជម្រាបថា ខ្ញុំមិនអាចនៅបង្អង់យូរទុកឲ្យយោធាខ្មែរក្រហមចូលផ្ទះខ្ញុំ ហើយឃើញរូបថតខ្ញុំដែលខ្ញុំព្យួរនៅជញ្ជាំង សុទ្ធសឹងតែរូបថតប្តីខ្ញុំជានាយទាហានពាក់ខោអាវ ហើយនិងរូបថតបងប្អូនខ្ញុំទាំងអស់ គឺគ្រួសារលោកសេនាប្រមុខលន់ នល់។

**ស៖** អរគុណ។ ពេលនោះយោធាខ្មែរក្រហមមិនបានមកដេញគ្រួសារលោកស្រីចេញពីផ្ទះផ្ទាល់ទេ ដេញអ្នកជិតខាងផ្ទះលោកស្រី។ អ៊ីចឹងទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា គេមកដេញហើយ គេបម្រុងមកដល់ផ្ទះខ្ញុំទៀតហើយ ព្រោះគេដេញៗ គេមកគ្រប់ៗផ្ទះចេញមកដល់ផ្ទះខ្ញុំហើយ។ ដូច្នេះខ្ញុំត្រូវតែភ័យ ហើយខ្ញុំភ័យ ហើយខ្ញុំត្រូវតែចេញយ៉ាងឆាប់រហ័សបំផុត ចេញជាបន្ទាន់។ ទោះបីគេមិនចូលក្នុងផ្ទះខ្ញុំក៏ដោយ ក៏ករណីនេះ ជាករណីគេបណ្តេញទាំងគេ ទាំងខ្ញុំ ឲ្យចេញពីផ្ទះភ្លាមៗ។

**ស៖** បើតាមចម្លើយលោកស្រីឆ្លើយអំមិញថា គេមិនបានដេញលោកស្រីនិងគ្រួសារទេ គេដេញផ្ទះអ្នកជិតខាង ប៉ុន្តែដោយសារលោកស្រីយល់ថាចៀសមិនរួច លោកស្រីនឹងចេញមុនគេដេញ។ ខ្ញុំនិយាយហ្នឹងត្រូវឬខុស?

[១១:០៤:៤៤]

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ខ្មែរក្រហមបណ្តេញគ្រប់ៗផ្ទះទាំងអស់ ហើយមកដល់ជិតផ្ទះខ្ញុំហើយៗ គេទាំងអស់គ្នា គេចេញពីផ្ទះអស់ហើយ។ ដូច្នេះ ខ្ញុំត្រូវតែចេញពីផ្ទះ ខ្ញុំដឹងថាច្បាស់ជាខ្មែរក្រហមមកដល់ផ្ទះខ្ញុំក្នុងពេលភ្លាមៗនេះហើយ។ ដូច្នេះខ្ញុំត្រូវតែចេញ។

**ស៖** ខ្ញុំសូមបញ្ជាក់បន្ថែមថា ពេលគេដេញមកដល់ផ្ទះលោកស្រីហ្នឹង សល់ប្រហែលប៉ុន្មានពីផ្ទះលោកស្រី ដែលផ្ទះគេដែលត្រូវបានដេញនោះ? ហើយពីផ្ទះហ្នឹងហើយមកផ្ទះលោកស្រីនៅសល់ផ្ទះប៉ុន្មាន ឬចម្ងាយប៉ុន្មាន?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ឈប់ៗ កុំអាលទាន់ឆ្លើយតប!

បាទ រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនលោកស្រី!

[១១:០៥:៤០]

**លោកស្រី បេ សុផានី៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកថាប្រហែលមួយផ្ទះទេ។ តែមួយផ្ទះទេនឹងមកដល់ផ្ទះខ្ញុំហើយ។ បានជាខ្ញុំភ័យខ្លាំងណាស់ គ្មានបានយកអ្វីបាន គឺប្រញាប់ប្រញាល់បំផុត ឱបកូន ហើយយកកូនទាំងពីរចេញជាប្រញាប់ជាបន្ទាន់។ សូមជម្រាបលោក។

**សួរដោយលោក សុន អរុណ៖**

**ស៖** អរគុណ។ បើអ៊ីចឹងមានន័យថា លោកស្រីចេញពីភ្នំពេញដោយស្ម័គ្រចិត្ត មិនមែនដោយខ្មែរក្រហមដេញទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ខ្ញុំមិនស្ម័គ្រចេញ ស្ម័គ្រចិត្តចេញពីផ្ទះខ្ញុំទេ។ តើអ្នកណាមួយដែលស្ម័គ្រចេញពីផ្ទះរបស់ខ្លួន? ទាល់តែខ្មែរក្រហមយោធាខ្មែរក្រហមធ្វើរបៀបនេះ បាញ់កាំភ្លើងឡើងលើរហូត "ចេញៗៗជាបន្ទាន់! អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកក្នុងពេលឆាប់ៗនេះហើយ"។ សម្ដីនេះដែលជាសម្ដីបន្លាចប្រជាជនទាំងអស់ ទាំងគេទាំងខ្ញុំត្រូវតែចេញពីផ្ទះ ទោះបីមិនបានមកដល់ខ្ញុំថា ចេញពីផ្ទះ ហើយមកដល់ឡើងលើផ្ទះខ្ញុំឃើញរូបថតប្ដីខ្ញុំ រូបថតគ្រួសារខ្ញុំ ក៏ខ្ញុំត្រូវតែចេញដូចប្រជាជនដទៃដែរ បើពុំនោះទេខ្ញុំនឹងមានគ្រោះថ្នាក់។ កាលបើខ្មែរក្រហម យោធាខ្មែរក្រហមមិនចូលមកដល់ក្នុងផ្ទះរបស់ខ្ញុំ ឡើងលើផ្ទះរបស់ខ្ញុំ ហើយឃើញរូបថត ហើយខ្ញុំមិនទាន់ចេញ នោះខ្ញុំនឹងមានរឿងរ៉ាវហើយចាស។

[១១:០៧:០៩]

**ស៖** ខ្ញុំយល់ចំណុចចម្លើយរបស់លោកស្រី។ ខ្ញុំសូមសួរបន្ត។ ពេលដែលខ្មែរក្រហមមកដល់ជិតផ្ទះលោកស្រីនៅសល់មួយផ្ទះទៀតទេ។ លោកស្រីឃើញសភាពពេលនុំង ទី១គឺសភាពខ្មែរក្រហមមកដេញផ្ទះជិតលោកស្រីហ្នឹងមានការគំរាមកំហែង ឬក៏ដេញធម្មតា សម្រួលតាមធម្មតា ឬក៏មានការគំរាមកំហែងយ៉ាងខ្លាំងក្លា?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកស្រីមេធាវី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាការសួរសំណួរបែបនេះ វាជាការសួរជាន់គ្នាដដែលៗ គឺហាក់ដូចជាមេធាវីការពារក្តីហ្នឹង គាត់អង្គុន់ ដូចថាជម្រេញទៅលើដើមបណ្តឹងរដ្ឋប្បវេណី។

[១១:០៨:១៣]

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយ។ ខ្ញុំជាមេធាវីការពារ មិនទាន់បានសួរសំណួរហ្នឹងទេ។ ហើយមេធាវីទាំងពីរក្រុមគាត់មិនទាន់បានសួរចម្លើយហ្នឹងដែរ។ នេះជាសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឬក៏របស់ព្រះរាជអាជ្ញា? នេះជាសិទ្ធិរបស់មេធាវីការពារអាចចិញ្ច្រាំ អាចកាត់កង់ៗយ៉ាងម៉េចជាសិទ្ធិរបស់មេធាវីសួរទៅកូនក្តី។ ឆ្លើយបានៗ បើឆ្លើយមិនបាន តុលាការវិនិច្ឆ័យទៅតាមហ្នឹង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរដែលសួរដោយមេធាវីការពារនូវសណ្ហួរចុងក្រោយអម្បាញ់មិញនេះ។

ទំនងជាគាត់ភ្លេចនូវសំណួរហើយ។ លោកមេធាវីការពារក្តី លោកអាចតាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត។

[១១:០៩:៤៩]

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំដើម្បីឲ្យចំណេញពេល ពេលវេលាខ្ញុំមានតែ១០នាទី ខ្ញុំសួរចម្លើយទៅមុខទៀត។ ពេលដែលលោកស្រីបានឃើញខ្មែរក្រហមចូលមកដល់ជិតផ្ទះលោកស្រី តើលោកស្រីមានឃើញឯកសណ្ឋាន និងសភាពការណ៍ឃោរឃៅ ឬមិនឃោរឃៅដោយស្រួលបួល ដោយស្លូតបូតរបស់កងទ័ពខ្មែរក្រហមទេ? ឬយ៉ាងម៉េចពេលនុំង បរិយាកាសយ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា មិនស្លូតបូតទេលោក។ មុខកាច មុខមាំ សម្លក់សម្លឹង កំញើញគំរាមឲ្យចេញពីផ្ទះ បាញ់កាំភ្លើងឡើងលើ ហើយស្រែកខ្លាំងៗ “ចេញពីផ្ទះភ្លាមៗ! អាមេរិកាំងនឹងមក

ទម្លាក់គ្រាប់បែកឥឡូវហើយ។ ចេញភ្លាមៗជាប្រញាប់ក្នុងរយៈពេល៣ថ្ងៃ!"។ ដូច្នេះមិនមែនជាសំឡេងស្លូតបូត សម្តីសំដៅស្លូតបូតទេ គឺកាចសាហាវៗណាស់។ ហើយឯកសណ្ឋានខ្មៅៗឃោធាខ្មែរក្រហម។

[១១:១១:០៣]

**ស៖** អរគុណ។ លោកស្រីមិនបានទទួលការគេដេញចេញពីផ្ទះទេ ប៉ុន្តែលោកស្រីឆ្លើយជម្រាបតុលាការហាក់ដូចជាច្បាស់លាស់ ខ្មែរក្រហមស្លៀកពាក់ បានឃើញបាញ់។ ពេលនោះ ពេលដែលគេមកជិតផ្ទះអ្នកជិតខាងនោះ លោកស្រីបានចេញទៅមើលខ្មែរក្រហមទេ ពេលនុ៎ងបានទៅស្តាប់ខ្មែរក្រហមទេ ផ្ទាល់ទេ ឬក៏យ៉ាងម៉េចបានជាលោកស្រីច្បាស់ដូចជាមកដេញលោកស្រីអ៊ីចឹងដែរ?

**ឆ៖** ច្បាស់ណាស់លោក ព្រោះផ្ទះនៅជិតគ្នាៗ។ ខ្ញុំឮទាំងអស់ សំឡេងដែលខ្មែរក្រហមស្រែកយ៉ាងសាហាវ ដេញប្រជាជន "ដេញវាឲ្យចេញពីផ្ទះ"។ គឺច្បាស់ណាស់ៗ មិនមែនជាសំឡេងស្លូតបូតទេ រួមផ្សំនឹងកាំភ្លើងទៀត បាញ់កាំភ្លើងឡើងលើជាប់ជានិច្ច ហើយគំរាមកំហែងឲ្យចេញពីផ្ទះយ៉ាងប្រញាប់។ នេះជារឿងពិត។

**ស៖** អរគុណ។ ពេលដែលលោកស្រីជម្លៀសខ្លួនចេញពីភ្នំពេញ លោកស្រីបានទៅដល់មួយកន្លែងនោះ លោកស្រីបានជម្រាបតុលាការថា ពេលនុ៎ងអស់អង្ករ អស់ម្ហូប ចំណីអាហារសព្វបែបយ៉ាង។ លោកស្រីមានសល់ចិញ្ចៀនមួយជាកេរពីបងថ្លៃអ៊ីចឹងទៅ ប៉ុន្តែបានចិញ្ចៀនហ្នឹងដូរយកអង្ករ ហើយយកអង្ករទៅដូរយកថ្នាំ បើបានខ្ញុំចាំអ៊ីចឹង។ ខ្ញុំចង់សួរថា ពេលដូរនោះ ដូរយកអង្កររហូតដល់ដូរយកថ្នាំហ្នឹងដូរជាមួយអ្នកណា? ហើយដូរនៅកន្លែងណា?

**ឆ៖** ខ្ញុំសូម--

[១១:១២:៥៥]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោកស្រី។ សូមអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ទូស៊ីន សាកាវ៉ាទី៖**

លោកប្រធាន មេធាវីការពារក្តីហាក់ដូចជាកំពុងធ្វើការសន្មតទៅលើអង្គហេតុដោយគាត់សន្មតថាទាក់ទងទៅនឹងការជម្លៀសរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺថាគាត់នៅសួរដដែលៗ ហើយបញ្ជាក់អំពីដើមបណ្តឹងរដ្ឋប្បវេណីមិនបាននិយាយអំពីការបាញ់កាំភ្លើង ឬក៏នេះទេ។ គឺថាគាត់មិនបានផ្តល់សក្ខីកម្មបែបនេះឡើយ មេធាវីការពារក្តីគាត់ធ្វើការសន្និដ្ឋានដោយខ្លួនគាត់ទៅលើអង្គហេតុទាំងអស់នេះ។

**លោក សុន អរុណ៖**

ខ្ញុំថាការចោទប្រកាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីខុសនឹងចំណុចដែលខ្ញុំសួរ។ ខ្ញុំសួរថាពេលដែលជម្លៀសខ្លួន អ្នកស្រី -- អានេះជាកម្មវត្ថុថ្មីមួយ។ អ្នកស្រីមានចិញ្ចៀនមួយ ចិញ្ចៀនគឺពេជ្រសល់ពីបងថ្លៃបានចែកឲ្យ ហើយយកទៅដូរពីរបីគន្លាក់ដើម្បីបានជាថ្នាំ។ ខ្ញុំសួរថាដូរនៅកន្លែងណា? ហើយដូរជាមួយអ្នកណា? ខុសស្រឡះពីដើមបណ្តឹងរដ្ឋប្បវេណីចោទ -- ដែលធ្វើការជំទាស់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

កុំអាលទាន់ឆ្លើយលោកស្រី ផានី។

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

លោកប្រធាន ខ្ញុំជំទាស់ទៅលើទម្រង់នៃការសួរ។ គាត់ចាប់ផ្តើមសួរដោយសន្មតទៅលើអង្គហេតុដែលលោកស្រី សុផានី បាននិយាយថា -- គាត់សន្មតថាលោកស្រី សុផានី ជម្លៀសដោយខ្លួនឯង ហើយគាត់បន្តសំណួរតទៅទៀត។ ដូច្នេះខ្ញុំជំទាស់ទៅលើទម្រង់ដែលជាការសួរ ដែលជាការសន្និដ្ឋាន ឬការសន្មតទៅលើអង្គហេតុបែបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ ដើមបណ្តឹងឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីការពារក្តី!

[១១:១៥:១៤]

**លោកស្រី បេ សុផានី៖**

**ផ៖** ខ្ញុំសូមជម្រាបលោកថា ដែលខ្ញុំដូរចិញ្ចៀននេះ គឺខ្ញុំដូរដោយលួចលាក់ជាមួយអ្នកភូមិ។ អ្នកភូមិដែលនៅភូមិនោះ គឺភូមិត្រើយស្លា។ ខ្ញុំសូមជម្រាបលោក។

**សួរដោយលោក សុន អរុណ៖**

**ស៖** បន្តសំណួរនេះ អ្នកភូមិនោះជាមនុស្សថ្មី ១៧មេសា ឬក៏ជាអ្នកចាស់នៅក្នុងភូមិហ្នឹងយូរមកហើយ?

**ប្រធានអង្គជំនុំ៖**

សូមកុំអាល់ទាន់ឆ្លើយតប!

**លោកស្រី បេ សុផានី៖**

**ឆ៖** ត្រង់កន្លែងនេះគឺខ្ញុំសូមបញ្ជាក់ថា អ្នកដែលនៅក្នុងភូមិនោះ គឺអ្នកស្រុក។ អ្នកស្រុកភូមិត្រើយស្លាហ្នឹង ដែលគេនៅក្នុងទីនោះហើយដែលគេធ្លាប់អាណិតខ្ញុំ ធ្លាប់ឲ្យបាយ ឲ្យសម្លកូនខ្ញុំ។ ដូច្នេះខ្ញុំដូរជាមួយអ្នកភូមិនោះដោយស្ងាត់ ដោយយោធាខ្មែរក្រហមមិនដឹង បើដឹងក៏មិនឲ្យធ្វើដែរ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ចំណុចខ្ញុំសួរ ចង់ដឹងថាអ្នកស្រីបានយកចិញ្ចៀនទៅដូរនុំងជាមួយនឹងមនុស្សរបៀបណា? មនុស្សចាស់នៅក្នុងភូមិហ្នឹងយូរមកហើយ ឬក៏អ្នកថ្មីទើបនឹងអញ្ជើញទៅដល់ដូចអ្នកស្រីអ៊ីចឹង?

**លោកស្រី បេ សុផានី៖**

**ឆ៖** មិនមែនអ្នកទៅដូចជារូបខ្ញុំទេគឺអ្នកប្រជាជនអ្នកនៅទីនោះ។ ប្រជាជនគេហៅថា អ្នកមូលដ្ឋាន អ្នកប្រជាជនចាស់។

[១១:១៧:០០]

**ស៖** បើអ្នកប្រជាជនចាស់ តើគេស្គាល់ថាអាហ្នឹងជារបស់មានតម្លៃទេ បានដូររបស់ឲ្យអង្ករឲ្យស្រូវឲ្យមកអ្នកស្រីបានអ៊ីចឹង?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា គេស្គាល់ណាស់ៗ ព្រោះអ្នកនោះមិនមែនជាអ្នកនោះដែលមិនស្គាល់ទីក្រុង ឬមិនស្គាល់អីទេ គឺជាមនុស្សគ្រាន់បើដែរ។ អ្នកភូមិ អ្នកនៅក្នុងភូមិនោះ គឺជាមនុស្សគ្រាន់បើដែរ គេស្គាល់ច្បាស់ គេស្គាល់ពេជ្រ គេស្គាល់មាស ច្បាស់ណាស់។ ជម្រាបលោក។

**ស៖** ខ្ញុំសូមបន្តសំណួរទៅមុខទៀត។ នៅពេលដែលវៀតណាម -- អ្នកស្រីបានជម្រាបតុលាការកាលពីព្រឹកមិញថា មុនពេលវៀតណាមចូលមកកម្ពុជា យៀកណាមឲ្យអ្នកស្រីជីករណ្តៅៗហ្នឹង គឺ២ម៉ែត្រ កន្លះម៉ែត្រ និងទទឹងកន្លះម៉ែត្រ។ លោកស្រីមានដឹងថា ហេតុអ្វីបានជាគេឲ្យជីករណ្តៅដូច្នេះទេ? គេមានប្រាប់ហេតុផលយ៉ាងម៉េចទេ បានគេឲ្យជីក?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា សំណួររបស់លោកច្រឡំហើយ ខ្ញុំមិនមែនថា វៀតណាមឲ្យខ្ញុំជីករណ្តៅទេ គឺខ្មែរក្រហមប្រធានភូមិ អនុប្រធានភូមិ គឺបង្ខំឲ្យប្រជាជនជីករណ្តៅតាមគ្រួសារនីមួយៗ។ សូមលោកជ្រាប។

[១១:១៨:៣៨]

**ស៖** ខ្ញុំបើសិន -- អំមិញខ្ញុំសួរខុស។ ខ្ញុំសូមសាឡើងវិញ សំណួររបស់ខ្ញុំថា ពេលដែលវៀត-

ណាមមុនចូលក្នុងដល់ផ្ទះលោកស្រី ខ្មែរក្រហមពេលហ្នឹងបានឲ្យអ្នកស្រី និងគ្រួសារជីករណ្ដៅ អាហ្នឹងសំណួររបស់ខ្ញុំ។ មានដឹងថា ហេតុអ្វី ហេតុអីទេបានជាគេឲ្យជីក? ហើយចំណុចរបស់ខ្ញុំអ៊ីចឹង។

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ខ្ញុំមានតែម្នាក់ឯងគត់។ អត់មានគ្រួសារអីទេ។ ខ្ញុំមានតែម្នាក់ឯងគត់ ព្រោះកូនស្លាប់អស់ហើយនៅតែម្នាក់ឯងគត់ នៅភូមិអ្នក១៧មេសា ហើយអ្នកដែលបញ្ជាឲ្យខ្ញុំជីករណ្ដៅហ្នឹង គឺយោធាខ្មែរក្រហម អនុប្រធានភូមិ គឺបង្ខំប្រជាជនឲ្យជីករណ្ដៅរៀងៗខ្លួនតាមគ្រួសារនីមួយៗ ដូចខ្ញុំបានជម្រាបហើយ ខ្ញុំមានតែម្នាក់ខ្ញុំគត់ ម្ដេចក៏ឲ្យខ្ញុំជីកដែរ? យោធាខ្មែរក្រហមឆ្លើយថា "ត្រូវតែជីក ជីកចាត់ទុកជាគ្រួសារមួយដែរ ថ្វីបើម្នាក់"។ បណ្ដោយ២ម៉ែត្រ ទទឹងកន្លះម៉ែត្រ ជម្រៅកន្លះម៉ែត្រ តែជីកមិនទាន់ឆ្លើយនៅឡើយទេ ជីកបានបន្តិចទេ ជម្រាបលោកចាស។

**ស៖** អរគុណ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ លោកស្រីបានជម្រាបតុលាការពីព្រឹកមិញថា សុខភាពលោកស្រីមិនល្អ ខួរក្បាលលោកស្រីវង្វេងវង្វាន់ លោកស្រីមានជំងឺខាងផ្លូវចិត្ត ជំងឺរ៉ាំរ៉ៃរហូតមកដល់ពេលនេះ។ បើលោកស្រីមានជំងឺដូច្នេះ តើលោកស្រីបង្កើតជាអង្គការ ឬសមាគមអីជួយស្ត្រីដទៃទៀតតាមរបៀបណា បើខួរក្បាលសុខភាពលោកស្រីមិនល្អសោះ?

[១១:២១:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោកស្រី ទូស៊ីន សាកាវ៉ាទី៖**

លោកប្រធាន លោក លោកស្រីចៅក្រម គឺថាលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីមិនដែលនិយាយថា ការចងចាំរបស់គាត់មិនល្អនោះទេ។ ដូច្នេះខ្ញុំស្នើសុំឲ្យមេធាវីការពារក្ដីបញ្ឈប់ការសន្និត ការសន្និដ្ឋានទៅលើអង្គហេតុបែបនេះតទៅទៀត។ សូមអរគុណ។

**លោក សុន អរុណ៖**

ក្នុងឋានៈខ្ញុំជាមេធាវីការពារ ខ្ញុំដេញសួរលម្អិតដល់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីចង់ដឹងថាតើអ្នកឆ្លើយត្រង់ពិតប្រាកដ ឬក៏បំប្លែង។ នេះជាចំណុចរបស់ខ្ញុំដែលសួរ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីការពារក្ដី គឺដូចជាមិនអនុវត្តតាមបទបញ្ជានៃការដំណើរការសវនាការទេ។ លោកស្រីមិនអាចងើបជំទាស់ពីរដងបានទេ។ លោកស្រីអាចជំទាស់បញ្ហាតែមួយតែម្ដងគត់។

[១១:២២:១៥]

បាទ សេចក្តីជំទាស់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺមានលក្ខណៈសមស្រប។ សំណួរនេះមិនពាក់ព័ន្ធនឹងអង្គហេតុដែលកើតឡើងដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការទេ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ។ ហើយលោកមេធាវីការពារក្តីលោក នួន ជា ដូចជាការប្រើប្រាស់ពេលវេលាច្រើនណាស់ហើយ។ បញ្ចប់នូវការសួរដេញដោលរបស់លោកត្រឹមនេះ យើងនឹងប្រគល់ពេលវេលាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ ហើយសូមជម្រាបសួរអ្នកស្រីផងដែរ។ ប៉ុន្តែក្នុងនាមលលោក ខៀវ សំផន យើងខ្ញុំអត់មានសំណួរសម្រាប់អ្នកស្រីទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អរគុណលោកស្រី បេ សុផានី ការស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា ព្យសនកម្ម និងសក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះលែងមានភាពចាំបាច់ទៀតហើយ។ សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា អំពីស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពារពិតក្នុងរឿងក្តីនេះ។ សូមពរលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ ហើយមានសេចក្តីសុខសេចក្តីចម្រើន។ ហើយលោកស្រីអាចវិលត្រឡប់ទៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី បេ សុផានី វិលត្រឡប់ទៅកាន់ទីកន្លែងដែលជាគោលដៅដែលគាត់ចង់ទៅ ឬទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ។

លោកស្រីអាចចាកចេញបានហើយ លោកស្រី បេ សុផានី!

*(ដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

[១១:២៦:៤៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**សៈ** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកឈ្មោះអី?

**លោក សឿន សុវណ្ណី៖**

**ឆៈ** បាទ ខ្ញុំឈ្មោះ សឿន សុវណ្ណី។

**សៈ** បាទ អរគុណលោកសុវណ្ណី។ សុវណ្ណី ឬក៏វណ្ណី? សុវណ្ណីអីចឹងហ្អេ? លោកសុវណ្ណី រង់ចាំបន្តិច ពេលដែលលោកស្តាប់សំណួររួចលោកបង្អង់បន្តិចដើម្បីឲ្យអ្នកបកប្រែបកប្រែភាសាសំណួរចំពោះលោកឲ្យបានត្រឹមត្រូវឲ្យបានពេញលេញ ហើយរហូតរង់ចាំ -- លោករង់ចាំរហូតដល់ក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យភ្លើងសញ្ញាក្រហមនៅទីនេះ ឬក៏នៅខាងក្រោមប៊ូតុង។ លោកមើលឃើញសឹមលោកឆ្លើយទើបសំឡេងរបស់លោកចូលក្នុងប្រព័ន្ធចែកចាយសំឡេងសម្រាប់ដល់ភាគីពាក់ព័ន្ធ និងសាធារណជនព្រមទាំងអង្គបកប្រែភាសាដើម្បីបកប្រែភាសារបស់លោកទៅជាបីភាសាផង។

តើលោកមានអាយុប៉ុន្មានឆ្នាំ?

[១១:២៧:៥៤]

**ឆៈ** ៥៧ ឆ្នាំ។

**សៈ** បាទ អរគុណលោកសុវណ្ណី។ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆៈ** ខ្ញុំមានទីកំណើតនៅក្រោយក្បាលមាន់ចែ ផ្សារដើមគរ ក្រុងភ្នំពេញ។

**សៈ** អរគុណ។ ចុះទីកន្លែងរស់នៅបច្ចុប្បន្នរបស់លោកតើលោករស់នៅកន្លែងណា?

**ឆៈ** បាទខ្ញុំនៅខេត្តបាត់ដំបង នៅភូមិបឹងវែង ឃុំរាំងឫស្សី ស្រុកសង្កែ ខេត្តបាត់ដំបង។

**សៈ** បាទ អរគុណហើយលោកប្រកបរបររកស៊ីធ្វើអ្វី?

**ឆៈ** បាទ ខ្ញុំជាអ្នកកសិករធ្វើស្រែចម្ការ។

**សៈ** បាទ អរគុណ ហើយឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆៈ** បាទ ឪរបស់ខ្ញុំឈ្មោះ ម៉ក់ ចេន ម្តាយឈ្មោះ គឹម លាង។

**សៈ** បាទ អរគុណ។ ហើយប្រពន្ធរបស់លោកគាត់ឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆៈ** ប្រពន្ធខ្ញុំឈ្មោះ សុង សុផៃ។ មានកូនតែមួយ មានកូនម្នាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក សុវណ្ណី។ ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ

អង្គជំនុំជម្រះផ្តល់ឱកាសឲ្យលោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការ អំពីស្ថានភាពទុក្ខសោក វេទនា ស្ថានភាពព្យសនកម្ម និងផលប៉ះពាល់ទាំងឡាយដែលបានកើតមានឡើងចំពោះលោក ជាអាទិ៍ ការខូចខាតផ្លូវចិត្ត ផ្លូវកាយ និងសម្ភារៈ ហើយជាព្យសនកម្មផ្ទាល់ខ្លួនដែលបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ន ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកនៅចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

សូមអញ្ជើញ!

[១១:៣០:៤៩]

**លោក សឿន សុវណ្ណី៖**

បាទ ពេលដែលក្នុងឆ្នាំ៧៥នោះ គឺក៏១៧ មេសា នោះក៏ខ្ញុំបានជម្លៀសចេញតាមផ្លូវក្បាលថ្នល់ច្បារអំពៅ, ចាក់អង្រែ ទៅដល់ស្ពានព្រែកតូច កោះធំ។ ក្នុងនោះពេលដែលចេញទៅនោះ គឺពេលដែលជម្លៀសចេញទៅពីភ្នំពេញចេញទៅហ្នឹង គឺឪខ្ញុំ ម្តាយខ្ញុំ បងខ្ញុំ គឺចេញទៅមុន។ បាទ ឲ្យខ្ញុំចាំផ្ទះជាមួយនឹងបងស្រីខ្ញុំ។ គាត់ចេញទៅក្រោយ៣ថ្ងៃ ក្រោយ១អាទិត្យក្រោយមកបានខ្ញុំចេញទៅក្រោយ។ ពេលដែលនោះ គឺចម្លៀសចេញហ្នឹង គឺដេញយកមែនទែន។ មុនដំបូងថាឲ្យចេញទៅមួយរយៈទេ ចាំគេរៀបចំភ្នំពេញឲ្យវាស្រួលបួលសិន បានគេឲ្យចូលវិញ។ ក៏ខ្ញុំក៏ចេញដើរទៅហ្នឹង ទៅស្វែងរក ព្រោះឪខ្ញុំ ម្តាយខ្ញុំហ្នឹងចេញទៅមុននោះ។ គាត់មុននឹងចេញទៅហ្នឹង គាត់ថាឲ្យរកតាមផ្លូវមាត់ទន្លេទៅឃើញហើយ។

ក៏ខ្ញុំចេញទៅហ្នឹង ទៅអត់ឃើញគាត់ទេ ដើររកទៅតាមមាត់ស្ទឹងហ្នឹងឃើញតែខ្មោច។ ជួបខ្មោចជួបអីហ្នឹងតាមផ្លូវ។ ហើយដល់ទៅដល់ឆ្ងាយមែនទែន គឺថាឲ្យបង្ខំឲ្យទៅកន្លែងអង្គការ១ថ្នាក់លើអង្គការគេហ្នឹង ទៅជួបអង្គការគេទៅ។ កន្លែងហ្នឹងសំបូរស៊ី សំបូរចាយណាស់ សំបូរសប្បាយសាច់ជ្រូកមួយគីឡូហ្នឹងប៉ុន្មាន ពីរបីរៀលទេ។ មិនដូចទាហានលន់ នល់ គុយទាវមួយចានប្រាំរយរៀលទេ។

[១១:៣២:៥០]

ហើយចេះតែទៅៗ រកសួរគេ ដែលអ្នកគេទៅមុនហ្នឹងសួររកឪខ្ញុំ។ គេថា អូ៎! ឪឯង ម៉ាក់ឯង បងឯងអីហ្នឹង គេឲ្យទៅមកទទួលសម្តេចវិញណា។ ហើយដល់តែខ្ញុំហ្នឹងក៏ចង់មកវិញដែរ មកវិញមកអត់រួច គេថាឯងចង់ទៅងាប់អីទៀត។ គេទៅហ្នឹង អ្នកដែលទៅវិលថយក្រោយ គេថាឲ្យទៅ ឲ្យថា

មកនេះហ្នឹងទៅទទួលសម្តេចហ្នឹងថាទៅងាប់ហើយ មិនមែនទៅរស់ទេ។ ខ្ញុំក៏ភ័យ ក៏ចេះតែទៅៗ ចេះតែទៅកន្លែងអង្គការគេ កន្លែងគេឲ្យចូលតាមការដ្ឋាន។ មុនដំបូងចែកអង្ករ ចែកមួយកំប៉ុងពីរនាក់ ហើយអំបិលមួយកញ្ចប់។ ហើយដល់ចូលស៊ីប់មែនទែន ចាប់ផ្តើមបបរ។ អត់គេចែកអង្ករ បបរធ្វើការ។

ដូចដឹងស្រាប់ហើយសម័យនោះគេហៅថា គុកឥតជញ្ជាំងហ្នឹង បង្អត់តែអាហារហ្នឹងស្គមគ្មានធ្វើការអីរួចទេ ធ្វើការទាំងបង្ខំ។ ហើយយកអាបបរហ្នឹងមកលាយត្រកួន លាយបន្លែអីហ្នឹង ឃើញមិនបានទៀតហ្នឹង ឈ្លបហ្នឹងទាត់កាម៉ែល ខ្ចាយកំពប់អស់។ គ្រាន់តែផ្លែស្វាយមួយបេះ សឹងអាយុជីវិត រើខ្ចប សុទ្ធតែកាំភ្លើង ពួកអាកាំភ្លើងអូសដី អាតូចៗ អាក្មេងៗហ្នឹង។ ដូចចប់ និយាយទៅវាដូចជាអួលដើម-ក មិនចង់ ព្រោះគេចោទថាអាហ្នឹង ពួកអាភ្នំពេញមកហ្នឹង សុទ្ធតែអាអ្នកពួកមិនចេះធ្វើការអីទេ ពួកអាសក្តិភូមិ ពួកអាដេកស៊ី ពួកអានាយទុនអីហ្នឹង។ ចេះធ្វើរកអីទេ ពួកអាហ្នឹង ឲ្យបង្អត់អ៊ីចឹងឲ្យសមមុខ។ វានិយាយអ៊ីចឹង។ ឯរហូតដល់ធ្វើម៉េច -- ហើយម្យ៉ាងទៀត ខ្ញុំវាអាចនឹងឮឃើញថាគេដូចខ្ញុំអ្នកកម្ពុជាក្រោមដែរ ប៉ុន្តែខ្ញុំនៅភ្នំពេញ ខ្ញុំអាចសំឡេងវាមិនដូចកម្ពុជាក្រោម ព្រោះឪពុកខ្ញុំ ម្តាយខ្ញុំបែបនិយាយខាងកម្ពុជាក្រោម ហើយអ្នកឃើញៗអ្នកកម្ពុជាក្រោមហ្នឹង។ រួចប្រមូល ហៅស្មើយកទៅធ្វើចម្ការ។ ប្រមូលផ្តុំមិនយកទៅសម្លាប់ឯណាអស់។ យកទៅមួយកន្លែងទៅកន្លែងហ្នឹង ប្រមូលម្តុំៗ។ សួរថាពួកហ្នឹងគេទៅណា? គេថា យី!យកទៅធ្វើចម្ការ ដល់លួចសួរគេទៅ ម៉ែ! គេយកទៅដាក់អន្លង់អស់។ គេចោទថាយួន។ បាទយួន ពួកអាហ្នឹងយួន។ គេសម្លាប់ វាថាយួន។ ហើយមិនមែនថានេះអី គ្នានៅរស់នៅតាំងពីសង្គមម៉្លេះ មិនមែនថាត្រឹមនេះ សម័យសម្តេចឪ គ្រាន់តែថាត្រកូលថាច់ ត្រកូលង្វៀង ត្រកូលសឺង អីហ្នឹង។ ហើយគាត់ខ្មែរដែរតើ នៅកម្ពុជាក្រោម ប៉ុន្តែឡើងមកមានត្រកូលខ្លះ ដូចថាជដែកមានពាក្យខ្លះហ្នឹង ដូចមានលាយវៀតណាមខ្លះអ៊ីចឹងណ៎ា។

[១១:៣៦:៥២]

ដូចឧបមាថា មានពាក្យមួយនិយាយថា វាឡើហើយហ្នឹងណ៎ា អា "ឡើហើយ" ហ្នឹងគឺថាពាក្យៗហ្នឹងគឺ អាឡើៗហ្នឹងពាក្យវៀតណាមទេ។ ហើយវាមាននេះដែរ ហើយអ៊ីចឹងទៅ ឮសួរអ៊ីចឹងវាថាពួកអាហ្នឹងយួន ទុកវាមិនបានទេ។ ដល់បន្តិចទៀតទៅយួននៅពេញប្រទេសខ្មែរហើយ យកពួកអាពួកកម្ពុជាក្រោមហ្នឹង អាពួកហ្នឹងហើយដែលនាំអាទីឲ្យយួនមក, ពួកអា សេ.អ៊ី.អា អាមេរិកាំង។ ព្រោះខ្ញុំមានបងប្អូនខ្ញុំដែរ នៅកាលសម័យរដ្ឋកម្ពុជា សម័យ លន់ នល់ ដែលគេយកទាហានម៉ៃហ្វកមកហ្នឹង ដូចមានអ៊ំខ្ញុំដែរ អ៊ំខ្ញុំ ថាច់ ឡុង, ទៀង កិច ហើយឪខ្ញុំពីសង្គមម៉េច គាត់ធ្វើការជាមួយនឹងតា សឺន សាន ដែរ

តើ ហើយនិងតា ដៀន ដេល ហ្នឹង។ ហើយមានតែ ហើយអ៊ំខ្ញុំមួយចំនួន ហើយបងប្អូនខ្ញុំច្រើនណាស់ដូច នៅខាងរំលេច បឹងខ្នារ ហើយសព្វថ្ងៃហ្នឹងខ្ញុំទៅរស់នៅ ទៅរកឃើញមានបងប្អូនខ្ញុំនៅសល់ខ្លះៗដែរនៅ រង្សីខេត្តបាត់ដំបងហ្នឹង។ ទៅខ្ញុំបានប្រពន្ធហ្នឹងទៅ រហូតជាខ្ញុំមិនជឿថាឪ ឪពុកម្ដាយខ្ញុំថាស្លាប់ទៀត ខ្ញុំទៅរករហូតដល់ជំរំទៀត។ រកដល់ជំរំនោះ ក៏អត់ឃើញទៀត ក៏ទៅធ្វើទាហាននៅនោះមួយសាទៀត។ ធ្វើទាហានក្នុងមិនឆ្អែតទេ ធ្វើក្រៅទៀត ដើម្បីរក ស្វែងរកបងប្អូនអត់ឃើញអ្នកណាម្នាក់។

[១១:៣៨:៤៩]

គិតទៅ ហើយខ្ញុំក៏វិលត្រឡប់ទៅកម្ពុជាក្រោម ក៏សួរអ្នកដែលស្រុកនៅកម្ពុជាក្រោមដែលនៅបងប្អូនគាត់ហ្នឹង បងប្អូនឪ ឪពុកខ្ញុំហ្នឹង ឪខ្ញុំហ្នឹង ក៏គ្មានអ្នកណាដឹង ឃើញម្នាក់ដែរ។ គឺថាឱអ៊ីចឹងបានថាដឹងថាអស់ ព្រោះខ្ញុំឃើញផ្ទាល់នឹងភ្នែកហើយ ឃើញដែលអ្នកកម្ពុជាក្រោមហ្នឹង ឡើងកម្ពុជាក្រោមប្រជាជននោះ យកគ្នាទៅវ៉ៃចោលនោះ ថាស្នើទៅធ្វើណោះ ធ្វើណោះ គឺយកទៅបាត់ៗទៅ។ អាហ្នឹង គឺខ្ញុំសូមឆ្លើយមួយវគ្គសិន។ រឿងការឈឺចាប់ហ្នឹង និយាយទៅពិបាកដែរ វាអ្នកណាដូចអ្នកណា។ ថាសូម្បីតែពស់ បង្គួយអីវត់កាត់មិនបានទេ ស៊ីតាំងពីបង្គួយ តាំងពីថ្លែនឡើងទៅបានរស់។

[១១:៤០:00]

**ប្រធានអង្គជំនុំ៖**

បាទ ដើម្បីបង្កើនល្បឿននៃកិច្ចពិភាក្សា អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះកូនក្ដីរបស់លោក។

សូមអញ្ជើញ!

**លោក សំ សុគង់៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក សំ សុគង់៖**

**ស៖** ជម្រាបសួរលោក សឿន សួវណ្ណី។ តាមការរៀបរាប់របស់លោកពីខាងលើអម្បាញ់មិញថា ក្រុមគ្រួសារលោកបានជម្លៀសចេញពីទីក្រុងភ្នំពេញមុនលោក រយៈពេល១អាទិត្យ។ សូមលោកបញ្ជាក់ឲ្យបានច្បាស់ថា មូលហេតុអីបានជាក្រុមគ្រួសាររបស់លោកចាកចេញមុនលោក មុនមួយអាទិត្យ? ហេតុអីបានលោកបន្តនៅទីក្រុងភ្នំពេញមួយសប្ដាហ៍ទៀតបានចេញទៅតាមក្រោយ?

[១១:៤០:៤៩]

**លោក សឿន សុវណ្ណី៖**

**ឆ៖** បាទ នេះគឺគាត់ឲ្យនៅចាំផ្ទះ ឲ្យនៅចាំផ្ទះសិន។ បាទ ឲ្យនៅចាំផ្ទះសិនពីរនាក់បងខ្ញុំឈ្មោះបងមួយអ៊ី។ ឲ្យនៅចាំផ្ទះសិន បើរំលង បើថាមិននឹកឃើញ ស្មានថាវាដេញទៅរហូតឯណា។ គឺថាគ្រាន់តែរៀបចំសិនតើ។ តែដល់ពេលនេះ ក្រោយ១អាទិត្យចុងក្រោយមក សុទ្ធតែភ្លង់ អ្នកណាដូចអ្នកណាដែរភ្លង់កាំភ្លើង បើមិនចេញបាញ់ចោល កម្ទេចចោលនៅហ្នឹងផ្ទះ។ ចុះឮសួរដែរ ឮសួរបុកបេបាញ់ក្នុងក្លាំងក៏ចេញ។ ហើយឪខ្ញុំមុននឹងចេញទៅគាត់និយាយប្រាប់ គាត់ថា "ចេញទៅមុនហ្នឹងទៅរកតាមមាត់ទន្លេទៅឃើញហើយ" បើសិនជានេះទៅ ក៏ទៅអត់ឃើញ។ ទៅជួបគេអ្នកគេស្គាល់ គេថា ឪហ្អែង បងហ្អែង ម៉ាក់ហ្អែងមកវិញហើយ។ មកភ្នំពេញវិញហើយ មកទទួលសម្តេច។

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធនឹងលោកបានរៀបរាប់ថា នៅពេលដែលកងទ័ពខ្មែរក្រហមចូលទីក្រុងភ្នំពេញ នៅពេលនោះលោកបានរៀបរាប់ថា មានការបាញ់ មានការនេះ។ ចុះចំពោះក្រុមគ្រួសាររបស់លោក នៅពេលនោះកងទ័ពខ្មែរក្រហមបានចូលទៅក្នុងផ្ទះរបស់លោកដើម្បីជម្លៀសក្រុមគ្រួសារលោកចេញពីទីក្រុងភ្នំពេញដែរឬទេ?

[១១:៤២:១៩]

**ឆ៖** គឺវាបណ្តេញហ្នឹងហើយបានជាយើងចេញ ព្រោះបង្ខំឲ្យចេញ ដែលថាឲ្យនៅចាំផ្ទះ។ គឺមិនបានទេ ថា ឪខ្ញុំម៉ាក់ខ្ញុំឲ្យនៅចាំផ្ទះ យ៉ឺ! មិនបានទេណ៎ះ! តែនេះ តែអាមេរិកាំងទម្លាក់គ្រាប់បែកហ្នឹងប្រយ័ត្នងាប់ទាំងអស់គ្នាណ៎ា។ ហើយមិនឃើញៗគេដឹកសម្ភារៈចេញពីភ្នំពេញទេ។ ចុះឃើញមែនមួយថ្ងៃៗដឹកនិយាយពីដឹកទាំងពីកាំភ្លើង ទាំងសម្ភារៈ។ ឡាន អាឡាន គេហៅឡានសំណាញ់ អាឡានសៗ អាឡានហ្នឹង ហើយឡានហ្សេ.អឹម.សេ។ ឡានទាហាននោះដឹកនិយាយពីដឹកអីវ៉ាន់ចេញពីភ្នំពេញហ្នឹង នឹកឃើញថាគេៗ ឃើញគេរៀបអីវ៉ាន់ អីវ៉ែអីវ៉ាន់ចេញទេ គេខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែកហ្នឹងណា។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងបញ្ហាជម្លៀស ខ្ញុំសូមសួរទាក់ទងនឹងការធ្វើដំណើរតាមផ្លូវរបស់លោក។ លោកថានៅពេលដែលក្រុមគ្រួសារលោកចេញពីទីក្រុងភ្នំពេញមុនលោករយៈពេលមួយអាទិត្យ លោកក៏ធ្វើដំណើរទៅតាមរកគ្រួសារ។ តើនៅក្នុងពេលលោកធ្វើដំណើរនោះស្ថានភាពនៅក្នុងពេលធ្វើដំណើរលោកឃើញមានស្ថានភាពបែបណាដែរនៅពេលធ្វើដំណើរនោះ?

**ឆ៖** បាទ ពេលដែលស្ថានភាពតាមផ្លូវនោះ គឺឃើញដូចថាមានសាកសពដែល ដូចថាអង្កាល់ខ្មោចដែលបាញ់ទាហាន ហើយដូចថាមួយសព្ទាហ៍ហ្នឹងដូចជាមានអ្នកខ្លះដូចបញ្ឆោតឱ្យមកទទួលសម្តេច ឬមួយទទួលអីហ្នឹង មួយកន្លែងៗហ្នឹង។ ឃើញអាត្រាក់ទ័រហ្នឹង អាត្រាក់ទ័រហ្នឹងរុញៗខ្មោចទម្លាក់គ្រលុកកន្លែងណាអ៊ីចឹង គឺអាត្រាក់ទ័រហ្នឹងរុញកប់ ហើយស្អុយតាមតែផ្លូវហ្នឹង។ សុទ្ធតែខ្មោចទាហាន ខ្មោចនេះហ្នឹង។ ហើយជាពិសេសតាមមាត់ៗទន្លេ តាមមាត់ទន្លេ អត់ប៊ានដងទឹកផឹកទេ ទៅរកអាទឹកអណ្តូងឃ្នូរអាទឹកថាំងគេនេះ អត់ប៊ានដងទឹកតាមមាត់ទន្លេផឹកទេ ឃើញសុទ្ធតែខ្មោច ហើយដង្កូវដល់ហើយ និយាយពីឃើញ--

[១១:៤៤:៣៦]

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងការធ្វើដំណើររបស់លោក តើនៅពេលនោះលោកបានជួបនូវបញ្ហាទុក្ខវេទនា ឬការឈឺចាប់អ្វីខ្លះ? ហើយនៅពេលនោះ តើទាក់ទងនឹងការ-- អារម្មណ៍របស់លោក តើលោកមានអារម្មណ៍យ៉ាងណាដែលនៅពេលធ្វើដំណើរតាមផ្លូវនោះ?

**ឆ៖** ពេលនោះ គឺមានអារម្មណ៍ស្តាយដែរ ដូចថា នឹកឃើញថា -- វាអត់នឹកឃើញថា -- មានអារម្មណ៍ថា "យី! អាដែងខ្មោចហ្នឹង មិនដឹងខ្មោចនរណា?" ហើយម្យ៉ាងទៀត គេដេញៗថាឲ្យទៅៗកន្លែងអង្គការៗគេហ្នឹងណ៎ះ! គេថាកន្លែងសម្បូរសប្បាយ ហើយខ្ញុំគិតឃើញថា បែបគេរៀបចំឱ្យទៅកន្លែងទៅធ្វើស្រែទៅធ្វើស្អីកន្លែងអង្គការគេនុ៎ង ប្រហែលជាសម្បូរសប្បាយហើយ។ ហើយចុះពេលជម្លៀសចេញ គេមិននិយាយអ៊ីចឹង គេថាទៅដល់កន្លែងហ្នឹងមានហើយ ដូចថាអីវ៉ែអីវ៉ាន់, ដូចថាសាច់ជ្រូកមួយគីឡូពីរបីរៀលទេ គុយទាវមួយចានតែពីររៀលអីទេ។ គេផ្តាស់របស់អានល់ ចេញហើយ។ អ៊ីចឹងទៅតិចទៀតទៅ ទៅដល់អង្គការគេហើយ។ ទៅដល់អង្គការកន្លែងណាទេ ទៅៗ ស្រាប់តែចូលដល់--

[១១:៤៥:៥៩]

**ស៖** បាទ សូមអរគុណលោក។ ពាក់ព័ន្ធនឹងការធ្វើដំណើរ លោកបានជម្រាបប្រាប់អង្គសវនាការពីខាងលើថា លោកធ្វើដំណើរមិនបានជួបក្រុមគ្រួសារក៏ដូចជាឪពុកម្តាយរបស់លោកទេ។ តើទាក់ទងនឹងការអារម្មណ៍របស់លោកវិញ នៅពេលដែលលោកមិនបានជួបក្រុមគ្រួសាររបស់លោកនៅពេលដែលលោកតាមរកពួកគាត់ ហើយមិនដឹងថា គាត់ហ្នឹងមានស្ថានភាពបែបណា? តើអារម្មណ៍របស់លោកមានអារម្មណ៍យ៉ាងដែរនៅពេលនោះ?

**ឆ៖** ដូចជាកាលនោះ ដូចជាមានអារម្មណ៍រន្ធត់ដែរ ហើយម្យ៉ាងទៀតកាលនុំងដូចនៅអាយុប្រហែលជាប្រាំពីរប្រាំបីដណ្តប់ហ្នឹង អង្កាល់នុំងវាថាដូចមិនសូវជាគិតអីជាបញ្ហាអីប៉ុន្មានទេ ព្រោះថាមានតែរន្ធត់ក្នុងចិត្តដែរ ឃើញខ្មោច ឃើញអីហ្នឹង។ ហើយដល់តែពេលទៅដល់កន្លែងអង្គការហ្នឹងបាន ៗមែនទែនបណ្តោយ ហើយនឹកឃើញថា អីយ៉ាងគេចូលមក ដល់ឲ្យធ្វើការធ្ងន់ធ្ងរអ៊ីចឹង ឲ្យស៊ីបបរអ៊ីចឹងបែបមិនរស់ទេ។ បើតាមមើល ខ្ញុំគិតខ្លួនខ្ញុំ ហើយបើបែងចែកអាដែងគេថា ១៧, ១៨ណ៎ះ! បើតាមខាង ១៨ហ្នឹង គេមានអី គេស៊ីផ្អែតស៊ីអីទៅ។ ហើយអ្នក ១៧មានអី ឲ្យធ្វើការក្បាលជង្គង់ធំជាងក្បាលហ្នឹង។

[១១:៤៧:២៧]

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធទៅនឹងការធ្វើដំណើរពីទីក្រុងភ្នំពេញ រហូតដល់ទៅដល់ស្រុកស្អាងដែលជាទីចុងក្រោយ។ នៅពេលនោះ នៅពេលដែលពូ -- នៅពេលដែលលោកធ្វើដំណើរ តើលោកមានត្រូវបានទាហានខ្មែរក្រហម ក៏ដូចជាក្រុមខ្មែរក្រហមធ្វើប្រវត្តិរូបពូដែរឬទេ?

**ឆ៖** បាទ ពេលនោះឯងក៏ខ្ញុំធ្វើដែរ។ ពេលនោះ ខ្ញុំនឹកឃើញអារម្មណ៍មួយមាន ដូចថាមួយនុំងគាត់នៅសង្គមកិច្ច គាត់មានបងប្អូនគាត់ គាត់អ្នក១៨។ ១៨ គាត់ឃើញខ្ញុំតែងងរែកទឹករែកអីឲ្យគាត់ហ្នឹង គាត់ក៏លួចខ្សឹបប្រាប់ខ្ញុំថា "អ្អែងតិចនិយាយឆ្លើយប្រវត្តិរូបថា ឪអ្អែងនៅភ្នំពេញធ្វើអីៗ ការអីៗណាប្រយ័ត្នងាប់" អ៊ីចឹង "អ្អែងដាក់អ្អែងនៅថា នៅធ្វើស្រែ ធ្វើអ្នកស្រែចម្ការទៅបានរស់។ អ្អែងប្រយ័ត្នថា ឆ្លើយថា ប្រវត្តិរូបថាធ្វើការអីនៅភ្នំពេញងាប់ហើយអត់រស់ទេ"។ គាត់ខ្សឹបប្រាប់ខ្ញុំអ៊ីចឹង។ ដល់ខ្ញុំបានឆ្លើយថា "កូនវណ្ណៈកសិករ ខ្ញុំរវល់ទៅឃ្វាលគោទៅ អាបេសែងកង់ដី ទម្លាប់កណ្តាលផ្ទះទៅងាប់អស់ទៅនៅសល់តែខ្ញុំម្នាក់ឯង"។ ខ្ញុំឆ្លើយថា អ៊ីចឹង។ ក៏គេថា អើ! មិត្តមកម្ខាង។ អាអ្នកឆ្លើយទៅ--

[១១:៤៩:០១]

**ស៖** បាទ សូមអរគុណពូ បាទ កុំឲ្យខាតពេលវេលា។ ពាក់ព័ន្ធទៅនឹងពូបានរៀប ជម្រាបប្រាប់អង្គសវនាការពីខាងលើថា នៅពេលនោះគឺមាននៅក្នុងភូមិរបស់ពូក៏ដូចជាសហករណ៍របស់ពូហ្នឹង កន្លែងធ្វើការហ្នឹង គឺមានគេថា មានក្រុមពួកប្រជាជនថ្មី ក៏ដូចជាខ្មែរក្រោម។ តើពូអាចជម្រាបប្រាប់អង្គសវ-នាការបានថា នៅពេលដែលខ្មែរក្រហមដឹងថាក្រុមណាមួយជាប្រជាពលរដ្ឋថ្មី និងខ្មែរក្រោម តើការរស់នៅរបស់ពួកគាត់មានស្ថានភាពខុសគ្នាបែបណាជាមួយនឹងអ្នកចាស់ ឬក៏អ្នកចាស់នៅទីនោះទេ?

**ឆ៖** បាទ ដែលឃើញហ្នឹងគឺ វាដូចថាអ៊ីចឹង គឺថាឲ្យតែឮសូរនិយាយថាធ្វើប្រវត្តិរូបកម្ពុជាក្រោមអីអ៊ីចឹងទៅ។ គ្រាន់តែឮសំឡេងក៏អាចដឹងដែរ ក៏គេរៀបចំជាក្រុមផ្នែកផ្សេងៗអ៊ីចឹងណ៎ា។ ស្រាប់

តែគេថាអ្នកកម្ពុជាក្រោមហ្នឹងឲ្យទៅធ្វើចម្ការ ធ្វើស្អីអ៊ីចឹងទៅ។ តាមការពិតគឺថាមិនដឹងយកទៅណា បែបយកទៅហ្នឹងហើយ យកទៅពិឃាដទៅអីហើយ បើតាមមើល ខ្ញុំយល់។ ព្រោះគេប្រមូលផ្តុំដាក់មួយកន្លែងៗអ៊ីចឹង ដឹងថាស្ងាត់ៗ ថ្ងៃនេះហើយ អាថ្ងៃនេះខ្ញុំចង់ទៅនឹងគេដែរ។ គេថា អ្ហែ! មិនបាច់ទៅទេ! មិត្តឯងទៅធ្វើអី គេទៅធ្វើចម្ការ"។ ដល់តែព្រឹថ្ងៃក្រោយបានលួចសួរគេបានដឹង បានដឹងថាគេយកទៅសម្លាប់។ ខ្ញុំឯណេះលែងចង់។

[១១:៥១:០២]

**ស៖** បាទ សូមអរគុណពូ។ លោកបានជម្រាបប្រាប់អង្គសវនាការថា លោកបានបាត់ចង់នូវបងប្អូន ជាពិសេសបងប្អូនហើយនិងឪពុកម្តាយ។ ខ្ញុំចង់សួរលោកថា តើលោកដឹងថាពួកគាត់បាត់បង់ហ្នឹងនៅពេលណា? ហើយដឹងថាតើមានអ្វីដែលកើតឡើងចំពោះពួកគាត់ទេ?

**ឆ៖** បាទ អង្កាល់នោះដូចជា វាដូចជាៗចម្រាញ់យ៉ាងម៉េច ឧទាហរណ៍ដូចថា បែងចែក គេចម្រាញ់ថា ដូចជាដូចថា១៧, ១៨អ៊ីចឹង ហើយអ្នកកម្ពុជាក្រោម អ្នកស្អីអ៊ីចឹង ផ្សេងៗគ្នា។ គឺអត់ឲ្យមានចូលប្រច្ចូកច្របល់អ្នកមូលដ្ឋានបានទេ អ្នក១៨បានទេ។ ហើយប្រកាន់ណាស់កាលហ្នឹង បើគេមិនប្រកាន់អ៊ីចឹង គេមិនដឹង ម៉េចនឹងគេរៀបចំទៅតាមនេះកើត។ បើគេធ្វើអ៊ីចឹងខ្ញុំមិនដឹងដែរ ព្រោះខ្ញុំនៅក្មេងដែរ ដូចជាស្អប់តែម្តង ឲ្យឃើញឮសូរថា*កទអេទកទអាញ់* ដូចយ៉ាប់បណ្តោយមួយពេលហ្នឹង។ ហើយ--

**ស៖** សូមអរគុណលោកពូ។ ដោយសារសំណួរខ្ញុំ ខ្ញុំចង់សួរថាតើលោកពូដឹងក្រុមគ្រួសាររបស់ពូ ដូចជាបងប្អូន ដូចជាឪពុកម្តាយហ្នឹងគាត់ស្លាប់។ លោកពូដឹងនៅពេលណា? លោកដឹងថាការស្លាប់ហ្នឹងដោយសារមូលហេតុអីដែរឬទេ?

[១១:៥២:៥៧]

**ឆ៖** បាទ ពេលដែលខ្ញុំមកនេះ គឺថាពេលដែលខ្ញុំដឹងដំណឹងដែលថាគាត់ចូលមកទទួលសម្តេចហ្នឹង គឺមិនទាន់ដល់ស្រុកស្អាងព្រែកតូចទេ។ គឺខ្ញុំទើបតែនឹងទៅដល់កន្លែង -- បាត់ការចងចាំដែរ គឺពាក់កណ្តាលគឺដូច -- ដែលពេលដែលគាត់ជម្លៀសមុនខ្ញុំហ្នឹង គឺមានទៅច្រើនគ្នានៅក្បែរៗផ្ទះហ្នឹង។ ក៏ខ្ញុំសួរគាត់ គាត់ថា អើ! បងអ្នែង ប៉ាអ្នែង ម៉ាកអ្នែង បងអ្នែងអីហ្នឹង ជាមួយអ៊ំអ្នែងស្អីឯណាឯណីហ្នឹង គឺចូលវិលចូលភ្នំពេញវិញអ្នកណាអ្នកចេះដឹងៗហ្នឹង យកមកឲ្យមកទទួលសម្តេច ដើម្បីនឹងទទួលកិច្ចការងារធ្វើវិញ។ ហើយគាត់ធ្លាប់មានជាមន្ត្រីមួយដែរនៅនេះហ្នឹង ហើយមិនដឹងថា គឺថាក៏លួចសួរគេមិនដឹងថាគេយកមកសម្លាប់ត្រង់ណា ក៏អត់ដឹងដែរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំឃើញលោកបានកាន់រូបថត តើលោកមានបំណងថាលោកចង់បង្ហាញរូបនេះជូនអង្គសវនាការ ឬជូនលោកប្រធានដើម្បីពិនិត្យមើលបែបណាដែរលោក បានលោកកាន់រូបថតមក?

[១១:៥៤:៣១]

**ឆ៖** នេះជារូបថតខ្ញុំនៅពេលដែលខ្ញុំ-- *(បង្ហាញរូបថត)*

**ស៖** សូមលើកឱ្យខ្ពស់បន្តិចពូ!

**ឆ៖** ទៅកម្ពុជាក្រោមនោះ រូបថតកូនខ្ញុំទៅយកមក ព្រោះកាលពីសង្គម រូបថតពីសង្គម។ នេះប៉ាខ្ញុំ នេះម្ដាយខ្ញុំ នេះមីងខ្ញុំ នេះបង សឿន សុវណ្ណា, សឿន សុវណ្ណី នេះ សឿន សុវណ្ឌី គឺខ្ញុំ។ ពរនៅនឹងដៃ ម្ដាយខ្ញុំកំពុងពរនេះគឺ សឿន សុវណ្ណឌឿន។ ហើយនេះអ៊ំខ្ញុំ គាត់រត់ឡាំប៉ាតាកង់បីនៅផ្សារអូឡាំពិកពីសង្គមបានមួយគ្រួសារគាត់ស្លាប់អស់ដែរ។ ហើយដល់អ៊ំខ្ញុំដែល ថាច់ ឡុង, ទៀង កិច កាលហ្នឹងបញ្ជូនមកក្រោយទេ កាលពីសម័យលន់ នល់, ដែលអង្កាល់ សឺង ង៉ុកថាញ់ ដែលជំនាន់បញ្ជូនទាហានលន់នល់ទាហានម៉ៃហ្វកនោះណាមកច្បាំងអីហ្នឹង។ ដល់ក្រោយមក ខ្ញុំមកស្រុកខ្មែរទៅ ឮ ស៊ើបសួរគេ គេថាស្លាប់នៅទន្លេបិទអស់រលីង។ គេឱ្យឡើងកប៉ាល់។ គេឱ្យឡើងកប៉ាល់ទៅឮថា កប៉ាល់មួយនេះរាប់រយនាក់ដែរ។ ដល់ឱ្យឡើងកប៉ាល់ថាឱ្យវិលទៅស្រុកយួនវិញ មានតែឡើងដល់ -- គ្រាន់តែឡើងដល់កប៉ាល់វាផ្ទោងដាក់ងាប់ អណ្ដែតពេញមួយទន្លេនៅទន្លេបិទ។ សូមអរគុណ។

[១១:៥៦:០៨]

**ស៖** បាទ សូមអរគុណលោក សឿន សុវណ្ឌី។ លោកអាចជម្រាបប្រាប់សវនាការថាតើលោកមានការឈឺចាប់ពីការស្លាប់ក្រុមគ្រួសារ ឬក៏បាត់បង់ដោយមិនដឹងពីមូលហេតុ រហូតដល់ការឈឺចាប់តើវាអាចមានការឈឺចាប់បន្តដល់បច្ចុប្បន្ននេះដែរឬទេ?

**ឆ៖** ខ្ញុំចង់សួរដល់អង្គសវនាការ ហើយនិងចង់ដល់លោកអ៊ំ ខៀវ សំផន ហើយនិងលោកអ៊ំ នួន ជា--

**ស៖** បាទៗ លោកខ្ញុំសុំសួរសំណួរខ្ញុំមុនសិន ចាំវេទិកានេះរបស់លោកបាទ។ ខ្ញុំចង់សួរថាតើលោកមានការឈឺចាប់ទាក់ទងនឹងការបាត់បង់ក្រុមគ្រួសារក៏ដូចជាឪពុកម្ដាយតាំងពីការបាត់បង់រហូតតើវាមានការឈឺចាប់តាំងពីពេលនោះ ហើយចុះចំពោះការឈឺចាប់បច្ចុប្បន្ន តើលោកនៅមានបន្តដែរឬទេ?

[១១:៥៧:២៧]

**ឆះ** បាទ គឺរឿងការឈឺចាប់ហ្នឹង ឥឡូវនេះគឺខ្ញុំវាដូចថា ពីដើមដូចមានការឈឺចាប់ជាខ្លាំង ដល់ពេលមកឥឡូវនេះដូចថាវារំសាយបន្តិចម្តងៗដែរពីព្រោះថានឹកឃើញថា រយៈកាលកន្លងមកដូចជាវាកាលនោះព្រៃផ្សៃ បើសិនជាកាត់ក្តីភ្លាមៗហ្នឹងគឺអាចនេះបាន ដល់ឥឡូវនេះខ្ញុំគឺថាវាដូចថា -- តែណ្ហើយចុះ ប៉ុណ្ណឹងក៏បានទៅហើយ បើការឈឺចាប់ខ្ញុំវារំសាយបន្តិចម្តងៗដែរ។ បើសិនជាកាលណាធ្វើនូវអ្វីមួយដែលមិនគប្បីនោះ គឺវាត្រូវតែបន្តសង្គ្រាមតទៅទៀតវាមិនអាចឈប់ឈរបានទេ។ ការសងសឹកនោះខ្មែរឃើញតែសម្លាប់ខ្មែរមិនដឹងថាមូលហេតុអ្វី? មិនដែលជនបរទេសណាមកនេះផង ដូចថាកាលសម័យយៀកកុងៗមិនឃើញយៀកកុងឯណា? ឃើញតែខ្មែរវ៉ៃ ខ្មែរលន់នល់នោះ វ៉ៃខ្មែរក្រហម គ្មានឃើញយៀកកុងផង។

**សះ** បាទ សូមអរគុណពូ។ ខ្ញុំនៅមានសំណួរពីទៀតដែលសួរទៅពូ។ សំណួរទី១របស់ខ្ញុំ សួរថា តើនៅពេលដែលពូបានដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តើពូមានបំណងស្នើសុំទៅតុលាការដើម្បីទាមទារនូវសំណងចំពោះការខូចខាតក៏ដូចជាការឈឺចាប់របស់ពូហ្នឹងមានសំណងអីដែរ ពូអាចជម្រាបបានទេ?

[១១:៥៩:៣២]

**ឆះ** បាទ ការសំណងហ្នឹងសុំឲ្យ ដូចអស់លោកដឹងស្រាប់ហើយដូចថា សំណងនោះគឺដូចខ្ញុំរំសាយការឈឺចាប់ សំណងនោះគឺសុំឲ្យថា ឲ្យមកជាសាលារៀន ផ្លូវថ្នល់ ហើយសុំធ្វើជានេះមួយផងធ្វើជាតាមមន្ទីរវត្ត -- កន្លែងតាមវត្តអារ៉ាមធ្វើជាចេតិយមួយសម្រាប់តាំង ធ្វើជាគោរពវិញ្ញាណក្ខន្ធរបស់ខ្មែរកម្ពុជាក្រោមដែលបានចែកឋានទៅនោះ ដែលអត់ដឹងរឿងអីនោះ។ សូម្បីតែកូននៅកន្ទេល ពរនឹងដៃហ្នឹង ក៏យកទៅបោកគល់ឈើដែរហ្នឹង ហើយគ្នាដឹងអី។ ហើយសាច់ឈាមជ័រថាកម្ពុជាក្រោមហ្នឹងហើយយកទៅបោកគល់ឈើ លេងទៅសម្លាប់ឪពុកម្តាយ។ ទុកអាហ្នឹង អាហ្នឹងហើយសងសឹក។ បើតាមខ្ញុំបាទយល់ឃើញ។

**សះ** បាទសំណួរចុងក្រោយរបស់ខ្ញុំ។ តើលោកមានសំណួរអ្វីដែលមានបំណងចង់សួរទៅជនជាប់ចោទទាំងពីររូប ឬក៏ជនជាប់ចោទរូបណាមួយនៅពេលនេះ? ហើយខ្ញុំសូមអរគុណចំពោះលោកដែលបានមកធ្វើសក្ខីកម្មថ្ងៃនេះ។

**លោក សំ សុគង់៖**

បាទ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោក សុវណ្ណី។ ហើយប្រសិនបើមានសំណួរអ្វីចង់សួរចំពោះជនជាប់ចោទ លោកអាចសួរបាន ប៉ុន្តែលោកមិនអាចសួរដោយផ្ទាល់បានទេ លោកអាចប្រើប្រាស់សិទ្ធិរបស់លោកក្នុងការតាំងសំណួរតាមរយៈយើង ប្រធានអង្គជំនុំជម្រះដើម្បីយើងបញ្ជូននូវសំណួរដែលលោកសួរជូនទៅជនជាប់ចោទដើម្បីឆ្លើយ ដើម្បីអនុវត្តឲ្យត្រឹមត្រូវតាមនីតិវិធីដែលបានចែងនៅក្នុងច្បាប់កម្ពុជា ក៏ដូចជាបទវិធានផ្ទៃក្នុងដែលអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។ សូមអញ្ជើញ!

[១២:០១:៥០]

**លោក សឿន សុវណ្ណី៖**

បាទ ខ្ញុំចង់សួរទៅលោកតា ខៀវ សំផន ហើយនិងលោកអ៊ំ នួន ជានោះ។ ថាតើហេតុអ្វីបានជាខ្មែរកម្ពុជា គេសម្រិតសម្រាំង និងប្រមូលផ្តុំខ្មែរកម្ពុជាក្រោមយកទៅសម្លាប់ដែលចោទថា ក្បាលយួនខ្លួនខ្មែរ។ ទី២ តើលោកមានវិប្បដិសារី ឬទេក្នុងការបង្កើតគោលនយោបាយដែលធ្វើឲ្យជនរងគ្រោះមានការឈឺចាប់ពីក្នុងរបបនោះដែរឬទេ? ទី៣ទៀត បើប្រសិនណាជាលោកអាចត្រឡប់ទៅជាដឹកនាំរបបនេះវិញ តើលោកមានដឹងអ្វីដើម្បីធ្វើឲ្យមានការកផ្លាស់ប្តូរប្រសើរឡើងវិញដែរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោក សុវណ្ណី។ បាទឥឡូវនេះ អង្គជំនុំជម្រះសូមបញ្ជូននូវសំណួរដែលសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី សឿន សុវណ្ណី ជូនទៅជនជាប់ចោទទាំងពីរ។ ជូនទៅលោក ខៀវ សំផន ដើម្បីមានឱកាសឆ្លើយតបទៅនឹងសំណួរដែលសួរនេះមុនលោកជនជាប់ចោទ នួន ជា។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម។ ទោះបីថាខ្ញុំមិនជំទាស់ទៅលើសំណួរដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែខ្ញុំសង្កេតឃើញថាសំណួរទី១ គឺវានៅឆ្ងាយពីវិសាលភាពនៃសវនាការក្នុងពេលបច្ចុប្បន្ននេះ។ ខ្ញុំមិនប្រាកដថា តើបញ្ហានេះវិសាលភាពការជំនុំជម្រះហ្នឹង គឺជាបញ្ហាដែលមេធាវីការពារក្តីអាចលើកឡើង ឬក៏អត់នោះទេ ប៉ុន្តែខ្ញុំគិតថាចំពោះ

បញ្ហាខ្មែរកម្ពុជាក្រោម គឺដូចជាមិនស្ថិតនៅក្នុងបញ្ហាដែលយើងកំពុងពិភាក្សានោះទេ។

[១២:០៤:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ បន្ថែមទៅលើការលើកឡើងរបស់មេធាវីលោក នួន ជា ខ្ញុំសូមលើកទៅលើចំណុចសំណួរទី៣ ដែលដើមបណ្តឹងរដ្ឋប្បវេណីសួររបៀបជាឧបមាណវិធី ដែលចំណុចនេះមិនគួរអនុញ្ញាតឲ្យជនជាប់ចោទឆ្លើយទេ។ ដូច្នេះ ខ្ញុំសូមឲ្យលោកប្រធានសម្រេចបដិសេធមិនប្រគល់សំណួរទី៣ទៅឲ្យលោក ខៀវ សំផន ឬក៏លោក នួន ជា ឆ្លើយ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមេធាវីលោក មេធាវីការពារក្តីលោក នួន ជា លើសំណួរទី៣យ៉ាងម៉េចទៅ? មានភាពច្បាស់លាស់ ជំទាស់ដូចមេធាវីការពារក្តីលោក ខៀវ សំផន ដែរទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំឃើញអំពីការសន្មតលើសំណួរនេះរួចទៅហើយ ហើយខ្ញុំក៏គិតថាកូនក្តីខ្ញុំដឹងអំពីការសន្មតនេះ។ ដូច្នេះយើងជំទាស់សំខាន់ទៅលើសំណួរទី១។

[១២:០៥:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក -- អ៎! លោក សុវណ្ណី!

**លោក សំ សុគង់៖**

សូមអរគុណលោកប្រធាន។ ទាក់ទងនឹងសំណួរទី១ ដែលដើមបណ្តឹងរដ្ឋប្បវេណី គាត់បានសួរទៅជនជាប់ចោទ ខ្ញុំយល់ឃើញថាពាក្យថា "សម្រិតសម្រាំង ឬក៏ការប្រមូលផ្តុំយកទៅសម្លាប់ ឬក៏ជាក្បាលយួនខ្លួនខ្មែរ" នេះ យើងឃើញនេះគឺជាអង្គហេតុមួយដែលមាននៅក្នុងវិសាលភាពនៅក្នុងសំណុំរឿង០០២ទាំងមូល ហើយសំណួរនេះ ខ្ញុំគិតថានៅដោយសារគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី ហើយគាត់មកថ្លែងនៅការឈឺចាប់ ហើយនិងជាឱកាសក្នុងការគាត់សួរទៅជនជាប់ចោទ ដើម្បីជនជាប់ចោទមានឱកាសឆ្លើយនូវសំណួររបស់គាត់។ ហើយទាក់ទងនឹងសំណួរទី៣ ខ្ញុំគិតថានេះជាការសួរដើម្បីឲ្យជន

ជាប់ឲ្យមាន ឲ្យឆ្លើយទៅនឹងអ្វីដែលលោកជាដើមបណ្តឹងដើម្បីសួរ ដើម្បីឲ្យដឹងថាតើមានការផ្លាស់ប្តូរទេ បើសិនជាគាត់ហ្នឹងអាចនឹងដឹកនាំរបបដូចពីមុនមកនោះ? បាទ សូមអរគុណ។

[១២:០៧:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៩:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់មេធាវីការពារក្តី ដោយសំណួរទី១ គឺអង្គជំនុំជម្រះសូមជម្រាបជូនថា សេចក្តីណែនាំក្នុងការកំណត់អំពីការស្តាប់នូវទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម និងផលប៉ះពាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺអង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចរៀបរាប់លើកឡើងអំពីបញ្ហាការប៉ះពាល់សេចក្តីទុក្ខសោករបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល គឺចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃ០៦ ខែមករា ឆ្នាំ៧៩។ ដូច្នេះគឺសំណួរនេះគឺសមស្របដែលដើមបណ្តឹងរដ្ឋប្បវេណីបានតាំងសំណួរចំពោះជនជាប់ចោទ ហើយជនជាប់ចោទគប្បីពិចារណា ហើយនិងឆ្លើយតបទៅនឹងសំណួរនេះដោយនៅក្នុងវិសាលភាពនៃសំណុំរឿងដែលយើងបានកំណត់ធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនាដើមបណ្តឹងរដ្ឋប្បវេណី។

[១២:១១:០៤]

ហើយដោយឡែកគឺសំណួរដែលជំទាស់លើសំណួរទី៣ គឺនេះគឺជាសំណួរមួយដែលមានការពាក់ព័ន្ធផ្ទាល់ ឬក៏ដោយប្រយោលទៅនឹងសេចក្តីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនេះឱកាសដែលដើមបណ្តឹងរដ្ឋប្បវេណីមានបំណងបង្ហាញអំពីការពិចារណារបស់គាត់ក្នុងការតាំងសំណួរចំពោះជនជាប់។ ដូច្នេះអាស្រ័យទៅលើជនជាប់ចោទនៅក្នុងការឆ្លើយតបទៅនឹងសំណួរទាំងអស់នេះ ហើយនិងអង្គជំនុំជម្រះសូមបញ្ជូននូវសំណួរនេះទៅជូនទៅលោក ខៀវ សំផន ដើម្បីមានឱកាសអាចឆ្លើយតបទៅនឹងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនលោក នួន ជា។ សូមអញ្ជើញ!

**លោក ខៀវ សំផន៖**

សូមជម្រាបសួរលោក សឿន សុវណ្ណី។ ខ្ញុំរីករាយនឹងឆ្លើយនឹងសំណួររបស់លោកទាំងបី។ សំណួរទី១ ថាតើហេតុម្តេចបានជាខ្មែរក្រហមបែងចែកបងប្អូនកម្ពុជាក្រោម ហើយយកបងប្អូនទៅសម្លាប់ចោល? រឿងនេះបើតាមខ្ញុំដឹងដូចជាមិនអីចឹងទេ។ បើតាមខ្ញុំដឹងគឺជំនាន់នោះ មេៗខ្មែរក្រហម

ទាំងអស់ មានទិសដៅប្រមូលរួមជាមួយបងប្អូនកម្ពុជាក្រោម ដើម្បីជាកម្លាំងរួមគ្នាតស៊ូទប់ទល់នឹងអំពីឈ្លានពានរបស់វៀតណាម។ អត់មានសំណួមពរអីទៅបែងចែកអីចឹងទេ។ នេះខ្ញុំសូមជម្រាបលោកប៉ុណ្ណឹង។

[១២:១៣:៣៦]

សំណួរទី២ ថាតើខ្ញុំសោកស្ដាយទេដែលខ្ញុំបានបង្កើតនយោបាយមួយដែលបង្កឲ្យមានជាទុក្ខសោកវេទនាឥតគណនាដល់ប្រជាជនយើងយ៉ាងនេះ? ខ្ញុំសូមជម្រាបលោកថា ខ្ញុំអត់បានបង្កើតនយោបាយយ៉ាងនេះទេ ពីព្រោះមួយជីវិតរបស់ខ្ញុំនេះ ខ្ញុំមិនដែលនឹកឃើញទៅធ្វើបាប ធ្វើទុក្ខ សម្លាប់អ្នកណាទេពិសេសខ្មែរគ្នាឯង។ នេះចំពោះសំណួរទី២។

សំណួរទី៣ ថាបើអាចត្រឡប់ថយក្រោយវិញ តើខ្ញុំនឹងប្រកាន់អាកប្បកិរិយាយ៉ាងម៉េចវិញ? សំណួរទី៣របស់លោកនេះ ខ្ញុំពិបាកឆ្លើយដែរ ពីព្រោះជីវិតមនុស្សវាមិនអាចថយក្រោយទៅវិញទេ។ ចាស់ហើយវាមិនអាចទៅជាក្មេងវិញទេ ក៏ប៉ុន្តែឧបមាចុះ ឧបមាថាយើងអាចត្រឡប់ថយក្រោយទៅវិញបាន។ តើខ្ញុំនឹងធ្វើយ៉ាងម៉េច? ខ្ញុំបើអាចត្រឡប់ថយក្រោយបាន ខ្ញុំនឹងទាមទារឲ្យមានសិទ្ធិដឹងឮនូវព្រឹត្តិការណ៍ជាសោកនាដកម្មផ្សេងៗគ្រាប់បែបយ៉ាងទាំងអស់ ដែលកើតមាននៅក្នុងពេលនោះ។ ឲ្យខ្ញុំមានសិទ្ធិដឹងឮផង ហើយខ្ញុំនឹងទាមទារដាច់ខាតឲ្យបក្សកុម្មុយនីស្ដកម្ពុជាត្រឡប់មកទិសដៅវិញ ទិសដៅដើមរបស់ខ្លួនវិញ នៅពេលដែលខ្លួនបានបដិសន្ធិនោះ។ គឺទិសដៅអី? គឺទិសដៅប្រទេសបានឯករាជ្យសន្តិភាព ប្រជាជនបានមានហូបមានចុកគ្រប់គ្រាន់ ហើយសម្បូរសប្បាយ ហើយសល់ផលស្រូវខ្លះ ឬផលអ្វីផ្សេងៗទៀតខ្លះនាំចេញយកទៅ ដើម្បីទិញថ្នាំសង្កូវមកព្យាបាលប្រជាជនយើង។ ពីព្រោះជំនាន់នោះ ប្រជាជនយើងខ្វះថ្នាំសង្កូវខ្លាំងណាស់ ហើយក្រៅពីថ្នាំសង្កូវ ប៉ុន្តែទិញថ្នាំសង្កូវ និងទិញថ្នាំបម្រើជីវភាពប្រជាជនហ្នឹងជាសំខាន់បានកំណត់អីចឹងច្បាស់ថា អាហ្នឹងជាបុព្វសិទ្ធិទី១ហើយ។

[១២:១៧:៤០]

ហើយបន្ទាប់ពីហ្នឹង បើមានលទ្ធភាពនឹងទិញរោងចក្រទិញអីមកដើម្បីនឹងប្រទេសយើងចេះតែមានទៅជាប្រទេសឧស្សាហកម្មបណ្ដើរៗ។ ខ្ញុំនឹងជម្រាបលោកថាខ្ញុំនឹងទាមទារយ៉ាងនេះ បើខ្ញុំដឹង ប៉ុន្តែវាទាស់តែខ្ញុំវាអត់ដឹងសោះតែម្ដងនូវអ្វីដែលបានកើតឡើងនៅពេលនោះ។ ខ្ញុំអត់បានដឹងទាស់តែសោះខ្ញុំជម្រាបលោកច្បាស់អីចឹង។ សូមលោកអធ្យាស្រ័យដល់ខ្ញុំ ហើយខ្ញុំសូមជម្រាបអស់ប៉ុណ្ណឹងហើយខ្ញុំដឹងថាលោកអាចមិនពេញ មិនអស់ចិត្តទេ ប៉ុន្តែធ្វើម៉េចបើខ្ញុំវាអត់ដឹងអីចឹងមែន។ ខ្ញុំសូមជម្រាប

លោក។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ហើយមន្ត្រីរដ្ឋបាលតុលាការធ្វើការផ្លាស់ប្តូរនៅ ឌីវីឌីភ្លាម!

បាទជាបន្តទៅនេះ អង្គជំនុំជម្រះសូមបញ្ជូននូវសំណួរដែលសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះជូនទៅជនជាប់ចោទ នួន ជា ដើម្បីឆ្លើយតបទៅនឹងសំណួរ។ សូមអញ្ជើញលោក នួន ជា!

[១២:២០:១៨]

**លោក នួន ជា៖**

សូមគោរពអង្គជំនុំជម្រះ សូមគោរពលោកប្រធាន។ ខ្ញុំ នួន ជា សូមបញ្ជាក់ជូនលោក សុវណ្ណី ដូចតទៅនេះ៖ ខទី១ កម្ពុជាប្រជាធិបតេយ្យមិនមានគោលនយោបាយអ្វីបែងចែក ឬប្រកាន់ថាអ្នកនេះជាខ្មែរកម្ពុជាក្រោម អ្នកនោះជាខ្មែរកណ្តាល ខ្មែរលើទេ គឺសាមគ្គីខ្មែរទាំងអស់ ទាំងបងប្អូនខ្មែរកម្ពុជាក្រោម ក៏ដូចជាបងប្អូនខ្មែរខាងលើ ដើម្បីពេលនោះតស៊ូការពារប្រទេសជាតិ។ ដូច្នោះកម្ពុជាប្រជាធិបតេយ្យទុកទាំងអស់ជាខ្មែរតែមួយ។ នេះខ្ញុំសូមជម្រាបដោយស្មោះស្ម័គ្រ មិនមានអ្វីទៅបែងចែកថាខ្មែរកម្ពុជាក្រោមយ៉ាងនេះយ៉ាងនោះ ខ្លួនខ្មែរ ក្បាលយួនអីនោះទេ។ នេះខ្ញុំសូមជម្រាបហើយជម្រាបទៀត។ នេះខទី១។

ខទី២ ដូចជាខទី១ដែរ គឺថាខទី២នេះ តាមខ្ញុំដឹងគឺវាទាក់ទងនឹងខទី១។ ឯ ខទី៣ ខ្ញុំសូមជម្រាបថាកន្លងមកវា៣៨ឆ្នាំជាងកន្លងមកហើយ។ ហេតុដូច្នេះតទៅមុខទៀត ឧបមាថា ឧបមាទេ គឺថាតើកម្ពុជាប្រជាធិបតេយ្យមានគោលនយោបាយយ៉ាងម៉េច? ខ្ញុំឃើញថាទៅតាមសភាពការណ៍នៃប្រទេសនាពេលបច្ចុប្បន្នេះ។ គឺថាកសាងប្រទេស ការពារប្រទេស ធ្វើយ៉ាងម៉េចឲ្យប្រទេសចម្រើនទៅមុខ។ ដូច្នេះយើងមិនអាចទៅយកអារឿងចាស់មកកសាង មកធ្វើជាថ្មីដែរទេ។ នេះខ្ញុំសូមជម្រាបដោយខ្លីតែប៉ុណ្ណឹងទេ។ សូមជម្រាប សូមអរគុណ សូមអរគុណលោកប្រធាន។

[១២:២២:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អរគុណលោក សុវណ្ណី ហើយឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងសាមសិបនាទីរសៀលនេះសូមអញ្ជើញ

ចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយនៅរសៀលនេះអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់នូវសេចក្តីថ្លែងអំពីទុក្ខសោកវេទនាផលប៉ះពាល់ ហើយនិងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សឿង សុវណ្ណី ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីមួយទៀតដែលយើងនឹងបន្តបញ្ចប់នៅរសៀលនេះ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹង -- សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ ឬក៏កន្លែងណាមួយសមស្របសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាកនៅក្នុងអំឡុងពេលអាហារថ្ងៃត្រង់នេះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនត្រឡប់ចូលមកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះវេលាម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:២៣ នាទី ដល់ម៉ោង ១៣:៣៣នាទី)*

[១៣:៣៣:០៧]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្នើ៖**

បាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្នើ៖**

**ស៖** ជម្រាបសួរលោក សឿង សុវណ្ណី។ ខ្ញុំឈ្មោះ ច័ន្ទ តារាស្នី ជាសហព្រះរាជអាជ្ញារងជាតិនៃអង្គជំនុំជម្រះក្នុងតុលាការកម្ពុជា ហៅថាសាលាក្ដីខ្មែរក្រហមនៅទីនេះ។ ខ្ញុំសូមលោកក្នុងនាមសហព្រះរាជអាជ្ញា។ សំណួរជាបន្តនេះ ខ្ញុំសូមសួរបន្តពីសំណួរដែលលោកបានឆ្លើយកាលពីព្រឹកមិញ។ សូមលោកជួយបញ្ជាក់ជូនអង្គសវនាការបានជ្រាប ថាតើមុខរបររបស់ឪពុកលោក នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ហ្នឹង គាត់ប្រកបមុខរបរជាអ្វីដែរបាទ?

[១៣:៣៤:៣២]

**លោក សឿង សុវណ្ណី៖**

**ឆ៖** បាទ គាត់ជាមន្ត្រីមួយ ជាទាហាននៅ ជាទាហាន លន់ នល់ ម្នាក់ នៅជាមួយនឹងលោក សឺន សាន, ដៀន ដេល។

**ស៖** បាទ អរគុណ។ តើនៅពេលនោះ គាត់ពាក់ស័ក្តិប៉ុន្មានដែរ? ហើយនៅក្នុងអង្គភាពណាដែរបាទ?

**ឆ៖** បាទ បើតាមខ្ញុំឃើញគាត់ ស័ក្តិហ្នឹងប្រហែលជាស័ក្តិ៣។

**ស៖** ចុះម្ដាយរបស់លោកវិញ តើគាត់ប្រកបមុខរបរអ្វីដែរនៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥?

[១៣:៣៥:៤១]

**ឆ៖** បាទ ម្ដាយខ្ញុំគាត់ជាអ្នក ដូចថាលក់ដូរម្នាក់។ លក់ដូរជា ដូចជាលក់គ្រឿងអីវ៉ាន់តូចបន្តិចបន្តួចនៅខាងមុខផ្ទះ។

**ស៖** បាទ សូមអរគុណ។ ព្រឹកមិញលោកបានបញ្ជាក់ថា មានពូម្នាក់ឈ្មោះ ទៀង កិច។ គាត់គឺជាទាហាននៅក្នុងរបបសាធារណរដ្ឋខ្មែរគឺរបបលន់នល់។ តើនៅពេលនោះគាត់ពាក់ស័ក្តិប៉ុន្មានដែរ? ហើយគាត់ធ្វើការនៅក្នុងអង្គភាពណាមួយដែរបាទ?

**ឆ៖** បាទ លោកមាខ្ញុំដែល ទៀង កិច នោះ បញ្ជូនមកកម្ពុជាក្រោមដែលទាហានម៉ៃហ្វកនោះ

គឺមានស័ក្តិ៤កន្លះ ទាហាន៤៧។ កាលពីដើមមិញ គាត់នៅឈរនៅវត្តស្លែង ទាហាន៤៧ កងទ័ពម៉ៃហ្វក ដែលបញ្ជូនមក ហើយមានអ៊ំម្នាក់ទៀត ស័ក្តិ៥ – ចាច់ ឡុង, នៅអង្គភាពជាមួយគ្នាហ្នឹងកងពល៤៧។ ទាហានកម្ពុជាក្រោម ទាហានដឹកនាំដោយលោកតា សឹង ង៉ុកថាញ់។

**ស៖** បាទ សូមអរគុណ។ លោក សុវណ្ណី សូមលោកជួយបញ្ជាក់ តើនៅពេលដែលឡើងកប៉ាល់ នៅទន្លេបិទខេត្តកំពង់ចាម តើនៅពេលនោះ លោក ទៀង កិច បានស្ថិតនៅលើកប៉ាល់នោះដែរឬទេ?

[១៣:៣៧:៥២]

**ឆ៖** បាទ ប្រហែលជានៅ ព្រោះគាត់មេទាហាន ជាមេទាហាន គាត់នៅហ្នឹង។ គាត់កូនទាហាន គាត់ទាំងអស់ដែលគេបញ្ជូនទៅកាលហ្នឹងនៅប្រពន្ធ ព្រោះប្រពន្ធគាត់នៅកំពង់ចាម ទន្លេបិទហ្នឹង។ គេបញ្ជូនទៅវ៉ៃត្រង់ហ្នឹងទៅ។ ដល់ពេលចូលមកចរចាត្រូវទៅ គេឲ្យឡើងកប៉ាល់ឲ្យវិលត្រឡប់ទៅវៀតណាមវិញ ទៅកម្ពុជាក្រោមវិញហ្នឹង ក៏ឡើងកប៉ាល់ទៅ ក៏ប្រហែលជារាប់រយនាក់ដែលបានឡើងទៅ។ ដល់ឡើងទៅដល់ហ្នឹង វាផ្ទោងកាំភ្លើងធំ កាំភ្លើងអី បាញ់ពន្លិចទឹក ពន្លិចកប៉ាល់ ស្លាប់អស់ទៅ។

**ស៖** បាទសូមអរគុណ។ នៅពេលដែលមានការផ្តោងដាក់លើកប៉ាល់នៅទន្លេបិទខេត្តកំពង់ចាមនោះ តើនៅពេលនោះ មានទាហានរបស់លន់ នល់ នៅលើកប៉ាល់ជាច្រើន ឬក៏មានប្រជាជនខ្មែរជាច្រើនទៀតនៅលើកប៉ាល់ហ្នឹង បានស្លាប់ក្នុងពេលនោះជាមួយគ្នា ឬក៏យ៉ាងម៉េចបាទ?

**ឆ៖** បាទ ប្រហែលជាបែបអ៊ីចឹងមែន ព្រោះខ្ញុំអត់បានមើលឃើញផ្ទាល់នឹងភ្នែកទេ ព្រោះខ្ញុំនៅភ្នំពេញនេះហើយ។

**ស៖** បាទ សូមអរគុណ។ លោក សុវណ្ណី នៅពេលដែលលោកត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញ តើលោក នៅពេលនោះលោកបានសង្កេតឃើញថា ការជម្លៀសរបស់ខ្មែរក្រហម របស់ទាហានខ្មែរក្រហមហ្នឹង ការបញ្ជាឲ្យជម្លៀសចេញហ្នឹង តើប្រជាជនអាចប្រកែកតវ៉ាចំពោះបទបញ្ជានៃការជម្លៀសនេះបានដែរឬទេ?

[១៣:៣៩:៤៦]

**ឆ៖** បាទ បែបមិនៗប្រកែកបានទេ ព្រោះអាវុធហ្នឹងនៅនឹងដៃហើយ។ បើសិនជាមិនចេញគឺបាញ់សម្លាប់ នៅនឹងផ្ទះហ្នឹងតែម្តង ព្រោះមានដែរ ក្បែរៗផ្ទះខ្ញុំហ្នឹងឃើញជួនបុកបេចូលក៏មាន បាញ់សម្លាប់នៅផ្ទះក៏មាន ដែលមិនព្រមចេញនៅស្តាយរបស់ទ្រព្យ។ ខ្ញុំគ្រាន់តែឃើញអ៊ីចឹងខ្ញុំសុខចិត្តចេញតាមក្រោយទៅ។ គេចៗកន្លែងហ្នឹងទៅ ដើម្បីជីវិតក៏ចេញទៅតាមគេតាមឯងទៅ។ បើនៅប្រហែលជា

ចុះអាវុធនោះបាញ់ហើយ សុទ្ធតែអ្នកដៃដល់ពួកហ្នឹង សាហាវៗណាស់ តែថាយ៉ាងម៉េចអ៊ីចឹងហើយ។

**ស៖** បាទ សូមអរគុណ លោកសុវណ្ណី។ នៅពេលដែលប្រជាជនត្រូវបានជម្លៀសចេញតាមដងផ្លូវតើរបបខ្មែរក្រហមហ្នឹងមានឲ្យមនុស្សតាមដានប្រជាជននៅពេលធ្វើដំណើរជម្លៀសតាមផ្លូវហ្នឹង ដូចជាការឃ្លាំមើល ការតាមដានឬក៏គ្រប់គ្រងប្រជាជនហ្នឹង ហើយតើមន្ត្រីកម្មាភិបាលខ្មែរក្រហមហ្នឹងបានបង្ខិតបង្ខំ ឬបំភិតបំភ័យប្រជាជនយ៉ាងដូចម្ដេចដែរនៅពេលកំពុងធ្វើដំណើរជម្លៀសតាមដងផ្លូវនោះ?

**ឆ៖** ពេលដែលជម្លៀសចេញទៅនោះ គឺបង្ខំថាឲ្យចេញទៅលឿនៗឡើងទៅប្រយ័ត្នមានអាមេរិកាំងបើកយន្តហោះ ប្រយ័ត្នទម្លាក់អាបេសែងកង់ដឹមកបន្ថែម។ បើមិនអ៊ីចឹងទេ ភ្នំពេញថ្ងៃណាមួយរលាយដោយសារគ្រាប់បែកបរិមាណូ ឲ្យចៀសចេញឆ្ងាយប្រយ័ត្នប៉ះផ្សែងពុលងាប់អស់។ ទៅ បង្ខំឲ្យទៅជួបកន្លែងអង្គការគេហ្នឹង មិនដឹងអង្គការកន្លែងណាចេះតែដេញទៅ ទៅៗ។ បង្ខំឲ្យយើងដើរទៅ។ លុយក៏ចាយមិនបានអីមិនបាន។ មានការដូចថាតាមផ្លូវដោះដូរដូចជាសារុង ខោអាវ អីហ្នឹងដូចជាមាសអីជាប់ខ្លួនដូរជាប៊ីចេង ដូរជាអង្ករអ៊ីចឹង ទៅតាមផ្លូវចែកចាយគ្នាហូបទៅទម្រាំដល់អង្គការគេហ្នឹង។

[១៣:៤២:១៨]

**ស៖** បាទ សូមអរគុណលោក សុវណ្ណី។ នៅពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចាកចេញពីទីក្រុងភ្នំពេញ តើទាហានខ្មែរក្រហម ឬក៏របបខ្មែរក្រហមហ្នឹងបានណែនាំយ៉ាងដូចម្ដេច ឬក៏បានជួយប្រជាជនដែរឬទេ ចំពោះប្រជាជនដែលដូចជាស្ត្រីមានផ្ទៃពោះ កុមារ ជនពិការ ឬក៏ជនមិនអាចដើរទៅធ្វើដំណើរទៅមុខទៀតបានដូចជាជនចាស់ជរាជាដើម។ តើមានវិធានការជួយដល់ពួកគេដែរឬទេនៅក្នុងពេលដែលជម្លៀសនោះបាទ?

**ឆ៖** ពេលដែលជម្លៀសចេញទៅនោះគឺ ពេលដែលអ្នកឈឺស្កាត់ដូចថា មុនដំបូងមានដូចថាយើងជម្លៀសចេញមានពេទ្យមានអីអ៊ីចឹងដែរ គ្នាយើងណ៎ាបាទ។ ដល់ពេលចេញទៅកន្លែងអង្គការគេគឺថាគ្មានថ្នាំសង្កូវទេ មានតែថ្នាំផលិតដោយអាចម៍ទន្សាយថ្នាំអីល្អមៗទៅ សេរ៉ូមអី ឃើញបេះទឹកដូងអីបន្តោងសេរ៉ូម បន្តោងអី ហ្នឹងថ្នាំខាងខ្មែរក្រហម។

[១៣:៤៣:៣៩]

**ស៖** អរគុណលោក សុវណ្ណី។ នៅពេលដែលលោកធ្វើដំណើរដល់គោលដៅចុងក្រោយនៅស្រុកស្អាងតើការរស់នៅរបស់លោក និងប្រជាជន តើលោកបានឃើញទិដ្ឋភាពសោកនាដកម្មអ្វីខ្លះដែលបានកើតឡើងចំពោះប្រជាជននៅទីនោះ? ហើយនៅពេលដែលលោកស្នាក់នៅក្នុងស្រុកស្អាងនោះតើលោក

បានជួបជាមួយមេដឹកនាំខ្មែរក្រហមណាមួយដែរឬទេ? ប្រសិនជាបានជួបគាត់បាននិយាយអ្វីខ្លះប្រាប់លោក ឬក៏ប្រាប់ទៅប្រជាជននៅតំបន់ប្រជាជនបានរស់នៅនោះ?

**ឆ៖** កន្លែងដែលខ្ញុំរស់នៅនោះគឺខ្ញុំមិនបាននេះទេ ព្រោះខ្ញុំធ្លាប់តែទៅធ្វើការបាត់ៗអ៊ីចឹងទៅ មកវិញគឺបើករបបបបរហ្នឹង។ ហើយការដែលការឃើញហ្នឹងគឺវាឃើញថា ដូចថាបណ្តើរ បណ្តើរដូចថាបណ្តើរទៅ សុំស្មើទៅធ្វើចំការធ្វើអីហ្នឹងគឺដឹងថាមិនរស់តែម្តង។ ជីកអន្លង់ខ្លួនឯង ជីកស្រះថាជីកស្រះដាំចម្ការ ធ្វើចម្ការធ្វើអី។ តាមការពិតប្រមូលផ្តុំអ្នករស់ហ្នឹងដែលយកទៅដាក់ក្នុងអន្លង់ ដូចថាប្រមូលអ្នកកម្ពុជាក្រោមយកទៅដាក់ចោលនៅអន្លង់ទៅ។ បណ្តើរទាំងខ្សែៗ បណ្តើរហ្នឹងមិនមែនបណ្តើរទៀតបណ្តើរល្ងាច ប្រហែលជាល្ងាចប្រហែលជាម៉ោងប្រាំមួយ ម៉ោងប្រាំពីរ ព្រលប់ៗហ្នឹង មិនឲ្យយើង បំភ័ន្តយើងមិនឲ្យដឹង។

[១៣:៤៥:១១]

**ស៖** បាទសូមអគុណលោក សុវណ្ណី។ ដោយសារតែខ្ញុំមិនមានពេលវេលាច្រើននឹងការសួរសំណួរលោក អ៊ីចឹងខ្ញុំសូមសួរសំណួរចុងក្រោយតែពីរសំណួរទៀតទេបាទ។ សូមលោកជួយបញ្ជាក់ជូនអង្គសវនាការនៅពេលនេះថា ហេតុអ្វីបានជាលោកធ្វើការរត់ភៀសខ្លួនចេញពីប្រទេសកម្ពុជា ហើយធ្វើដំណើរទៅប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៨បាទ?

**ឆ៖** បាទ ពេលនោះឯង ដោយការឃើញថាថ្ងៃណាមួយ គឺមិន ខ្ញុំក៏ត្រូវនឹងស្លាប់ហើយ ប្រមូលផ្តុំ ព្រោះពេលនោះឯងគឺតំបន់បូព៌ាបែកហើយ។ តំបន់បូព៌ាគេយកទៅសម្លាប់រាល់តែថ្ងៃ ហើយរហូតទៅដល់នេះហ្នឹងគឺថា ពួកយើងមិនរស់ទេនៅតែថ្ងៃគេកម្ទេចចោលទៀត។ ម្ល៉ោះហើយសុខចិត្តបបួលគ្នាទៅរត់ហែលទន្លេទៅឲ្យវៀតណាមជួយ។ ទៅដល់វៀតណាមហ្នឹង ក៏គេជួយដែរ ហែលទឹកទន្លេហ្នឹង។ អ្នកដូចថាអ្នកនេសាទហ្នឹង គេចែវទូកទន្លេហ្នឹង ក៏គេទៅប្រាប់អ្នកដែលយកការណ៍នៅ ដូចថាអ្នកនុំងយកការណ៍ទៅប្រាប់វៀតណាម។ វៀតណាម ក៏យកកប៉ាល់ធំៗមកស្រោចស្រង់។ ហើយក៏ប្រាប់វៀត-ណាមអ៊ីចឹងទៅថា អ៊ូ! ពួក ប៉ុលពត វ៉ៃកាប់សម្លាប់ច្រើនណាស់។ ខ្មែរ និងខ្មែរហ្នឹងវ៉ៃកាប់សម្លាប់នៅមិនបានទេ។ សុំភៀសខ្លួនឲ្យជួយសង្គ្រោះផង។ នៅខ្មែរឃើញតែកាប់សម្លាប់គ្នារាល់តែថ្ងៃទេ។ ហើយកាលនោះមែន ក្បាលជង្គង់ធំជាងក្បាល។

គ្រាន់តែទៅដល់ហ្នឹង ឃើញប្រទេសគេសឹងស្លុតចិត្ត។ ឃើញមានផ្សារ មានអី ឃើញប្រទេសខ្លួនឯង ដូចគ្មានសិរីសួស្តីសោះ។ ឃើញតែថ្ងៃណា ក៏ថ្ងៃទុក្ខព្រួយដែរ ថ្ងៃសម្លាប់។ ហើយបែងចែកដូច

គ្មានសេរីសោះ អត់មាន សូម្បីតែឆ្លងកាត់មួយទៅថ្នល់មួយអត់បាន។ ដឹងតែទៅធ្វើការមកវិញ។ គេហៅថាគុកឥតជញ្ជាំង បង្អត់បាយ១ឲ្យស៊ីបបរ។

[១៣:៤៧:៣៧]

**ស៖** បាទអរគុណលោក សុវណ្ណី។ អ៊ីចឹងបានន័យថា លោកបានធ្វើដំណើរភៀសខ្លួនចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៧ បើតាមឯកសារ។ ហើយអ៊ីចឹងខ្ញុំសូមសួរថា នៅពេលដែលលោកទៅដល់នោះ គឺលោកប្រហែលជាមានសិទ្ធិសេរីភាពក្នុងការនិយាយស្ដី ការដើរហើរ ការហូបចុកគ្រប់គ្រាន់ ហើយផ្ទុយពីអ្វីដែលលោកបានជួបនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺរបបខ្មែរក្រហម។ តើចំណុចនេះលោកយល់ឃើញថា ប្រជាជនខ្មែរនៅក្នុងរបបខ្មែរក្រហម តើគាត់មានសិទ្ធិសេរីភាពដូចលោកដែរឬទេ? ហើយតើអង្គការខ្មែរក្រហមបានគោរពសិទ្ធិសេរីភាព ឬក៏បានផ្ដល់សិទ្ធិសេរីភាពដល់ប្រជាពលរដ្ឋខ្មែរ ឬក៏យ៉ាងណា? សូមលោកជួយបញ្ជាក់ចំណុចនេះ ព្រោះលោកជាសាក្សីដែលបានឃើញផ្ទាល់នឹងភ្នែកនៅក្នុងអង្គហេតុ ឬក៏នៅក្នុងព្រឹត្តិការណ៍ដែលបានជួបកន្លងមកនេះបាទ។ សូមអរគុណ។

**ឆ៖** បាទ គឺគ្មានឲ្យសេរីភាពតែម្ដង អត់មានឲ្យសេរីភាព បើខ្លាចតែកន្លែងមូលដ្ឋានគ្នាមិនដឹងទេ។ បើថាប្រជាពលរដ្ឋ ប្រជាជនដែលជម្លៀសចេញមកដូចថាជារូបខ្ញុំអីអ៊ីចឹង អត់១ គ្មានបណ្ដោយ។ សូម្បីតែឆ្លង មកទៅធ្វើការកន្លែងណា គឺនៅហ្នឹង។ បានមកតាមផ្លូវហ្នឹង លួចកាយដំឡូង កាយអីហ្នឹង។ ដល់តែយប់មិនឲ្យ ស៊ីអត់ឲ្យគេឃើញទៀត។ ដល់គេឃើញ គេថាយើងស៊ីក្បត់សមូហភាព។ មិត្តឯងហ្នឹងគឺថា ហូបចុកហ្នឹងអត់ ក្បត់សមូហភាពទេ គ្មាននេះទេ។ បើឃើញទៀត សូម្បីតែឧបមាថា បបរ១ បេះត្រកួន បេះព្រលឹត បេះអីហ្នឹងយកមកដាក់នៅក្នុងកាម៉ែលហ្នឹង បន្ថែមហ្នឹងក៏វាទាត់ដែរ ទាត់ចោល។ ព្រោះអាល្អបហ្នឹង កូនកម្មាភិបាលហ្នឹង។ អាយុពីរបីដណ្ដប់នោះស្ពាយកាំភ្លើងអូសដីហ្នឹង។

[១៣:៤៩:៣៦]

ហើយម្ល៉ោះហើយនឹកឃើញថា ដល់តែពេលរត់ទៅដល់វៀតណាមហ្នឹង ឃើញគេហ្នឹងគេសេរីភាពគ្រាន់តែ គុយទាវ ខ្ញុំហូបបីចានអត់ឆ្អែតទេ។ ទៅដល់ឃើញគេមានផ្សារ មានអីហ្នឹងដូចរំភើបចិត្តខ្លួនខ្ញុំនឹកឃើញថា អូ៎! ម៉េចប្រទេសគេ គេអត់អ៊ីចឹង។ ចុះប្រទេសខ្មែរម៉េចក៏កម្មអីអាក្រក់ម្ល៉ោះកាលនុ៎ង។ ឃើញតែថ្ងៃណាក៏ថ្ងៃសម្លាប់ ថ្ងៃណាក៏ថ្ងៃឲ្យគ្នាទៅធ្វើការគ្មានទីផ្សារ គ្មានស្អីសោះ គ្មានទំនែកអីលក់សោះ។ វាទៅជាអ៊ីចឹងទៅវិញ។ ហើយមុនដំបូងហ្នឹងរំដោះ ខំមកនាំគ្នាទះដៃអបអរសាទរ អូ៎! ឯករាជ្យហើយ ប្រទេសខ្មែរយើងឯករាជ្យហើយ ឈប់ចម្បាំងឈប់អីហើយ។ ដល់ទៅជាអ៊ីចឹង ហួស

ចិត្តមែនទែន ខ្ញុំសឹងថាសព្វថ្ងៃហ្នឹងមិនដូចរបបនោះ ដូចរបបព្រៃផ្សៃ ដូចជាប់គុក ដូចថាគុកជញ្ជាំង។ គុកនោះគឺគុកអង្គត់បាយតែម្តង ឱ្យស៊ីបបេរមួយគ្រាប់ៗ បបរឃើញមួយគ្រាប់ៗ ដូចថាអ៊ីចឹង ថាបេះបន្លែយកមកលាយទៅ វាឃើញមិនបាន ឃើញយើងលាយបន្លែលាយអីទាត់ខ្លាយអស់។ ហើយប៊ានមិនបានទេ សូម្បីតែផ្លែស្វាយមួយ ខ្ញុំបេះសឹងអស់អាយុជីវិត កុំឱ្យតាៗហ្នឹងអង្វរករខ្លាំងទេ កុំអីហ្នឹងខ្ញុំស្លាប់ហ្នឹងហើយ។ ផ្លែស្វាយមួយ ថាមិត្តឯងក្បត់សមូហភាព បេះគ្មានប្រាប់អង្គការទេ។ បេះយកស៊ីក្បត់សមូហភាព មិត្តឯងនេះ ហៅខ្ញុំ -- ហើយខ្ញុំអាក្មេងល្អិត ស្លាយកាំភ្លើងនរណាទៅប៊ាននឹងវា។ ស៊ីក្បត់សមូហភាព បាញ់មិត្តឯងចោលឥឡូវ ដូចឆ្កែឥឡូវហ្នឹង។ ហួសចិត្ត។

[១៣:៥១:៣៣]

**លោក ច័ន្ទ តារាស្មី៖**

បាទ ខ្ញុំសូមអរគុណលោក សុវណ្ណី។ ក្នុងនាមសហព្រះរាជអាជ្ញា ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកដែលបានឆ្លើយបំភ្លឺសំណួររបស់ខ្ញុំនៅពេលនេះ ហើយខ្ញុំសង្ឃឹមថាសំណួររបស់ -- ចម្លើយរបស់លោកគឺពិតអាចចូលរួមចំណែកក្នុងការស្វែងរកការពិត និងយុត្តិធម៌នៅក្នុងសំណុំរឿងក្តីដែលកំពុងដំណើរការសវនាការនៅពេលនេះ។ ហើយសូមជូនពរឱ្យលោកជួបតែសំណាងល្អ និងទទួលជោគជ័យក្នុងជីវិត ក៏ដូចជាការងារ។ សូមអរគុណលោក សុវណ្ណី។

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរនៅពេលនេះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១៣:៥២:១០]

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន! មេធាវីរបស់លោក នួនជា មិនមានសំណួរទេល្ងាចនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រមទាំងអស់ជាទីគោរព ភាគីទាំងអស់ជាទីគោរព ហើយនិងលោកដើមបណ្តឹងរដ្ឋប្បវេណីជាទីគោរព។ ខ្ញុំឈ្មោះ អត់តា ហ្គីសសេ ជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ហើយខ្ញុំនឹងចោទសំណួរទៅកាន់លោកមួយចំនួន ដោយសំណួរបន្តិចបន្តួចនោះទេ ពីព្រោះថាយើងពុំមានពេលវេលាច្រើន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** នៅក្នុងចម្លើយរបស់លោក ការឆ្លើយរបស់លោកនេះ គឺថានៅថ្ងៃទី១៧ មេសា ៧៥ នៅពេលដែលលោកត្រូវបានគេឲ្យចេញពីផ្ទះនោះ កាលនោះលោកនៅជាមួយបងស្រីរបស់លោក។ ហើយលោកបានពន្យល់ថាឪពុកម្តាយរបស់លោកហើយនិងបងប្អូនស្រីរបស់លោកបានចាកចេញពីផ្ទះ១អាទិត្យមុនពេលហ្នឹង។ តើពិតជាត្រឹមត្រូវដែរឬទេ? ខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ?

[១៣:៥៣:៤០]

**លោក សឿន សុវណ្ណី៖**

**ឆ៖** បាទគឺពេលដែលជម្លៀសចេញនោះ គឺពិតមែនតែអ៊ីចឹងមែន។ តែបានជាខ្ញុំជម្រាបលើនៅខាងដើមហើយ។

**ស៖** បើខ្ញុំសូមបញ្ជាក់ថា ខ្ញុំសូមឲ្យបំភ្លឺនេះ ពីព្រោះថានៅក្នុងចម្លើយ គឺថានៅក្នុងទម្រង់បែបបទដែលលោកបានបំពេញនេះ ដែលមានលេខកូដជាភាសាអង់គ្លេសគឺ ERN គឺថាឯកសារ D22/2745a ហើយជាភាសាខ្មែរគឺអត់មាន “a” នៅចុងទេ។ លេខ ERN គឺអង់គ្លេសគឺថា 00556030, ជាភាសាខ្មែរគឺ 00556039, ហើយនិងទំព័របន្ទាប់ទៀត។

ការសុំបំភ្លឺរបស់ខ្ញុំគឺមកពី នៅពេលដែលយើងអានទម្រង់បែបបទទី១របស់លោកនេះ យើងយល់ថា ក្រុមគ្រួសាររបស់លោកចាកចេញពីលំនៅដ្ឋានក្នុងថ្ងៃជាមួយគ្នា។ ហើយខ្ញុំបានអានផងដែរថា លោកបានផ្តល់ព័ត៌មានបន្ថែមទៀតនៅក្នុងទម្រង់បែបបទនោះ ហើយដែលនៅក្នុងនោះលោកបានកែតម្រូវគឺឯកសារ ERN ជាភាសាបារាំង គឺ 00909167 ហើយនិងភាសាខ្មែរគឺ 00576163, ជាភាសាអង់គ្លេសគឺ 00865120។ នៅក្នុងឯកសារបន្ថែមនេះព័ត៌មានបន្ថែមនេះគឺលោកបានប្រាប់ថា “នៅពេលខ្មែរក្រហមចូលមកក្នុង៧៥ ខ្ញុំនៅជាមួយបងប្អូនស្រីរបស់ខ្ញុំ ហើយនិងផ្លូវសម្តេចប៉ុន”។ បញ្ហាដែលខ្ញុំមិនយល់នេះ ខ្ញុំ

ចង់ -- ព្រោះថានៅក្នុងទម្រង់បែបបទទី១ លោកបានឆ្លើយរៀបរាប់ព័ត៌មានដូចតទៅនេះ -- អង្គហេតុដូចតទៅនេះ ដោយនិយាយថា លោកត្រូវបានបំបែកពីគ្រួសារ គឺថាពីបងស្រីនោះនៅតាមផ្លូវ។ អ៊ីចឹងសំណួរខ្ញុំៗចង់ដឹងថា តើនៅពេលណាលោកត្រូវបានបំបែកពីក្រុមគ្រួសាររបស់លោក គឺនៅតាមផ្លូវ ឬក៏ឪពុកម្ដាយរបស់លោកនោះបានចាកចេញតាំងពីមុនថ្ងៃ១៧ មេសា នុ៎ងទៅទៀត?

[១៣:៥៧:០៧]

**ឆ៖** បាទ ដែលគាត់ចេញហ្នឹង ចេញមុន១អាទិត្យ បានដែលខ្ញុំចេញទៅតាមក្រោយគាត់ហ្នឹងបានកើតជាបែកបាក់។ ហើយសូមទៅ ដែលថាចេញទៅតាមជាមួយបងស្រីនោះ គឺទៅដល់កន្លែងអង្គការគេក៏បែកពីបងស្រីទៅទៀត គាត់នៅកងចល័ត។ ខ្ញុំនៅកងយុវជន កង គេហៅថា “កងកញ្ចុះ”។

**ស៖** សំណួរខ្ញុំច្បាស់លាស់ អ៊ីចឹងបើសិនជាឪពុកម្ដាយរបស់លោកចាកចេញ១អាទិត្យមុនថ្ងៃទី១៧ មេសា តើហេតុអីបានគាត់ចាកចេញតាំងពី១អាទិត្យមុនហ្នឹង តើគាត់ត្រូវបានគេបង្ខំ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គេបង្ខំចេញ។ គាត់បង្ខំចេញហ្នឹង គាត់ថាចេញហ្នឹងគឺថាគេរៀបចំទេ គ្រាន់តែថាឥឡូវគឺរៀបចំ គេហៅថាគ្រាន់តែឲ្យចេញមួយរយៈទេ គេមិនមែនដេញទៅឲ្យនេះទេ គេចាំរៀបចំភ្នំពេញហើយកន្លះខែ ឬមួយទៅមួយខែអីបានគេឲ្យវិលចូលមកវិញ។ បានកើតឲ្យខ្ញុំចាំនៅចាំក្នុងផ្ទះ នៅចាំផ្ទះជាមួយបងស្រី។ ដល់តែក្រោយពីហ្នឹងទៅទៀតបានគេដេញចេញទៅផ្ដាច់ អ្នកណាមិនចេញគឺមិនបានត្រូវស្លាប់នៅអាមេរិកាំងទម្លាក់គ្រាប់បែកបរមាណូ។

[១៣:៥៨:៥៦]

**ស៖** ក៏ប៉ុន្តែមួយសប្ដាហ៍មុនថ្ងៃទី១៧ មេសា នោះខ្មែរក្រហមមិនទាន់ចូលមកដល់ភ្នំពេញនោះទេ អ៊ីចឹងខ្ញុំចង់ដឹងថា អ្នកណាអ្នកបង្ខំឪពុកម្ដាយលោកឲ្យចេញពីលំនៅដ្ឋាននៅពេលហ្នឹង ពីព្រោះលោកបាននិយាយថា គាត់ចាកចេញមួយអាទិត្យមុនពេលថ្ងៃ១៧ មេសា។ អ៊ីចឹងខ្ញុំចង់ដឹងថា អ្នកណាបង្ខំឲ្យពួកគាត់ចាកចេញពីទីក្រុងភ្នំពេញ?

**ឆ៖** បាទអ៊ីចេះ ខ្ញុំនិយាយហ្នឹងនិយាយពីអង្កាល់ដែលរំដោះបានហើយទេ រំដោះបានចូលទៅដល់ភ្នំពេញហើយទេ មិនមែនថាៗនិយាយដល់ថ្ងៃណោះមិនទាន់ខ្មែរក្រហមចូលដល់ភ្នំពេញទេ។ ចូលដល់ភ្នំពេញហើយ បានកើតជាជម្លៀស បណ្ដេញចេញពីទីក្រុងភ្នំពេញទៅ។ មិនមែនខ្ញុំនិយាយថាថ្ងៃនេះទេ ថ្ងៃនុ៎ងគឺថ្ងៃដែលគេដេញចេញតែម្ដង។ បានកើតទៅជាឲ្យចេញមុនក្រោយនោះ គ្រាន់តែថារៀបចេញមួយរយៈទេ។ គ្រាន់ថា ឲ្យចេញមួយរយៈសិនទៅ បើគេរៀបចំភ្នំពេញហើយបាន គេឲ្យចូលវិលត្រឡប់

មកភ្នំពេញវិញ។ បានកើតឲ្យចាំផ្ទះខ្លះ ចេញទៅខ្លះ បណ្តោះគ្នាចេញទៅ។ មិនដឹងថាវាចេញទៅឲ្យស្ងាត់ឯណា អត់ដឹង។ ហើយថ្ងៃទីប៉ុន្មានៗ គឺខ្ញុំមិនចាំទេ ព្រោះថ្ងៃនោះខ្ញុំដឹងថាខ្មែរក្រហមចូលព្រាតហើយ។ អ្ហូ! ពេញតែភ្នំពេញ។ អ្នកខ្លះហ្នឹងមិនចេះជិះម៉ូតូផងយកម៉ូតូជិះដួលពព្រឹសពព្រូស ហើយនិយាយពីសៀតប៊ិកហ្នឹង អត់ចេះអក្សរទេ ប៉ុន្តែគេសៀតប៊ិកហ្នឹងពេញតែហោប៉ៅហើយ។ គេថាឯហ្នឹងកម្មាភិបាលដែរ ហើយដែលបង្រៀនចេះជិះម៉ូតូ កាលហ្នឹងម៉ូតូនេះហ្នឹងជិះដួលពេញតែផ្លូវហ្នឹង។ ហើយមួយថ្ងៃៗនិយាយពីដឹកៗ អីវ៉ែអីវ៉ាន់សម្ភារៈចេញពីភ្នំពេញ អាហ្នឹងខ្ញុំនៅទាន់ ៗឃើញ។

[១៤:០១:០៤]

ខ្ញុំនិយាយហ្នឹងនិយាយពេលដែលចូលដល់ទេ ខ្ញុំអត់បានថាថ្ងៃណាៗទេ ព្រោះថ្ងៃនុ៎ងនិយាយពេលដែលមើលឃើញខ្មែរក្រហមចូលដល់ ដេញចេញពីភ្នំពេញប៉ុណ្ណឹង។ ថ្ងៃណាៗខ្ញុំអត់បានចងចាំ ឥឡូវបាត់ការចងចាំច្រើនផង។

**ស៖** មានចំណុចមួយដែលខ្ញុំយល់មិនច្បាស់។ ខ្ញុំសូមអភ័យទោស ដោយសារការបកប្រែមិនទាន់បានចប់សព្វគ្រប់អម្បាញ់មិញ។ លោកមិនចាំកាលបរិច្ឆេទច្បាស់លាស់ ប៉ុន្តែតាំងពីព្រឹកមិញមកនោះមានការ -- គេចោទសំណួរទៅកាន់លោក -- ចោទសួរទៅលោកនោះដោយនិយាយ គឺថ្ងៃ១៧ មេសា អ៊ីចឹងតើខ្ញុំអាចនិយាយបានថា លោក ហើយនិងបងប្អូនលោកទាំងអស់នោះ ហើយរួមទាំងលោកផងដែរ បានចាកចេញពីទីក្រុងភ្នំពេញមុនថ្ងៃទី១៧ មេសា ហ្នឹង១សប្តាហ៍ ខ្ញុំត្រូវយល់យ៉ាងដូច្នេះ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំនិយាយនេះ និយាយពីអង្កាល់ដែលថ្ងៃណាចេះ ថ្ងៃរំដោះហ្នឹងតែម្តង។ ថ្ងៃរំដោះពីរបីថ្ងៃហ្នឹង គឺដេញចេញ ប្រជាជនចេញពីភ្នំពេញហើយ។ ហើយដេញចេញហ្នឹង គឺមើលឃើញថា គ្រាន់តែឲ្យចេញមួយរយៈទេ មិនមែនគ្រាន់ថាដេញឲ្យផុតពីនេះទេ គ្រាន់តែចេញទៅមួយរយៈទេ។ គេរៀបចំភ្នំពេញបានហើយ បានគេឲ្យចូល។ អ៊ីចឹងបានជាកើតចេញពីខ្លះនៅខ្លះហ្នឹង។ ដល់ចុងក្រោយ ១សប្តាហ៍ក្រោយបានជាចេញទៅបង្ហើយ បើថាមិនបានទេ នៅមិនបានទេ បើសិនជានៅទៀតអាមេរិកាំងច្បាស់ជាទម្លាក់គ្រាប់បែកបរិមាណូហើយនៅមិនបានត្រូវចេញឲ្យអស់។ បានកើតជាចេញទៅ។

[១៤:០៣:១៦]

**ស៖** ខ្ញុំយល់ច្បាស់ហើយ ក៏ប៉ុន្តែបញ្ហា គឺថាខ្ញុំចង់កំណត់កាលបរិច្ឆេទពេលដែលលោកចាកចេញពីភ្នំពេញ ហើយនិងពេលដែលឪពុកម្តាយរបស់លោកចេញពីក្រុងភ្នំពេញ។ លោកបាននិយាយថា

ឪពុកម្តាយលោកបានចាកចេញ១អាទិត្យមុនលោក។ ជួន -- លទ្ធភាព គឺថា ជួនគឺថាគាត់ចេញមុនពេលខ្មែរក្រហម ថ្ងៃទី១៧ មេសានេះ ១សប្តាហ៍ ជួនឬលោកចេញពីក្រុងភ្នំពេញមួយសប្តាហ៍ក្រោយបន្ទាប់ពីថ្ងៃទី១៧ មេសា។ អ៊ីចឹងខ្ញុំដឹងថាវាមានកាលបរិច្ឆេទពីរខុសគ្នា អ្វីដែលខ្ញុំចង់ដឹងនោះ គឺថាតើលោកចង់នៅ -- លោកបានស្នាក់នៅទីក្រុងភ្នំពេញរហូតដល់១អាទិត្យ ក្រោយពេលដែលខ្មែរក្រហមបានចូលរំដោះហើយនេះ។ អ៊ីចឹងមែនទេ?

[១៤:០៤:១២]

**ឆ៖** បាទ អ៊ីចឹងមែន។ ដូចខ្ញុំរាយរាប់ខាងដើមអ៊ីចឹង។ និយាយហ្នឹង និយាយទៅនិយាយមកដូចនិយាយដដែលៗ។ ពេលដែល ពេលនោះដែលខ្ញុំមិនបានចាំថ្ងៃចាំអីទេ ពីនោះរហូតមកដល់ឥឡូវប៉ុន្មានឆ្នាំមកហើយ។ ពីខ្ញុំអាយុ១៧ឆ្នាំ មកដល់ឆ្នាំនេះខ្ញុំ៥៧, ៥៨ហើយ វាបាត់ការចងចាំច្រើន ហើយម្យ៉ាងទៀតកាលសឹកសង្គ្រាមហ្នឹង គឺថាច្រើនណាស់ ម្សេវ គឺថាសឹងពេញខួរក្បាលហើយ ធ្វើទាហានហ្នឹងខាងណេះបន្តិច ខាងណោះបន្តិច វាមិនច្បាស់។ អាហ្នឹងដោយមូលហេតុបែកបាក់បងប្អូនដើររក។ នៅខាងនោះរហូតដល់ទៅចេញទៅជំរំ ទៅរកបងប្អូនទៅដល់កន្លែងជំរំនុ៎ងទៀតក៏មិនឃើញទៀត ហើយជ្រាលទៅដល់ទៅធ្វើ ហេតុតែធ្លាប់តែនិស្ស័យធ្វើទាហានពី លន់ នល់ ទៅចង់ធ្វើទាហានប៉ាវ៉ាទៀត ដើម្បីចង់ដឹងមើលតើអ្នកណាធ្វើឲ្យខ្មែរហ្នឹងបែកបាក់គ្នា។ ទៅរកមិនឃើញរហូតដល់សព្វបងប្អូនខ្ញុំម្នាក់សោះអស់រលីង។ ស្រាវជ្រាវតាមកាកបាទក្រហមទៅបរទេសក៏ឃើញទៀត ដល់ជំរំ។

**ស៖** ដើម្បីឲ្យច្បាស់លាស់បំផុត នេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយ ខ្ញុំចង់បំភ្លឺចំណុចហ្នឹង។ តើខ្ញុំត្រូវយល់ថា លោកបាននៅក្នុងផ្ទះរបស់លោកក្រោយពេលដែលខ្មែរក្រហម ដែលលោកបានពណ៌នាកាលព្រឹកមិញនេះ ដែលពួកគេបានបញ្ជាឲ្យលោកចេញពីទីក្រុងភ្នំពេញ។ អ៊ីចឹងទោះបីជាគេបញ្ជាឲ្យលោកចាកចេញពីទីក្រុងភ្នំពេញក៏ដោយ ក៏លោកនៅតែនៅទីក្រុងភ្នំពេញរហូតដល់១សប្តាហ៍ទៀត។ តើអ៊ីចឹងមែនទេ?

[១៤:០៦:៣១]

**ឆ៖** បាទ ពិតមែន។ បានវាបង្ខំ គំរាមមែនទែនទៅ អាហ្នឹងគំរាមខ្លាំងមែនទែន។ ចុះឃើញៗដែរ ឃើញវាបាញ់ចូលផ្ទះចូលអី បាញ់កម្ទា ក្នុងក្លាំងពេញតែហ្នឹងឯង បានសុខចិត្តចេញ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមានការអីទៅលោកមេធាវី?

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខ្ញុំជឿថា -- ខ្ញុំគិតថាសំណួរនឹងចម្លើយមិនត្រូវគ្នាទេ។ បើខ្ញុំស្ដាប់ជាភាសាបារាំងនិយាយថា ក្នុងរយៈពេល១អាទិត្យចុងក្រោយហ្នឹង គឺលោកដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែនៅជាមួយនឹងគ្រួសាររបស់គាត់នៅភ្នំពេញ ឬយ៉ាងដូចម្ដេច? ក៏ប៉ុន្តែនៅពេលដែលបកប្រែជាខ្មែរថា លោកដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែនៅក្នុងភ្នំពេញ ឬយ៉ាងដូចម្ដេច? អ៊ីចឹងបាត់ពាក្យមួយដែលត្រូវមានបន្តទៀត ដែលថាគាត់នៅក្នុងភ្នំពេញជាមួយក្រុមគ្រួសាររបស់គាត់ ឬយ៉ាងណា។ ដូច្នេះធ្វើឲ្យចម្លើយរបស់គាត់ខុសអំពីសំណួររបស់លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ អ៊ីចឹងសូមឲ្យ -- សូមទោស -- សូមឲ្យលោកស្រីមេធាវីសួរសំណួរហ្នឹងម្ដងទៀត ដើម្បីឲ្យគាត់ឆ្លើយ។ សូមអរគុណលោកប្រធាន។

[១៤:០៨:១១]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនដឹងថាគេបកប្រែជាភាសាខ្មែរយ៉ាងម៉េចនោះទេ ប៉ុន្តែជាភាសាបារាំងនោះ ខ្ញុំមិននិយាយដូចលោកនិយាយអំមិញនោះទេ។ ព្រោះខ្ញុំស្ដាប់ទៅជាភាសាបារាំងនោះ គឺថាវាអត់ដូចអ្វីដែលខ្ញុំនិយាយទេ។ ឥឡូវនេះខ្ញុំនឹងបំភ្លឺចំណុចនេះឡើងវិញ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃនេះនៅក្នុងសវនាការលោកបាននិយាយថា ឪពុកម្ដាយរបស់លោក ហើយនិងបងប្អូនប្រុសស្រីរបស់លោកបានចាកចេញពីផ្ទះលោក១អាទិត្យ មុនពេលដែលលោកចេញពីគេហដ្ឋានរបស់លោកគឺចេញពីភ្នំពេញនោះ។ តើខ្ញុំពិតជាយល់ត្រឹមត្រូវទេ ឥឡូវយើងធ្វើបោះទៅមុខមួយជំហាន១ម្ដង? អ៊ីចឹងខ្ញុំចង់ដឹងថាតើឪពុកម្ដាយរបស់លោកនោះ បានចាកចេញពីភ្នំពេញមុនលោក១សប្ដាហ៍ មែនទេ?

**លោក សឿង សុវណ្ណី៖**

**ឆ៖** បាទ ពិតមែន។

**ស៖** តើនៅថាថ្ងៃដែលគាត់ចាកចេញហ្នឹង ត្រូវនឹងថ្ងៃដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺពិតមែន។

[១៤:០៩:៣៣]

**សៈ** បើអ៊ីចឹងលោក ដោយសារលោកចាកចេញក្រោយឪពុកម្ដាយរបស់លោក១សប្ដាហ៍ក្រោយ អ៊ីចឹងយើងអាចនិយាយបានដែរឬទេថា លោកបានចាកចេញពីទីក្រុងភ្នំពេញ១សប្ដាហ៍ក្រោយថ្ងៃដែលខ្មែរក្រហមចូលក្នុងក្រុងភ្នំពេញ។ អ៊ីចឹងមែនទេ?

**ឆះ** បាទ ព្រោះវានិយាយថាដែលឲ្យចេញមួយរយៈនោះ ឲ្យចេញមួយរយៈសិន ចាំគេរៀបចំភ្នំពេញវិញបានឲ្យចូល។ បានកើតជាចេញពីរ១ដង ឲ្យខ្ញុំពីរនាក់បងខ្ញុំចាំផ្ទះសិន ឲ្យគាត់ចេញទៅមុន។ ក្រែងលោគេរៀបចំភ្នំពេញហើយ បានគាត់ចូលមកវិញ។ មិនដឹងតើវាដេញទៅរហូតឯណា បានកើតជាបែកគ្នាហ្នឹង។ ដល់គំរាមមែនទែនបានចេញអស់ពីផ្ទះ ចេញពី -- មិនចេញត្រឹមតែផ្ទះខ្ញុំ ចេញមួយទីក្រុងភ្នំពេញចេញទៅទាំងអស់។ បើមិនចេញគឺបាញ់ចោល។ បាញ់ងាប់នៅហ្នឹង ងាប់តាមផ្ទះ ធ្វើដំណើរតាមផ្លូវមក ឃើញខ្លះងាប់លើផ្ទះលើអី ដោយសារស្ដោយរបស់ទ្រព្យ ហើយដូចថា និយាយតមាត់ ត-កអីខ្លះទៅ បាញ់ហើយ ព្រោះគេហ្នឹង គេអ្នកដាច់ខាត។ អាវុធនឹងដៃ សុទ្ធតែពួកកងសាហាវ។

**សៈ** ចន្លោះពេលរំដោះ ហើយនិងពេលដែលឪពុកម្ដាយចាកចេញផ្ទះ ហើយនិងពេលដែលលោកចាកចេញពីផ្ទះដែរ ជាមួយនឹងបងស្រីរបស់លោក។ អ៊ីចឹងគឺថាបើខ្ញុំមិនច្រឡំទេ គឺចន្លោះពេលហ្នឹងគឺថាលោកនៅក្នុងផ្ទះលោករហូត លោកមិនបានចាកចេញទៅណាទេ។ អ៊ីចឹងមែនទេ? ឬក៏លោកបានចាកចេញពីផ្ទះដែរពេល១សប្ដាហ៍ហ្នឹង?

[១៤:១១:៣១]

**ឆះ** ចេញ និយាយមិនចេញម៉េច បើមិនចេញវាសម្លាប់នៅនឹងផ្ទះ ព្រោះវានិយាយ វានិយាយហើយ បើថាបើមិនចេញទេ ប្រយ័ត្នងាប់នៅនឹងភ្នំពេញហ្នឹងហើយ។ ព្រោះអាមេរិកាំងវាធ្វើការបើកកប៉ាល់ហោះទម្លាក់គ្រាប់បែក បើមិនចេញមិនបានទេ ត្រូវចេញឲ្យអស់។ ហើយថ្ងៃខ្លះឮសូរក្តុងក្តាំងៗបាញ់ប៉ភីសប៉ភូសៗពេញហ្នឹង មិនដឹងជាបាញ់ស្អី ក៏បបួលគ្នាចេញទៅរកទៅ ហើយឪម៉ែ -- ឪខ្ញុំហ្នឹងមុននឹងគាត់ចេញទៅ បើថាៗចេញទៅ ទៅរកគាត់តាមមាត់ទន្លេ។ ឲ្យចេញទៅមុន ចេញមុនក្រោយរកតាមៗមាត់ទន្លេទៅឃើញគាត់ហើយ។ ដល់ទៅហ្នឹង ទៅអត់ឃើញ មិនដឹងនយោបាយគេប្រើឲ្យបំភាន់ឲ្យមកថាទទួលសម្ដេច នៅត្រង់នេះត្រង់នោះអី បានគាត់វិលចូលភ្នំពេញវិញ។ ក៏មិនដឹងស្លាប់ត្រង់ណាអីត្រង់ណា ខ្ញុំអត់បានឃើញដែរ។

**សៈ** ខ្ញុំមិនដឹងថា មានបញ្ហាបកប្រែ ឬក៏យ៉ាងណាទេ។ ក៏ប៉ុន្តែសំណួរអម្បាញ់មិញនេះ គឺខ្ញុំចង់ដឹងថា ចន្លោះពេលដែលឪពុកម្ដាយរបស់លោកចេញពីទីក្រុងភ្នំពេញនៅថ្ងៃរំដោះ ហើយនិងពេលដែល

លោកចេញ បើតាមចម្លើយរបស់លោក គឺថាលោកចេញ១សប្តាហ៍ក្រោយហើយទេ។ តើក្នុងចន្លោះពេល១សប្តាហ៍ហ្នឹង លោកនៅក្នុងផ្ទះហ្នឹងរហូត ឬក៏លោកបានដើរទៅក្រៅខ្លះដែរ?

[១៤:១៣:១១]

**ឆ៖** បាទ ខ្ញុំចេញ ជម្លៀសចេញទៅរកគាត់ហ្នឹងហើយ។ ទៅរកៗតាមដងមាត់ទន្លេរហូតដល់ស្ពានព្រែកតូច កោះធំ។

**ប្រធានអង្គជំនុំ៖**

សំណួរអ៊ីចេះ ណោះ លោក សុវណ្ណី! សំណួរសួរថា ចាប់ពីថ្ងៃដែលឪពុកម្តាយគ្រួសាររបស់លោកចាកចេញទៅ លោកបាននៅទីក្រុងភ្នំពេញ គឺនៅនឹងផ្ទះនោះ១សប្តាហ៍ក្រោយ ទើបលោកចាកចេញទៅ។ សំណួរសួរថា ក្នុងចន្លោះដែលលោកនៅនឹងផ្ទះនេះ ចាប់ពីឪពុកម្តាយចាកចេញទៅរហូតដល់ពេលថ្ងៃដែលត្រូវលោកចាកចេញទៅ ដែលលោកនៅនឹងផ្ទះ តើលោកមានចាកចេញក្រៅពីផ្ទះរបស់លោកដែលរស់នៅហ្នឹងដែរឬទេ?

**លោក សឿង សុវណ្ណី៖**

**ឆ៖** ពេលដែលក្រោយសប្តាហ៍ដែលម្តាយឪពុកដែលចេញទៅហ្នឹង គឺថាបានដើរមើលក្បែរៗជិតខាងហ្នឹង គឺបានដើរៗមើលទិដ្ឋភាពដែរ ទៅឃើញគេដឹកអីវ៉ាន់អីវ៉ាន់ពេញតែទីក្រុងភ្នំពេញហ្នឹងឯង មិនដឹងជាដឹកស្អីៗទេ ចេញទៅ គេរៀបចំភ្នំពេញមែន។ បានកើតជាភ័យខ្លាចគេបាញ់សម្លាប់ហ្នឹង ក៏ចេញទៅតាមគាត់ទៅ។

[១៤:១៥:០១]

**កញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណីអ្វីដែលខ្ញុំចង់ដឹងនោះ គឺថាអ្វីដែលលោកបានឃើញថាខ្មែរក្រហមបាញ់ឡើងលើ ហើយឲ្យប្រជាជនចាកចេញ កាលនោះគឺថានៅថ្ងៃរំដោះទេ គឺថាពេលថ្ងៃដែលឪពុកម្តាយរបស់លោកចាកចេញពីភ្នំពេញ។ លោកឃើញគេបាញ់ឡើងលើមេឃលើអីហ្នឹងនៅពេលដែលឪពុកម្តាយលោកចាកចេញពីភ្នំពេញ ឬក៏១សប្តាហ៍ក្រោយមកទេ។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅថ្ងៃ១៧ មេសានៅថ្ងៃដែលឪពុកម្តាយលោកចាកចេញពីទីក្រុងភ្នំពេញហ្នឹងលោកឃើញអ៊ីចឹងដែរ ហើយពេលដែលលោកចេញ១សប្តាហ៍ក្រោយមក ក៏លោកឃើញគេបាញ់ឡើងលើមេឃឡើងអ៊ីចឹងដែរដើម្បី គំរាមឲ្យប្រជាជនចេញពីទីក្រុងភ្នំពេញ។

**ឆ៖** បាទ ឃើញពិតអ៊ីចឹង ឃើញអ៊ីចឹងមែន ឃើញគេគំរាមអ៊ីចឹង គេគំរាមថា គេបាញ់ហ្នឹងគឺសម្រាប់ឲ្យបង្អើលប្រជាជនដើម្បីឲ្យចេញ ដើម្បីគេរៀបចំភ្នំពេញ។ បានខ្ញុំហ្នឹងលាចាកចេញទៅរកឪពុកម្ដាយដែលចេញទៅមុននឹងតាមផ្លូវដងទន្លេហ្នឹង។

**ស៖** ខ្ញុំសូមសាកល្បងលើកចុងក្រោយហើយ។ តើថ្ងៃដែលលោកចាកចេញគឺថា១សប្ដាហ៍ក្រោយពេលដែលឪពុកម្ដាយរបស់លោកចាកចេញនោះ អ៊ីចឹងតើ១អាទិត្យក្រោយនោះ ខ្ញុំចង់ដឹងថាតើមានមនុស្សអ្នកទីក្រុងភ្នំពេញហ្នឹងចាកចេញ កំពុងតែចេញពីទីក្រុងភ្នំពេញដែរឬទេ ឬក៏មានតែលោក ហើយនិងបងស្រីលោកទេ ១សប្ដាហ៍ក្រោយពីខ្មែរក្រហមចូលមកក្រុងភ្នំពេញនេះ?

[១៤:១៧:០៣]

**ឆ៖** បាទ ឃើញៗចេញទៅជាបន្តបន្ទាប់តាមគ្នា គរទៅតាមរហូតតាមដងផ្លូវ ផ្លូវណាក៏មានដែរ ផ្លូវជាតិ ខ្ញុំជម្លៀសចេញហ្នឹងចេញផ្លូវជាតិលេខ១ ក្បាលថ្នល់ ច្បារអំពៅហ្នឹង។ មនុស្សឲ្យកុះករចង្អៀតណែនណាន់តាន់តាប់ហ្នឹងតាមផ្លូវហ្នឹងរហូតចេញជាបន្តបន្ទាប់ហ្នឹង ខ្លះរែក ខ្លះទូល បណ្ដើរកង់បណ្ដើរនេះទៅ មានម៉ូតូជិះម៉ូតូទៅ ណែនណាន់តាន់តាប់តាមផ្លូវហ្នឹងរហូត។

**ស៖** ដើម្បីឲ្យច្បាស់លាស់នោះគឺថា អ្វីដែលលោកបានរៀបរាប់នោះគឺថា គឺថ្ងៃដែលលោកចេញជាមួយបងស្រីរបស់លោកអ៊ីចឹងមែនទេ ថា១សប្ដាហ៍ក្រោយហើយទេ ដើម្បីឲ្យច្បាស់ទាំងអស់គ្នា?

**ឆ៖** បាទ ឃើញចេញទៅទាំងអស់គ្នាហ្នឹង ហើយបើមិនចេញទៅម៉េចកើត នៅម៉េចកើតបើវាដេញហើយមិនទៅម៉េចកើត។ ហើយប្រជាជនហ្នឹងដូចជម្រាបប្រាប់ ចេញជម្លៀសដូចបានឃើញហើយខ្លះទូល ខ្លះរែក ខ្លះអីហ្នឹង។ ដូចខ្ញុំជម្រាបខាងដើម ដល់សួរអ៊ីចឹងខ្ញុំលែងចង់ដឹងឆ្លើយ។ វាមានចេញមុនក្រោយៗ។ ឧបមាថា មានគេនិយាយថាឲ្យចេញមួយរយៈ វាមានមុនក្រោយអ៊ីចឹងណា ខ្លះចេញទៅមុនខ្លះចេញទៅក្រោយ គឺចេញទៅជាបន្តបន្ទាប់តាមក្រោយ។

[១៤:១៩:០៣]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំឈប់សួរដើមបណ្ដឹងរដ្ឋប្បវេណីហើយ។ ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណីខ្ញុំសូមអរគុណលោកដែលបានព្យាយាមឆ្លើយនឹងសំណួររបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក សឿន សុវណ្ណី។ ការស្ដាប់នូវសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ស្ពាន-

ភាពព្យសនកម្ម ផលប៉ះពាល់និងសក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកអាច -- សេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់លោក និងផលប៉ះពាល់ និងសក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្ដីនេះ។ សូមលោក សឿន សុវណ្ណី មានសុខភាពល្អ ជួបតែសំណាងល្អបានសេចក្ដីសុខ សេចក្ដីចម្រើន ហើយវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក សឿន សុវណ្ណី វិលត្រឡប់ទៅកាន់ទីកន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅ ឬទៅកាន់លំនៅដ្ឋានរបស់គាត់វិញចុះ។

លោក សឿន សុវណ្ណី អាចចាកចេញវិលត្រឡប់ទៅវិញបានហើយ!

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-141 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៤:២២:៤២]

បាទ នៅក្នុងកិច្ចដំណើរការស្ដាប់នូវសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ផលប៉ះពាល់ និងសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ដោយសារដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គាត់មានពិការចក្ខុ ដូច្នេះសូមអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនថា អង្គជំនុំជម្រះសូមឲ្យលោកស្រី ឆាយ ម៉ារីដែត ដែលជាបុគ្គលិករបស់អង្គការ ធី.ភី.អូ ដែលជាបុគ្គលិកមកអង្គុយអម ដើម្បីជួយពង្រឹងស្មារតីដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលស្ដាប់សក្ខីកម្ម ឬក៏ផ្ដល់នូវសេក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងផលប៉ះពាល់នៅក្នុងអំឡុងពេលនេះ ដោយលោកស្រីជួយសម្រួលដោយកាយវិការណាមួយ ឬក៏កេះគាត់ ជម្រាបជូនគាត់ គាត់មិនអាចមើលឃើញនៅដំណើរប្រតិបត្តិការនៃឧបករណ៍នៅទីនេះទេ។ អ៊ីចឹងនៅពេលដែលឧបករណ៍នេះចាប់ផ្ដើមប្រតិបត្តិការ ក្រោយពីស្ដាប់សួរ គឺសូមលោកស្រីកេះជម្រាបទៅគាត់ដើម្បីឲ្យគាត់ទៅឆ្លើយតបបានរលូន បានល្អ នៅក្នុងកិច្ចដំណើរការសវនាការនាពេលនេះ។

[១៤:២៣:៥៨]

**សួរដោយការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី សេង ស៊ីវត្ថា៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ សេង ស៊ីវត្ថា។

**ស៖** បាទអរគុណលោកស្រី សេង ស៊ីវត្ថា តើលោកស្រីមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ចាស ឆ្នាំនេះខ្ញុំមានអាយុ៤៧ឆ្នាំ។

**ស៖** អរគុណ។ តើលោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ចាស ខ្ញុំសព្វថ្ងៃនេះ ខ្ញុំរស់នៅខេត្តតាកែវ ភូមិពោធិ៍ ស្រុកគីរីវង្ស ខេត្តតាកែវ។

**ស៖** ចុះភូមិកំណើតរបស់លោកស្រីវិញ លោកស្រីកើតនៅទីកន្លែងណា?

**ឆ៖** ភូមិកំណើតដែលខ្ញុំបានកើត គឺនៅខេត្តតាកែវហ្នឹងតែម្តង។

**ស៖** បាទ អរគុណ។ ហើយសព្វថ្ងៃលោកស្រីធ្វើអ្វី?

**ឆ៖** សព្វថ្ងៃខ្ញុំអត់បានធ្វើអ្វីទេ ត្បិតខ្ញុំងងឹតភ្នែកទាំងពីរ។

**ស៖** បាទ អរគុណ។ តើឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ព្រំ ថន ម្តាយឈ្មោះ ម៉ៅ ផាន។

**ស៖** បាទ អរគុណ។ ស៊ីវត្ថា តើលោកស្រីបានរៀបការដែរឬទេ ឬក៏នៅលីវ?

**ឆ៖** ចាស ខ្ញុំបានរៀបការនៅឆ្នាំ១៩៨២។

**ស៖** បាទ អរគុណ។ ហើយប្តីលោកស្រីគាត់ឈ្មោះអី ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ចាស ខ្ញុំមានកូនបួននាក់។ ប្តីខ្ញុំឈ្មោះ ជា ធឿន។

[១៤:២៦:០៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សេង ស៊ីវត្ថា ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការសវនាការនេះ អង្គជំនុំជម្រះផ្តល់ឱកាសជូនលោកស្រីថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា ផលប៉ះពាល់ដែលបានកើតមានចំពោះលោកស្រីជាអាទិ៍ ការខូចខាតខាងផ្លូវចិត្ត ខាងផ្លូវកាយ ឬក៏សម្ភារៈ ជាព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋដែលកើតមានពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ននេះ ដែលនាំឲ្យលោកស្រីប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុង

រឿងក្តីនេះ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទចំនួនពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រី នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

តែដោយសារមេធាវីរបស់លោកស្រីសូមតាំងខ្លួន -- តាំងសំណួរចំពោះលោកស្រីមុនពេលផ្តល់ឱកាសឲ្យលោកស្រីធ្វើសេចក្តីថ្លែងនោះ អង្គជំនុំជម្រះផ្តល់វេទិកានេះជូនទៅមេធាវីការពាររបស់លោកស្រីដើម្បីសាកសួរលោកស្រីមុន ហើយនៅក្នុងអំឡុងពេលនោះ លោកស្រីអាចធ្វើសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងផលប៉ះពាល់ទាំងឡាយចំពោះលោកស្រីដូចអង្គជំនុំជម្រះបានជម្រាបជូនលោកស្រីរួចហើយ។

ជាបន្តនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីទទួលសិទ្ធិជាមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី -- ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

[១៤:២៧:៥២]

**លោក អេមម៉ានូអែល ហ្សាកូមី**

សូមអរគុណលោកប្រធាន និងជម្រាបសួរអស់លោក លោកស្រីនៅក្នុងសាលសវនាការ។ ខ្ញុំជាមេធាវីរបស់អ្នកស្រី ស៊ីវត្ថា។ ដូចលោកប្រធានលើកឡើងហើយ គឺថាគាត់មានបញ្ហាចក្ខុ ហើយគាត់ត្រូវបានគេទទួលជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ ទាក់ទងទៅនឹងការជម្លៀសដំណាក់កាលទី១ ហើយនិងសហករណ៍ត្រាំកក់។ ខ្ញុំសូមឲ្យលេខយោងរបស់ចម្លើយរបស់គាត់ កំណត់ហេតុស្តាប់ចម្លើយរបស់គាត់មានពីរឯកសារគឺថា ទី១គឺថាD22/3804 (*ស៊ិក*) ហើយមួយទៀតគឺថាE9/2.2.16 (*ស៊ិក*)។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក អេមម៉ានូអែល ហ្សាកូមី**

**ស៖** អ្នកស្រី សេង ខ្ញុំសូមជម្រាបសួរ ហើយសូមអរគុណដែលមកផ្តល់សក្ខីកម្មនៅទីនេះ។ ខ្ញុំសូមចោទសំណួរមួយចំនួនទាក់ទងនឹងការឆ្លងកាត់របស់អ្នកស្រីនៅក្នុងរបបខ្មែរក្រហម ហើយបន្ទាប់មកទៀត អ្នកស្រីនឹងមានលទ្ធភាពក្នុងការសំណួរទៅជនជាប់ចោទ។ សំណួរទី១របស់ខ្ញុំទាក់ទងទៅនឹងភ្នែករបស់អ្នកស្រី។ អ្នកស្រីជាអ្នកពិការភ្នែក ហើយអ្នកស្រីបានឆ្លើយនៅក្នុងទម្រង់បែបបទចម្លើយរបស់លោកស្រីនោះថា ខូចភ្នែកនេះដោយសារខ្មែរក្រហម។ តើអ្នកស្រីអាចពន្យល់បានទេ មានរឿងអ្វី

កើតឡើងចំពោះអ្នកស្រីបានធ្វើឲ្យអ្នកស្រីពិការភ្នែកយ៉ាងដូច្នេះ?

[១៤:២៩:២៤]

**លោកស្រី សេង ស៊ីវត្ថា៖**

**ឆ៖** ចាស ខ្ញុំ នាងខ្ញុំកាលពី -- ហេតុតែខ្ញុំងងឹតភ្នែកទាំងពីរនេះ ដោយមូលហេតុកាលពី៣ឆ្នាំ ៨ខែ២០ថ្ងៃ។ ខ្ញុំបានត្រូវគេបង្ខំឲ្យចុះក្នុងរណ្ដៅកើបអាចម៍ជ្រូក ហើយក្នុងរណ្ដៅកើបអាចម៍ជ្រូកនោះមានជម្រៅជ្រៅ។ ដូច្នេះ ខ្ញុំត្រូវកើបឲ្យគេចំនួនជាង២០បង្គីទាំងខ្លួនខ្ញុំផ្ទាល់។ ហើយដល់អ៊ីចឹង ធ្វើឲ្យខ្ញុំហេវហត់អស់កម្លាំងដោយគ្មានអ្វីហូបគ្រប់គ្រាន់។ ដល់អ៊ីចឹងធ្វើឲ្យខ្ញុំនេះ ទន់ដៃទន់ជើង ហើយត្រូវឡើងពីរណ្ដៅមក វែកឡើងមកដោយខ្លួនឯង ហើយអ៊ីចឹងក៏ខ្ញុំងងឹតមុខដួលផ្កាប់មុខ កំពប់ជីហ្នឹងតែម្ដង។

ពេលដែលខ្ញុំកំពប់ហ្នឹងមានអ្នកក្រោយជួរជាមួយគ្នាហ្នឹងគេបានជាន់ខ្ញុំកំពប់អស់។ ដល់អ៊ីចឹងគេបានយកដងវែកវ៉ៃខ្ញុំ ហើយពេលដែលខ្ញុំស្រែកយំ -- អ៎! ខ្ញុំព្យាយាមរត់គេក៏យកខ្សែបង្គីចងខ្ញុំជាប់ដើមត្រាច ហើយបន្ទាប់មកទៀតគេក៏បានវ៉ៃខ្ញុំបន្តទៅទៀត ហើយពេលនោះខ្ញុំស្រែកទ្រហោយំខ្លាំង គេក៏ស្រាយខ្ញុំចេញតែវ៉ៃបន្ថែមទៀត ធ្វើឲ្យត្រូវភ្នែកនាងខ្ញុំខាងឆ្វេងតែម្ដង។

ហើយអ៊ីចឹងក្រោយមក គេក៏នាំគ្នាប្រមូលជីហ្នឹងវែកមកចាក់ឃ្លាំង ហើយខ្ញុំនេះនៅម្នាក់ឯង យំផង ក្ដីឈឺចាប់ភ្នែកផង ខ្ញុំកើបជីដាក់ក្នុងបង្គីហើយ ខ្ញុំក៏វែកមកបញ្ចូលឃ្លាំងនៅកងអង្គត្រាវ។ ពេលដែលខ្ញុំមកដល់កងពេលយប់ ព្រលប់ៗ ខ្ញុំមិនអាចទៅធ្វើអីកើតទៀតទេ ខ្ញុំក៏ចូលទៅហូបបបរ ហើយការដែលឈឺភ្នែករបស់ខ្ញុំហ្នឹង ឈឺចុកចាប់តែខ្ញុំអត់បានដឹងថា ភ្នែកខ្ញុំជាំឈាម ឬក៏បែបណា ប៉ុន្តែពេលយប់ខ្ញុំដេកឈឺខ្លាំង ហូរទឹកភ្នែក ព្រឹកឡើងខ្ញុំមិនអាចទៅធ្វើការបាន។ ខ្ញុំមានបំណងថាខ្ញុំនឹងរត់ទៅផ្ទះ។

[១៤:៣១:០៨]

ពេលម៉ោងបួនទៀបភ្លឺ ខ្ញុំក៏រត់ទៅផ្ទះជួបជីតារបស់ខ្ញុំ ទៅរកអ្នកផ្ទះរបស់ខ្ញុំ តែអត់មានឃើញអ្នកណាទេនៅក្នុងផ្ទះស្ងាត់ស្ងៀមតែម្ដង។ ពេលអ៊ីចឹងខ្ញុំដឹងថា ជីតាខ្ញុំគាត់នៅរៀបចំចំបើងនៅផ្លូវទៅទំនប់ចម្ការសៀង។ ពេលនោះខ្ញុំទៅដល់ឃើញជីតាខ្ញុំកំពង់តែនៅលើផ្នូកចំបើង ខ្ញុំក៏ស្រែកហៅគាត់ឲ្យគាត់ចុះជួយមើល ភ្នែកខ្ញុំ។ ពេលគាត់ចុះមក គាត់សួរខ្ញុំថា ហេតុអីបានជាភ្នែកឡើងក្រហម។ ខ្ញុំថាភ្នែកខ្ញុំត្រូវគេវ៉ៃខាងឆ្វេងហ្នឹងគេវ៉ៃត្រូវនឹងខ្សែគោ ខ្សែចងបង្គី។ អ៊ីចឹងក៏ខ្ញុំ គាត់បានប្រាប់ខ្ញុំថា ឲ្យយកក្រមាហ្នឹងស្អំគាត់ក៏ផ្ដុំក្រមាស្អំភ្នែកឲ្យខ្ញុំ ប៉ុន្តែពេលដែលស្អំហ្នឹង ក៏មិនបានស្រុយស្រួលដែរ ត្បិតអីការងារជីតារបស់ខ្ញុំត្រូវរៀបចំធ្វើផ្នឹមចំបើងហ្នឹងតទៅទៀត។ ហើយគាត់ក៏បានឲ្យខ្ញុំហ្នឹងអាចម៍គោមួយបង្គី -- មួយអំប្រែក

ហ្នឹងរែកទៅកងវិញ ហើយបានផ្តាំថាទៅដល់កងវិញព្យាយាមផ្តុំភ្នែកនឹងក្រមា ប៉ុន្តែពេលនោះខ្ញុំនៅក្មេង អាយុបាន១១ឆ្នាំហើយ ពេលខ្ញុំបាននៅកងអង្គត្រាវហ្នឹង។ ខ្ញុំមិនអាចនឹងដឹងថាភ្នែកហ្នឹងបែបណាទេ ខ្ញុំមិនអាចផ្តុំអីដូចជា ឬក៏ដាក់ថ្នាំ ឬក៏ព្យាបាលដោយវិធីពេទ្យអីគឺអត់មានទេ។ ខ្ញុំលុបមុខក៏ទឹកមិនស្អាត ហើយការឈឺចាប់ ក៏ឈឺចាប់យ៉ាងខ្លាំង។ ពេលនោះខ្ញុំទ្រាំធ្វើការទាំងឈឺទាំងជា តស៊ូធ្វើការដោយក្តីលំបាក និងការឈឺចាប់ភ្នែកម្ខាងដែលខាងឆ្វេងត្រូវគេវ៉ៃត្រូវហ្នឹង។

[១៤:៣២:៣៧]

ហើយក្រោយមកទៀត ខ្ញុំក៏សម្រេចចិត្តថាទៅឲ្យម្តាយ ទៅជួបម្តាយ តែម្តាយក៏មិនជួបទៀត ភ្នែកខ្ញុំក៏ទ្រាំឈឺអ៊ីចឹងរហូតមក លុះដល់ឆ្នាំ១៩៧៩ ហ្នឹង ថ្ងៃរំដោះហ្នឹងបានដឹងថាភ្នែកខ្ញុំខាងឆ្វេងត្រូវខូចបាត់បង់។ ពេលនោះដែរ ភ្នែកខាងឆ្វេងបានខូចបាត់បង់ដោយសារជួបជុំឪពុកម្តាយ គាត់មកជួបជុំអង្កាល់ឆ្នាំ៧៩ហ្នឹង គាត់បានឃើញភ្នែកខ្ញុំហ្នឹងតូចមួយចំហៀង ហើយគាត់ក៏បានសួរខ្ញុំថាហេតុអីបានភ្នែកតូចមួយចំហៀង? មើល៍ម៉ែមើលមើល៍។ ដល់ពេលអ្នកម្តាយខ្ញុំគាត់មើលគាត់ឃើញថាភ្នែកហ្នឹងអត់មានឃើញអី គ្រាន់តែឃើញដូចមានគ្រាប់បាយតូចចេញពីក្នុងមក ហើយគាត់ក៏បានថា អ៊ីចឹងទាល់តែរកទិញថ្នាំនៅប្រទេសវៀតណាមយកមកដាក់។ អ៊ីចឹងគាត់ទិញថ្នាំប៉ូម៉ាតប៉េលីសាលីនយកមកដាក់ភ្នែកហ្នឹង តែដាក់អត់ជាទេ។ ពេលនោះភ្នែកខ្ញុំខាងឆ្វេងហ្នឹងក៏ចេះតែទ្រុឌទ្រោម ហើយខ្ញុំក៏បានចូលសាលារៀននៅឆ្នាំ៨០ ពេលខ្ញុំបានចូលសាលារៀន ខ្ញុំទៅរៀនបណ្តើរភ្នែកខ្ញុំឈឺបណ្តើរ ឈឺរកាំហូរទឹកភ្នែកជារៀងរាល់ថ្ងៃ ប៉ុន្តែខ្ញុំព្យាយាមនឹងទៅរៀន។ ហើយការដែលខ្ញុំមើលអក្សរនោះ ភ្នែកខាងស្តាំមិនអាចបានដូចគេដូចឯងទេ ភ្នែកខ្ញុំខាងស្តាំក៏មានការព្រិលមើលអក្សរ ពេលឈ្ងោកសរសេរ ពេលងើបឡើងវិញមើលព្រិលអស់ ជាន់ដៃជាន់ជើងចូលគ្នា មិនអាចនឹងមើលអក្សរបាន។ ហើយខ្ញុំត្រូវការ -- ជុំវិញខ្លួនខ្ញុំហ្នឹង គេនិន្ទាខ្ញុំ គេដៀលខ្ញុំថា ធម្មតាក្មេងមិនអាចគេល្អជាមួយយើងគ្រប់ដប់ទេ គេមានទាស់អីបន្តិចបន្តួចគេខ្ញុំ មីខ្វាក់ មីក្វាងម្ខាក់ ហើយខ្ញុំមានអារម្មណ៍ថាក្តុកក្តួលចិត្តកន្តែងហ្នឹង។ ខ្ញុំឈឺចាប់ ខ្ញុំមិនអាចរៀនតទៅទៀតបាន ខ្ញុំសម្រេចចិត្តថាខ្ញុំនឹងឈប់រៀន ហើយខ្ញុំនៅលក់ដូរបន្តិចបន្តួចជាមួយម៉ាក់យាយខ្ញុំ។

[១៤:៣៤:៣៤]

ពេលនោះដែរ ក្នុងឆ្នាំ១៩៨២ ខ្ញុំបានរៀបការ ហើយពេលហ្នឹងខ្ញុំបានខូចភ្នែកខាងឆ្វេងអស់រលីង ហើយអត់មានសល់ទេ។ ហើយដល់អ៊ីចឹងភ្នែកខាងស្តាំហ្នឹងក៏ចេះតែព្រិលអ៊ីចឹងរហូត ហូរទឹកភ្នែក មើល

អីក៏អត់ស្ងួរច្បាស់ដែរ។ ដល់អ៊ីចឹងក្នុង -- អ៎! ខ្ញុំនិយាយថយក្រោយបន្តិចវិញ។ ដល់ឆ្នាំ៨០ ខ្ញុំបានម៉ាក់យាយខ្ញុំយកមកពេទ្យចិនៗ ដល់ពេលមកពេទ្យចិនៗបានផ្ទុះមើលថាភ្នែកខាងឆ្វេងហ្នឹងខូចហើយអត់មានកែអីបានទៀតទេ តអីមើលគ្រាប់ភ្លើង សញ្ញាភ្លើងនៅក្នុងហ្នឹងអត់ឃើញ។ អ៊ីចឹងខ្ញុំក៏អស់សង្ឃឹមភ្នែកខាងឆ្វេងហ្នឹង។ តែភ្នែកខាងស្តាំនៅឈឺរហូត ព្រិលអ៊ីចឹងរហូតមក ហើយក៏ព្យាយាមព្យាបាលហ្នឹងក៏មិនបានធូរស្រាលដែរ។

[១៤:៣៥:២៦]

អ៊ីចឹងនៅក្នុងឆ្នាំ៨២ ហ្នឹងក៏បានរៀបការ។ នៅពេលនោះខ្ញុំតស៊ូរកស៊ីផង ព្យាបាលភ្នែកខាងស្តាំហ្នឹងផង ត្បិតអីចេះតែឈឺ ចេះតែរោយ ចេះតែរកាំ។ អ៊ីចឹងនៅក្នុងឆ្នាំ១៩៩៥ ខ្ញុំគិតថា ភ្នែកខ្ញុំខាងស្តាំប្រហែលជាទ្រុឌទ្រោមទៅមែនទែនហើយ អ៊ីចឹងខ្ញុំគិតថា ចងសង្គ្រោះភ្នែកខាងស្តាំ ខ្ញុំក៏មកពេទ្យអង្គឌួងខ្វេះភ្នែកខាងឆ្វេងហ្នឹងចោល ដាក់កែវ ហើយក៏បានលោកគ្រូពេទ្យថា ភ្នែកខាងស្តាំប្រហែលជាមិនអាចសង្គ្រោះបាន១០០ភាគរយទេ។ ត្បិតអីវាឆ្លងរួចបាត់ទៅហើយ ពេលនោះខ្ញុំមានអារម្មណ៍ថាក្តុកក្តួលក្នុងចិត្តគិតថាថ្ងៃក្រោយខ្ញុំនឹងត្រូវពិការភ្នែកទាំងពីរ។ ប៉ុន្តែខ្ញុំតស៊ូលក់ដី លក់ផ្ទះ លក់សម្បែងដើម្បីយកលុយព្យាបាលភ្នែក តែខ្ញុំព្យាបាលភ្នែកអត់ជាទេ រហូតដល់ថ្ងៃដែលខ្ញុំងងឹតទាំងស្រុងនេះ គឺឆ្នាំ២០០៨។ ខ្ញុំងងឹតសូន្យទាំងស្រុងតែម្តង។ នៅខ្ញុំងងឹតភ្នែកទាំងស្រុងនេះ ប្តីក៏បានបោះបង់ខ្ញុំចោល ដោយថា ខ្ញុំពិការភ្នែកទាំងពីរហើយ គ្មានអ្វីនឹងសំអាង និងរស់នៅជាមួយខ្ញុំមានអនាគតទៀតទេ។ គេទៅរកអ្នកថ្មីត្បិតអីខ្ញុំងងឹតខ្វាក់អស់ហើយ គ្មានសម្រាប់ -- សម្រាប់គេ គឺគ្មានប្រយោជន៍។ ពេលនោះ ខ្ញុំជួបទុក្ខលំបាកវេទនាយ៉ាងធ្ងន់ធ្ងររកអ្វីរស់ពុំបាន ហើយត្រូវបញ្ឈប់ការសិក្សាកូនទាំងបួននាក់។ កូនអាយុ ១៧ឆ្នាំត្រូវទៅធ្វើសំណង់ កូន១៤ឆ្នាំត្រូវទៅធ្វើការរោងចក្រ កូនអាយុ១០ឆ្នាំត្រូវរើសអេតចាយ។ រីឯកូនម្នាក់ទៀតអាយុបីឆ្នាំ ត្រូវដឹកដៃខ្ញុំនៅជាមួយខ្ញុំ។

[១៤:៣៧:១៦]

ពេលនោះ ខ្ញុំឈឺចាប់យ៉ាងខ្លាំង ហើយក៏ខ្ញុំជួបទុក្ខលំបាកវេទនាយ៉ាងធ្ងន់ធ្ងរ។ ខ្ញុំសូមនិយាយថយក្រោយបន្តិច។ នៅក្នុងឆ្នាំ១៩៧៥ ថ្ងៃ១៧ មេសា ពេលនោះខ្ញុំនៅតូចអាយុបាន៩ឆ្នាំ ជម្លៀសចេញពីភ្នំពេញ ខ្ញុំជួបទុក្ខលំបាកវេទនាត្រូវម្តាយ ម៉ាក់យាយខ្ញុំចងដៃខ្ញុំជាប់ពីរនាក់បងស្រីខ្ញុំ ចងជាប់គ្នា ហើយយកទៅចងជាប់នឹងសង្រែក ត្បិតអីពេលពេលនោះមនុស្សច្រើនចេញពីភ្នំពេញ មនុស្សចង្អៀតគ្នា ហើយណែនជ្រៀតដូចម្រាមដៃ។ អ៊ីចឹងគាត់ខ្លាចបែកគ្នា គាត់ចងដៃជាប់គ្នាហើយ ធ្វើដំណើរតាមផ្លូវរហូត។

ខ្ញុំជួបប្រទះនឹងខ្មោចស្លាប់តាមចិញ្ចើមថ្នល់ និងតាមថ្នល់ដែលខ្ញុំដើរហ្នឹង ខ្ញុំត្រូវជាន់ខ្មោច ដើរកន្លងខ្មោច ហើយត្រូវការហេវហត់អស់កម្លាំង ថ្ងៃក្ដៅ ស្រេកទឹក ហើយពេលខ្ញុំដើរខ្ញុំឃ្លានបាយ ខ្ញុំមិនអាចឈប់ហូបបាយបាន ពេលនោះដែនៅសល់ម្ហូង ម្នាក់ៗពីរនាក់បងស្រីក៏បើកគម្របឆ្នាំងបាយ លូកបាយហូបម្ដងម្នាក់។ ប៉ុន្តែខ្ញុំស្រេកទឹកអត់បានហូបទេ ត្បិតអីយើងដើរគ្មានទីកំណត់ថា យើងត្រូវឈប់កន្លែងណា។ ដើររហូតដល់យប់ៗដើរទៅទៀត ទម្រាំតែបានដល់គោលដៅថា វាលអាចយើងឈប់បាន។

[១៤:៣៨:៤២]

ពេលនោះដែរ ខ្ញុំដើររហូតដល់ស្ពានច្បារអំពៅទៅចាក់ទៅវត្តនិរោធរហូតទៅទៀត ទៅដល់កោះក្របី ទើបដើរកាត់ទៅចាកស្ពានផ្លូវថ្នល់ជាតិលេខ៣ បានជួបឡាន អេ.ម៉ា.សេ របស់ -- មិនដឹងជារបស់ខាងណាខ្ញុំអត់បានស្គាល់ដែរ ដែលខ្ញុំនៅតូច បានហៅថាប្រជាជនសុំឡើងមកៗ ឲ្យជិះឡានទៅតាមខេត្តតាមជនបទ។ ពេលនោះ ខ្ញុំព្ញសួរម៉ាក់យាយខ្ញុំ តាខ្ញុំគាត់ថា ហេតុអីបានជាគេឲ្យយើងឡើងឡានទៅតាមខេត្ត ព្រោះមួយរយៈនេះគឺថា ឲ្យយើងចេញតែមួយរយៈយ៉ាងខ្លីតើ ហេតុអីក៏គេឲ្យយើងទៅតាមខេត្តទៀត? ប្រហែលជាយើងមិនអាចវិលត្រឡប់មកកន្លែងវិញទេ បានជាគេឲ្យយើងទៅតាមខេត្ត។ អ៊ីចឹងក៏យើងមិនប៉ានប្រកែក យើងក៏នាំគ្នាឡើងទៅតាមខេត្តហ្នឹង។ គេក៏បានដឹកទៅដល់ភូមិតាម៉េង នៅក្នុងខេត្តតាកែវដដែលហ្នឹង នៅ១០៩។

[១៤:៣៩:៤៦]

ពេលខ្ញុំទៅដល់១០៩ហ្នឹង ទៅដល់អត់នៅភូមិបានប៉ុន្មានទេ គេក៏បញ្ជូនទៅនៅកង ឲ្យទៅនៅកងច្រកជីគាំ។ ខ្ញុំពេលដែលទៅនៅកងនេះ ខ្ញុំត្រូវជួបទុក្ខលំបាកវេទនាយ៉ាងខ្លាំង ត្បិតនៅតូចត្រូវប្រើខ្ញុំធ្វើការទាំងយប់ទាំងថ្ងៃ។ ពេលថ្ងៃឲ្យចូកស្មៅចេក ចូកស្មៅពោត។ ពេលព្រលប់ឲ្យខ្ញុំទៅដកសំណាប។ ពេលម៉ោងបួនឲ្យខ្ញុំទៅជញ្ជូនកណ្ដាប់ឲ្យចាស់ៗស្ទូង។ ពេលនោះដែរខ្ញុំអត់ស្គាល់ឈ្លើង ថាឈ្លើងហ្នឹងជាសត្វអ្វី វាអាចខាំអត់ដឹង ស្មានថាសត្វហ្នឹងថាគេយកទៅហូបបាន។ ខ្ញុំសួរអ៊ុំម្នាក់ គាត់ក៏បានប្រាប់ថាសត្វហ្នឹងគេយកទៅលីង។ ខ្ញុំក៏ខំតែចុះឲ្យវាតោង ខំពេញខ្លួនប្រាណ ដើម្បីយកទៅលីងហូប។ ប៉ុន្តែដល់ពេលមួយមានអ៊ុំម្នាក់គាត់ខ្លាច ឲ្យគាត់ជួយបេះគាត់រត់ គាត់ខ្លាច បានខ្ញុំដឹងថាសត្វខ្លាច។ ពេលនោះឯងខ្ញុំលោះព្រលឹង ខ្ញុំរូសនៀលខ្លួននៅនឹងស្មៅខ្លួននៅនឹងស្មៅ ដាច់របូតសត្វហ្នឹងចេញពីខ្លួនអស់។

[១៤:៤០:៤៥]

ខ្ញុំក៏សម្រេចចិត្តថាលែងទៅធ្វើការទៀត ប៉ុន្តែមិនអាចចៀសផុតបាន ដោយគេប្រើគេបង្ខំរហូត

ហើយគេត្រូវដករបបអាហាររបស់ខ្ញុំមិនឲ្យខ្ញុំហូប។ ពេលនោះឯងខ្ញុំក៏សម្រេចចិត្តរត់ទៅនៅក្នុងព្រៃអស់រយៈកាលប្រាំប្រាំមួយខែ ដោយអត់អាហារ មិនដែលស្គាល់ជាតិបាយ ឬក៏បបរ។ ខ្ញុំដេកលើចុងឈើដោយក្ដីលំបាកវេទនា ភ្លៀងរងាររញ្ជាក់ញ័រ ដោយខ្ញុំដេកមានតែអាវខោមួយចង្កេះផ្អេះនឹងខ្លួន សើមហ្នឹងស្ងួតហ្នឹង។ ហើយខ្ញុំត្រូវហូបអ្វីដែលចង្អែតក្រពះបាន ខ្ញុំហូបស្លឹកឈើ ខ្ញុំហូបត្រសក់ ហូបត្រប់ ត្រឡាចដែលខ្ញុំដើរប្រទះ ហូបក្ដាមខ្យង ជួនកាលអាចដំខ្យងឆៅហូប ជួនកាលខ្ញុំដកស្មៅហូប ជួនកាលខ្ញុំចុះស្រែលួនចុះក្នុងសន្ទូង ដកដង្ហើមស្រូវហូបដោយដេកត្រាំទឹក ហើយដកសន្ទូង ដកដង្ហើមស្រូវហូប។ ជួនកាលខ្ញុំមិនអាចេញទៅក្រៅខ្លាចគេឃើញ ខ្ញុំត្រូវកើបលិឍដីខ្សាច់ យកដីខ្សាច់ហូបទៀត។ ខ្ញុំជួបទុក្ខលំបាកវេទនាយ៉ាងខ្លាំង។

[១៤:៤១:៥៨]

លុះដល់ខ្ញុំវិលត្រឡប់គេបញ្ជូនមក១០៥ ស្រុកត្រាំកក់ ភូមិសិរីដំណាក់ ឃុំត្រពាំងធំខាងជើង ខ្ញុំជួបទុក្ខលំបាកវេទនាយ៉ាងខ្លាំងកន្លែងហ្នឹង។ ខ្ញុំនៅកងភូមិត្រូវរែកទឹកស្រោចដំណាំមួយថ្ងៃប្រាំរង ហើយរងនោះវែង១ណាស់ ខ្ញុំអត់ដឹងថាប៉ុន្មានម៉ែត្រទេ តែវែង។ គេឲ្យចុះក្នុងត្រពាំងរែកទឹកឡើងពីត្រពាំងមកស្រោចដំណាំ ហើយគេធ្វើជណ្ដើរពីដើមឈើ។ ហើយជណ្ដើរនោះស្ដែកាន់ ខ្ញុំរែកឡើង ខ្ញុំមានអារម្មណ៍ថាខ្លាចភ័យ ខ្លាចធ្លាក់ចុះទៅក្នុងត្រពាំងវិញ។ ពេលនោះឯងខ្ញុំក៏ត្រដេរត្រដររែកដោយបង្ខំចិត្ត ហើយក៏អត់ធ្លុត់បំផុត។ ពេលបានស្រោចហើយម្ល៉ែខ្ញុំមានអារម្មណ៍ថាសប្បាយចិត្ត។ ប៉ុន្តែមានថ្ងៃមួយខ្ញុំក៏រែកធ្លាក់រអិលជើង ទាំងធុងទាំងមនុស្សទាំងខ្ញុំហ្នឹងទៅក្នុងត្រពាំងវិញ ប៉ុន្តែគេអត់ធ្វើអីខ្ញុំទេ គេគ្រាន់តែងើបឡើងរែកបន្តទៀត។

ពេលនោះខ្ញុំមានជំងឺគ្រុនក្ដៅ ខ្ញុំហេវហត់អស់កម្លាំង ដោយហូបមិនគ្រប់គ្រាន់ ខ្ញុំក៏សម្រេចចិត្តថានឹងបេះផ្លែក្រូចមួយហូប ត្បិតអីផ្លែក្រូចនៅមានក្បែរខ្លួន ចម្ការក្រូចនៅបៀតកន្លែងខ្ញុំដាំបន្លែ។ ខ្ញុំក៏បេះផ្លែក្រូចមួយហូប ពេលដែលខ្ញុំបេះហើយ ហូបហើយ ខ្ញុំអត់បានដឹងថាផ្លែក្រូចមួយខ្ញុំមានទោស អត់បានបោះសំបកចោលទៅឆ្ងាយពីខ្លួន។ បន្ទាប់មកនោះមេកងខ្ញុំក៏មកដល់។ មកបៀតខ្ញុំធុំក្លិនក្រូច គាត់ក៏បានហិតមាត់ខ្ញុំ ថាខ្ញុំហ្នឹងហូចផ្លែក្រូចឆ្មារ។ គាត់បានសួរខ្ញុំថាខ្ញុំមានបេះផ្លែក្រូចដែរអត់? មានហូបក្រូចដែរអត់? គេអត់បាននិយាយសីលធម៌អីចឹងទេ គេហៅស៊ី មានបេះផ្លែក្រូចស៊ីដែរអត់? ខ្ញុំថាខ្ញុំអត់បានហូបទេ ខ្ញុំអត់បានបេះទេ។ គេក៏អត់ជឿខ្ញុំ គេក៏យកក្រមាពីកគេទាក់កខ្ញុំ ហើយគេម្លួលកខ្ញុំ គេរឹតគេយកក្រមារឹតកខ្ញុំ ដល់ខ្ញុំចង់លៀនអណ្ដាតលៀនភ្នែក ហើយខ្ញុំមិនអាចនិយាយបាន ខ្ញុំបានត្រឹមតែហូរទឹកភ្នែក។

ពេលនោះដែរខ្ញុំមិនអាចទ្រាំកុហកគេតទៀតបាន ខ្ញុំក៏ឆ្លើយត្រង់ថា ខ្ញុំបានបេះផ្លែក្រូចឆ្មារមួយហូបមែន។ អ៊ីចឹងគេក៏អត់លែងខ្ញុំទេ គេនឹងរឹតក៏ខ្ញុំទៀត។ តែបានកុមារីតូចៗដូចគ្នា កូនអ្នកមូលដ្ឋានបានជួយអង្វរថា ឈប់ធ្វើកុមារីហ្នឹងទៅគ្នាតូច ហើយស្គមស្គាំង ហើយគ្នាឃ្លានឲ្យគ្នាហូចមួយទៀត អ៊ំអើយអាណិតគ្នា។ ពេលជួយអង្វរគ្រប់គ្នាគាត់ក៏បានលែងខ្ញុំវិញ ហើយគាត់បានប្រាប់ខ្ញុំថា ថ្ងៃក្រោយកុំឲ្យខ្ញុំលួចអ៊ីចឹងទៀត កុំឲ្យលួចបេះក្រូចឆ្មារហូបអ៊ីចឹងទៀត។ ពេលនោះ ខ្ញុំក៏បានរួចខ្លួនពីគាត់រឹតក ហើយខ្ញុំក៏ដើបឡើងទៅរែកទឹកស្រោចដំណាំតទៅទៀត។

[១៤:៤៥:០៧]

ការទុក្ខលំបាករបស់ខ្ញុំ កាលពីសម័យ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ខ្ញុំជួបទុក្ខលំបាកវេទនាខ្លាំង ដោយនៅកងកុមារខ្ញុំត្រូវធ្វើការដូចមនុស្សចាស់ ហើយខ្ញុំហូបអាហារមិនគ្រប់គ្រាន់។ ខ្ញុំហូបបបរគេវាល់វែកឲ្យមួយវែក ហើយត្រូវលាយ ជួនលាយពោត ជួនលាយដំឡូង ជួនក៏លាយមើមល្ពុង ឫសល្ពុង ហើយនិងមើមចេក ហើយខ្ញុំត្រូវអត់ចេះហូបចំណីអស់ហ្នឹង ប៉ុន្តែខ្ញុំត្រូវតស៊ូហូបដោយក្ដីឃ្លាន ស្រែកឃ្លានខ្លាំងពេក។ ហើយពេលដេក ខ្ញុំត្រូវដេកកំសត់ម្នាក់ឯង អត់មានឪពុកម្ដាយនៅក្បែរ ដេកលើតុបាយ ដេកលើចាក់សាប ដេកលើដី ដេកលើស្លឹកត្នោត ហើយគ្មានសាប៊ូដុះខ្លួន គ្មានសាប៊ូងូតទឹកល្អស្អាតត្រឹមត្រូវ ហើយក៏ត្រូវអត់អាហារហូប ជួនក៏អត់មួយយប់ទាល់ភ្លឺ។ ហើយត្រូវរូបកាយរបស់ខ្ញុំកើតរមាស់ដំបៅពេញខ្លួន ដំបៅពេញខ្លួនពេញជើង ដំបៅដល់ៗឆ្អឹង ហើយត្រូវបង្ខំចិត្តធ្វើការ។ ជើងហើមៗដើរអត់ចង់រួចទេ ទាក់ក្រមាលោតដូចសត្វលោតអ៊ីចឹង ទាក់ក្រមាលោត ព្រោះអីជើងហើមលើបអស់ ដើរអត់បានហើយស្ពឹក។ ហើយខ្ញុំត្រូវវេទនា ដេកយប់ឡើង ខ្ញុំកំសត់ម្នាក់ឯង ដេកហូរទឹកភ្នែក។ ខ្ញុំមិនដែលជួបប្រទះនូវទុក្ខលំបាកវេទនាបែបនេះ។

[១៤:៤៦:៥៧]

ហើយខ្ញុំក៏សម្រេចចិត្តថាខ្ញុំចង់រត់ទៅផ្ទះ ប៉ុន្តែខ្ញុំរត់ទៅអត់បាន។ បើសិនជាខ្ញុំរត់ទៅផ្ទះ ខ្ញុំត្រូវក៏ទៅម្នាក់ឯងដដែល អត់បានជួបឪពុកម្ដាយយាយតា ត្បិតអី ឪពុកម្ដាយយាយតា គេបញ្ជូនទៅសហករណ៍ផ្សេងៗទាំងអស់ បងស្រីអី អត់មានសល់ទេ។ អ៊ីចឹងខ្ញុំសម្រេចចិត្តនៅកងធ្វើការតទៅទៀត ដោយក្ដីលំបាកវេទនាជាទីបំផុត។ ហើយខ្ញុំត្រូវគេវៃធ្វើបាបជារៀងរហូត ហូបបាយអត់មានបាយហូប ដេកអត់មានមុងភួយ ខោអាវសម្លៀកបំពាក់អត់មានផ្លាស់ ហើយត្រូវកើតជំងឺចៃសាច់ ចៃសាច់កើតពេញខ្លួន។

ពេលយប់ឡើងខ្ញុំត្រូវគេឲ្យប្រជុំស្វ័យទិតៀន និងទិតៀន ហើយខ្ញុំនៅតូច ខ្ញុំអត់ដឹងថា ទិតៀន

ស្វ័យទិតៀនបែបណាទេ។ ខ្ញុំចេះតែឡើងទិតៀនគេឯងអ៊ីចឹង ទិតៀនខុស ដូចថា អត់ដឹងថាគេធ្វើអ្វីខុស ធ្វើអ្វីត្រូវ ប៉ុន្តែគេៗបង្ខំចិត្តឲ្យខ្ញុំឡើងទិតៀន បើសិនណាជាខ្ញុំមិនឡើងទិតៀនគេ គេនឹងទិតៀនខ្ញុំ។ ខ្ញុំធ្វើអ្វីខុសបន្តិចបន្តួច ដូចថាការធ្វើការយឺតដៃយឺតជើងបន្តិចបន្តួច តែងមានក្រុមជាមួយគ្នាគេនឹងទិតៀនខ្ញុំ ហើយខ្ញុំត្រូវទិតៀនគេ ហើយពេលនោះ ខ្ញុំអត់យល់កាលៈទេសៈ ថាធ្វើការបែបណាល្អ បែបណាអាក្រក់ ខ្ញុំអត់បានដឹង អត់បានយល់។ ខ្ញុំចេះតែទិតៀនគេអ៊ីចឹង ដូចគេដូចឯងទៅវិញទៅមក។ ហើយពេលអ៊ីចឹងក៏ទិតៀនគេខុសអ៊ីចឹងទៅ គេអាចវ៉ៃខ្ញុំអ៊ីចឹងក៏ថាបាន។ ហើយពេលនោះដែរ ខ្ញុំមានអារម្មណ៍ថាខ្ញុំឈឺចាប់ជាទីបំផុត ដែលពេលខ្ញុំធ្វើការហើយ ខ្ញុំត្រូវខុស ហើយធ្វើការហើយត្រូវហូបអាហារមិនគ្រប់គ្រាន់។ ឈឺក៏ខ្ញុំមិនអាចឈប់នៅផ្ទះបាន សម្រាកបាន ពេលឈឺក៏ធ្វើការទាំងឈឺទាំងជា។

[១៤:៤៩:៣៤]

ប៉ុន្តែមកដល់ពេលនេះ ខ្ញុំបានគិតថា ជីវិតរបស់ខ្ញុំបានសុខស្រួលហើយ នៅឆ្នាំ១៩៧៩។ គិតថាជីវិតខ្ញុំបានសេរីភាព និងបានសុខហើយ ប៉ុន្តែទន្ទឹមនឹងបានសុខ ខ្ញុំត្រូវងងឹតភ្នែកទាំងស្រុង ដោយមើលអ្វីមិនឃើញ ហើយដែលត្រូវប្ដីបោះបង់ចោល ហើយខ្ញុំត្រូវជួបទុក្ខលំបាក ដោយខ្ញុំរកអ្វីទទួលទានមិនបាន ត្រូវធ្វើអ្វីមិនបាន រស់នឹងចិញ្ចឹមជីវិតដូចគេ។ ដូច្នេះ ខ្ញុំត្រូវជួបទុក្ខលំបាកវេទនាយ៉ាងធ្ងន់ធ្ងរជាទីបំផុត។

**សៈ** សូមអរគុណលោកស្រី ស៊ីវុត្ថា ដែលបានបង្ហាញជូននូវបទពិសោធន៍នៃការឈឺចាប់ដែលលោកស្រីបានជួបប្រទះ។ ខ្ញុំចង់សួរសំណួរបន្ថែមមួយចំនួនទៀតទៅកាន់លោកស្រីពាក់ព័ន្ធទៅនឹងអ្វីដែលបានកើតឡើងចំពោះលោកស្រីក្នុងសហករណ៍។ នៅសម័យនោះលោកស្រីនៅតូចនៅឡើយទេ គឺត្រឹមតែអាយុ១១ឆ្នាំប៉ុណ្ណោះ។ ហើយកុមារដូចលោកស្រីហ្នឹងត្រូវធ្វើការធ្ងន់ៗដូចមនុស្សធំដែរ។ ហើយនៅក្នុងចម្លើយរបស់លោកស្រីហ្នឹងគឺថា លោកស្រីត្រូវបង្ខំចិត្តធ្វើការជាមួយនឹងលាមក។ តើលោកស្រីអាចពន្យល់បានទេថាលោកស្រីធ្វើអ្វីឲ្យពិតប្រាកដដែរចំពោះការងារទាំងអស់នោះ?

[១៤:៥១:១៥]

**ឆៈ** ចាស ខ្ញុំត្រូវនៅក្មេងអាយុ១១ឆ្នាំ ហើយត្រូវគេបង្ខំឲ្យធ្វើការជាមួយលាមក ដូចជាលាមកមនុស្ស លាមកសត្វ លាយបញ្ចូលគ្នាហើយដាក់ទៅក្នុងឃ្លាំង។ ហើយពេលខ្លះក៏គេឲ្យយើងទៅរកកើបអាចម៍ គោប្រមូលអាចម៍គោតាមស្រែ។ អាហ្នឹងគេអត់តាមយើងទេ គេឲ្យយើងដើររកពាសវាលពាសកាល តែគេកំណត់ឲ្យយើងក្នុងមួយថ្ងៃឲ្យបាន៨០គីឡូ។ ហើយបើយើងទៅកើបអាចម៍ជ្រូកក្រោលអាហ្នឹងបានគេតាមយើង។ ប្រធានគេតាមយើង។ ហើយគេនាំយើងទៅចុះរណ្ដៅកើបអាចម៍ជ្រូក

បញ្ចូលឃ្លាំង។

ពេលដែលខ្ញុំទៅចុះក្នុងរណ្ដៅខ្ញុំមានអារម្មណ៍ថាលំបាកមែនទែន។ ត្បិតអីចុះរណ្ដៅវាជ្រៅហើយខ្ញុំនៅតូចពេកចុះទៅរណ្ដៅនោះតែងតែលិចខ្ញុំត្រឹមចង្កេះ។ ធ្វើឱ្យខ្លួនប្រាណរបស់ខ្ញុំកើតរមាស់ យប់ឡើងរមាស់អត់បានដេក ថ្ងៃក៏ខ្ញុំដើរអេះ អង្គុយអេះ រមាស់ដំបៅពេញខ្លួនទាំងអស់។ ហើយពេលដែលគេចែករបបអាហារដូចជាដំឡូងមួយដុំប៉ុនកដៃអ៊ីចឹង ក៏គេមិនអាចឱ្យខ្ញុំងើបឡើងនៅលើគោកហូបដែរ គេឱ្យខ្ញុំឈរហូបនៅក្នុងរណ្ដៅអាចម៍ជ្រូកតែម្ដង។ ពេលនោះខ្ញុំមានអារម្មណ៍ថាវេទនាជាទីបំផុត ត្បិតអីដៃខ្ញុំទាំងសងខាងត្រូវប្រឡាក់សុទ្ធតែអាចម៍ជ្រូក ហើយកាន់ដំឡូងហូប ហើយត្រូវខ្លួនប្រាណរមាស់។ ដល់ពេលគេទម្លាក់បង្គីឱ្យខ្ញុំកើបហ្នឹងគេសុទ្ធតែទម្លាក់ពីលើចុះមកខ្ទាតប្រលាក់ពេញមុខ ពេញក្បាល ធ្វើឱ្យខ្ញុំជួបទុក្ខលំបាកវេទនាមែនទែន ប៉ុន្តែខ្ញុំមិនអាចប្រកែកបាន ខ្ញុំនឹងតស៊ូធ្វើ តស៊ូកើបឱ្យគេ ដើម្បីបានរួចផុតពីការគេជេរស្ដី និងការគេវ៉ៃ។

[១៤:៥៣:០៧]

**សៈ** តើគេមានឱ្យសាប៊ូលោកស្រីសម្រាប់លាងខ្លួនទេ?

**ឆៈ** ចាស អត់បានមានសាប៊ូមានអីទេ អត់មានសាប៊ូដុសខ្លួនដុសក្បាលអីទេ គឺធម្មតាៗអ៊ីចឹង ហើយពេលនោះយើង នាងខ្ញុំអត់មានអាវខោអីហ្នឹងផ្លាស់ទេ។ ខ្ញុំមានតែខោអាវមួយចង្កេះឆ្អេះហ្នឹងខ្លួនហ្នឹងគឺស្លៀកប្រលាក់អ៊ីចឹងហើយ ពេលវេកជីមកដល់ចូលឃ្លាំង ខ្ញុំចុះទៅក្នុងត្រពាំងលាងខ្លួនឱ្យស្អាតអ៊ីចឹងហើយក៏ឈរហាលថ្ងៃឱ្យវាស្ងួតតែម្ដង។

**សៈ** លោកស្រីបានឆ្លើយថានៅពេលដែលលោកស្រីឈឺ គ្រុន ក៏គេបង្ខំឱ្យធ្វើការដែរ។ អ៊ីចឹងតើមុននឹងគេឱ្យធ្វើការតើគេមានផ្ដល់ថ្នាំសង្កូវឱ្យយើងព្យាបាលអីឱ្យជាសិនទេ?

**ឆៈ** ចាស ពេលដែលមានជំងឺគ្រុនក្ដៅ ដូចជាឈឺក្បាលវិលមុខ អស់កម្លាំង ក្ដៅខ្លួនអ៊ីចឹង អត់មានថ្នាំទេ អត់បានមានថ្នាំព្យាបាលទេ។ គឺយើងឈឺធម្មតា ឈឺអ៊ីចឹង ធ្វើការអត់បានឈប់ផង អត់ដឹងថាគេហ្នឹងដឹងថាយើងឈឺ ឬក៏យើងប្រាប់គេថាយើងឈឺក៏អត់បានដែរ ព្រោះអីយើងអត់ហ៊ានប្រាប់គេ។ យើងក៏ត្រូវធ្វើការទាំងឈឺទាំងជាហើយគ្មានថ្នាំព្យាបាលតែម្ដង អត់មានថ្នាំទេ។

[១៤:៥៤:៥៥]

**សៈ** សូមអរគុណលោកស្រី ស៊ីវុត្ថា។ យើងនិយាយអំពីការស្លាប់របស់ប្អូនស្រីរបស់លោកស្រីនៅក្នុងឯកសាររបស់លោកស្រី។ លោកស្រីថា ស្លាប់ដោយសារអត់មានថ្នាំព្យាបាល។ តើលោកស្រី

អាចនិយាយអំពីការស្លាប់របស់ប្អូនស្រីលោកស្រីជម្រាបជូនតុលាការបន្តិចបានទេ?

**ឆ៖** ចាសបាន។ ប្អូនស្រីរបស់ខ្ញុំត្រូវមានជំងឺគ្រុនក្តៅ ហើយពងបែករលាកពេញខ្លួន។ តែអត់មានអ្នកណាមើលថែ ហើយក៏គ្មានថ្នាំព្យាបាល។ ពេលនោះក៏ប្អូនខ្ញុំនៅឈឺរ៉ាំរ៉ៃអ៊ីចឹង ឈឺរហូតស្គមមានតែស្បែកដណ្តប់ឆ្អឹង ហើយត្រូវដាក់ក្នុងអង្រឹងចោល ដោយគ្មានអ្នកមើលថែ។ ពេលនោះក៏អាហារក៏គ្មាន សូម្បីតែបបរយកទៅបញ្ចុកប្អូនក៏អត់មាន។ អ៊ីចឹងធ្វើឱ្យប្អូនឈឺធ្ងន់ទៅៗ រហូតដល់អ្នកម៉ែយកប្អូនស្រីទៅពេទ្យ។ គិតថាទៅពេទ្យហ្នឹងប្រហែលជាមានថ្នាំអត់ព្យាបាលបាន ប៉ុន្តែអត់មានថ្នាំព្យាបាលទេពេលនោះ ធ្វើឱ្យប្អូនស្រីខ្ញុំស្លាប់តែម្តង។

[១៤:៥៦:២២]

**ស៖** សូមអរគុណ។ ក្រៅពីបាត់បង់ភ្នែកលោកស្រី តើលោកស្រីមានជំងឺអ្វីផ្សេងទៀតដែលកើតឡើងកើតឡើងដោយសាររបបខ្មែរក្រហមដែរឬទេ?

**ឆ៖** ចាសមាន។ សព្វថ្ងៃ ខ្ញុំមានជំងឺធ្ងន់ធ្ងរនៅក្នុងខ្លួន។ ទី១ ត្រចៀករបស់ខ្ញុំមានអាការៈស្រៀវមកពីសរសៃភ្នែក មកពីសរសៃក្បាលហ្នឹង ស្រៀវៗជាប្រចាំ ហើយជួនក៏ហ៊ឹង ជួនក៏ស្រៀវ ហើយធ្វើឱ្យខ្ញុំពិបាកដកដង្ហើម។ ពេលដង្ហើមខ្ញុំដក ដកផុតៗ ដកអត់ដល់គ្នា។ ធ្វើឱ្យខ្ញុំរៀងដូចស្ទះៗ ហើយខ្ញុំមានអារម្មណ៍ថាពិបាកនឹងរស់មែនទែន ពេលដែលខ្ញុំបាត់បង់ភ្នែក។ ពេលដែលខ្ញុំបាត់បង់អ្វីៗគ្រប់យ៉ាង។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំលែងចង់រស់ ខ្ញុំសម្រេចចិត្តទិញថ្នាំកណ្តុរ ទិញថ្នាំដង្កូវយកមកសម្លាប់ខ្លួន។ ប៉ុន្តែខ្ញុំបានបងស្រី និងម្តាយ គាត់បានណែនាំថាមិនឱ្យខ្ញុំធ្វើបែបនេះ រស់ដើម្បីមើលថែកូន។ អ៊ីចឹងហើយ ខ្ញុំសម្រេចចិត្តថាទ្រាំរស់តទៅទៀតនៅក្នុងសភាពវេទនា។ ហើយការឈឺរបស់ខ្ញុំនេះ សព្វថ្ងៃខ្ញុំមិនអាចមានសមត្ថភាពទៅពេទ្យព្យាបាល ឬក៏ទៅទិញថ្នាំអ្វីយកមកព្យាបាលជំងឺខ្ញុំដែរ។ ត្បិតអី ខ្ញុំឈឺនេះ បើតាមពិតទៅមិនដឹងជាឈឺបែបណា។ បើយប់ឡើង ខ្ញុំដេកតែងតែយល់សប្តិអាក្រក់ៗ ហើយដូចថាចេះតែធ្លាក់ផ្អើម។ សូម្បីតែសំឡេងបើកទ្វារខ្លាំង ក៏ខ្ញុំធ្លាក់ផ្អើមភ្ញាក់ៗ ហើយញ័រសាច់ ជួនកាលមានអារម្មណ៍អត់ល្អធ្វើឱ្យខឹងកូន អាចវ៉ៃកូន បើមិនវ៉ៃដូចថាអារម្មណ៍របស់ខ្ញុំអត់ស្ងប់។

[១៤:៥៨:២០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី អរគុណដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីដប់ប្រាំនាទី សូមអញ្ជើញចូល

វិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ រួមទាំងបុគ្គលិក ធី.ភី.អូ ដែលនៅអមដើមបណ្តឹងរដ្ឋប្បវេណីសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅ វេលាម៉ោងបី និងដប់ប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៩ នាទី ដល់ម៉ោង ១៥:១៧ នាទី)*

[១៥:១៧:២៨]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងប្រគល់វេទិកាជូនទៅក្រុម មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីអាចបន្តការតាំងសំណួរដេញដោលចំពោះកូនក្តីរបស់ខ្លួន។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថា សរុបទាំងពេលវេលាសួរហើយនិងឆ្លើយតបរបស់ជនជាប់ចោទផង មានពេល១៥នាទីទៀត។

**លោក អេមម៉ានូអ៊ែល ហ្សាកូមី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អេមម៉ានូអ៊ែល ហ្សាកូមី៖**

**ស៖** លោកស្រីក្នុងរយៈពេល១៥នាទីដែលនៅសល់នេះ ខ្ញុំសូមសួរលោកស្រីដោយខ្លីៗពាក់ព័ន្ធ ទៅនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយនិងលក្ខខណ្ឌរស់នៅរបស់លោកស្រីនៅភូមិតាម៉េង។ លោកស្រីបាននិយាយអំពីការជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយលោកស្រីថាឃើញអ្នកជំងឺ ឃើញ

មនុស្សចាស់ជរានៅតាមដងផ្លូវ។ តើលោកស្រីអាចពន្យល់បានទេថា តើមានហេតុការណ៍អ្វីកើតឡើងចំពោះអ្នកទាំងអស់នុ៎ង? គេទុកគាត់ចោលនៅតាមផ្លូវ នៅតាមចិញ្ចើមផ្លូវ ឬក៏មានអ្នកមើលថែពួកគាត់ខ្ញុំសំដៅដល់មនុស្សចាស់ជរា ហើយនិងអ្នកមានជំងឺ?

[១៥:១៩:១៨]

**លោកស្រី សេង ស៊ីវត្ថា ៖**

**ឆ៖** ចាស ការដែលជម្លៀសចេញពីទីក្រុងភ្នំពេញ ខ្ញុំបានជួបប្រទះនូវរឿងហេតុយ៉ាងច្រើន។ ត្បិតអីថ្ងៃនោះពេលចេញហ្នឹង ព្រលឹមឡើងគឺធ្វើដំណើរចេញតែម្តង។ ពេលដែលចេញហ្នឹងឃើញមានអ្នកស្លាប់តាមផ្លូវថ្នល់ហ្នឹង គឺអ្នកស្លាប់ច្រើន ហើយកណ្តាលថ្នល់ក៏មានអ្នកស្លាប់ កៀនតាមចិញ្ចើមថ្នល់ហ្នឹងក៏មានអ្នកស្លាប់ ហើយក៏មានអ្នកដេកដែលមិនទាន់ស្លាប់ដូចជាចាស់ជរា មានយាយ មានតា មានជនពិការ មានអ្នកស្វិតជើង ស្វិតដៃអ៊ីចឹង។ មិនដឹងជាអ្នកណាគេដាក់ចោលទេ ប៉ុន្តែឃើញតែដេកតាមចិញ្ចើមថ្នល់អ៊ីចឹងទៅ ខ្លះក៏ជិតស្លាប់ ខ្លះក៏ស្លាប់បាត់បង់ជីវិតហើយ អ្នកខ្លះក៏នៅអង្គុយដោយអត់អាហារហើយគ្មាន ដូចថាថ្ងៃក្តៅខ្លាំង ហើយទឹកភ្នែកហូរហៅកូន ហៅអីអ៊ីចឹង ប៉ុន្តែមិនដឹងថា ក្រុមគ្រួសារគេនៅឯណាទេ គ្រាន់តែឃើញសភាពបែបហ្នឹង។ ហើយមានតាចាស់ម្នាក់ ខ្ញុំសង្វេគក្នុងចិត្តដល់សព្វថ្ងៃឃើញគាត់ដេក ហើយគាត់បើកភ្នែកសម្លឹងមើលខ្ញុំ ហើយមានបាយមួយចានទឹកមួយកំប៉ុងវីហ្គោនៅក្បែរក្បាលដេកគាត់។ ហើយស្រមោចចូលខាំត្រចៀកគាត់ ពេលហ្នឹងខ្ញុំអែអង់ទាញសង្រែកម៉ាក់យាយខ្ញុំបែរមើលគាត់ហ្នឹង ឃើញមានស្រមោចចូលខាំគាត់ ខាំភ្នែក ខាំត្រចៀកគាត់ហ្នឹង ហើយក្នុងចិត្តរបស់ខ្ញុំក្នុងអារម្មណ៍របស់ខ្ញុំហ្នឹង ដូចថា ឃើញបែបហ្នឹង ខ្ញុំដើរបណ្តើរខ្ញុំយំបណ្តើរ។

[១៥:២០:៥០]

ហើយពេលដើរទៅទៀត ក៏ឃើញមានអ្នកស្លាប់ និយាយទៅឃើញអ្នកស្លាប់បន្តបន្ទាប់តាមផ្លូវតែរហូត អត់មានថាអត់ឃើញទេ។ ហើយបើមិនអ៊ីចឹងបានថា ឲ្យខ្ញុំដើរទៅជាន់ខ្មោច ពារខ្មោច ជំពប់ខ្មោចដួលហ្នឹងដោយក្តីសង្វេគណាស់ ខ្ញុំពេលនោះ។

**ស៖** សូមអរគុណលោកស្រី ស៊ីវត្ថា មុននេះបន្តិចនេះលោកស្រីថា គេបំបែកលោកស្រីចេញពីគ្រួសារ តើលោកស្រីអាចបញ្ជាក់បានទេថា នៅពេលណាដែលគេបំបែកលោកស្រីនោះ? ហើយតើលោកស្រីមានបញ្ហាអ្វីដែរនៅពេលដែលគេបំបែកចេញពីគ្រួសារបែបនេះ ទាំងនៅក្មេងដូច្នេះនោះ?

**ឆ៖** ចាស ពេលដែលខ្ញុំត្រូវបែកពីក្រុមគ្រួសារ ពេលនោះខ្ញុំទៅដល់ភូមិតាម៉េង ស្រុក១០៩ ខេត្ត

តាកែវ។ ពេលទៅដល់ហ្នឹង ខ្ញុំត្រូវគេប្រមូលឲ្យទៅនៅកង ឪពុកម្ដាយទៅផ្សេង បងស្រីទៅផ្សេងបែកៗគ្នាអស់រលីង អត់មានសល់ទេ អ្នកនៅក្នុងផ្ទះគឺគ្មាន គ្មានសូម្បីតែមនុស្សមួយអត់មានផងនៅក្នុងផ្ទះហ្នឹង។ ហើយពេលនោះ ខ្ញុំក៏គេបានបញ្ជូនទៅនៅកងដោយមិនទាន់គ្រប់អាយុទើបតែបាន៩ឆ្នាំទេ កាលចេញពីភ្នំពេញ។

[១៥:២២:១០]

ពេលដែលខ្ញុំទៅនៅកងហ្នឹង គេឲ្យទៅដេកនៅវត្តកាប៉េង។ ពេលទៅដេកនៅវត្តកាប៉េងហ្នឹងគ្មានខោអាវជាប់ទៅនឹងខ្លួនទេ ទៅតែខ្លួនទទេ ហើយត្រូវដេកលើឥដ្ឋ ហើយរងាខែនុំងខែវស្សា រងាញាក់ញ័រ ពេលខ្ញុំដេកបាន១យប់ ខ្ញុំមានអារម្មណ៍ថា ខ្ញុំនឹកផ្ទះ នឹកម្ដាយ នឹកម៉ាក់យាយខ្ញុំ ជាពិសេសនឹកម៉ាក់យាយខ្ញុំ។ ខ្ញុំដេកយំអស់រយៈមួយយប់ទាល់ភ្លឺ ខ្ញុំដេកយំ ភ្ញាក់ដឹងខ្លួនថ្មើរណាខ្ញុំដេកយំទឹកភ្នែកខ្ញុំហូររហាម តែខ្ញុំមិនអាចវិលត្រឡប់មកភូមិវិញបាន ត្បិតអីមានគេមើល មានគេបង្ខំឲ្យទៅមុខរហូត។ មានគេត្រូវបង្ខំឲ្យខ្ញុំធ្វើដំណើរទៅច្រកជីគាំតទៅទៀត។ ពេលនោះ ខ្ញុំទៅដល់កងច្រកជីគាំហ្នឹងក៏ខ្ញុំនៅក្នុងអារម្មណ៍របស់ខ្ញុំ គឺនឹកផ្ទះ នឹកឪពុកម្ដាយ បើខ្ញុំអត់ដែលមានបែកឪពុកម្ដាយ ហើយខ្ញុំត្រូវទៅធ្វើការដូចមនុស្សចាស់មិនស្គាល់យប់ មិនស្គាល់ថ្ងៃ ហើយអាហារហូបអត់គ្រប់គ្រាន់ មិនបានហូបផង ហូបតែបបរលាយមួយវែកៗហ្នឹងទឹករាវកក្លក ខ្ញុំមានការហេវហត់ហើយ ត្រូវបែកឪពុកម្ដាយអស់រលីងពីខ្លួន ហើយខ្ញុំសង្វេគក្នុងចិត្ត អារម្មណ៍របស់ខ្ញុំគឺទឹកភ្នែករហូតពេលដែលខ្ញុំដេកយប់ឡើង។ ទឹកភ្នែករហូតប៉ុន្តែខ្ញុំមិនអាចវិលត្រឡប់មកភូមិវិញបាន។

[១៥:២៣:៣៥]

**ស៖** សូមអរគុណលោកស្រី។ ក្នុងភូមិតាម៉េង ដែលលោកស្រីរស់នៅបន្ទាប់ពីជម្លៀសចេញពីទីក្រុងភ្នំពេញ តើមានមនុស្សប្រភេទផ្សេងៗគ្នាដែរឬទេ? ហើយប្រសិនបើមានតើមានការប្រព្រឹត្តខុសគ្នាយ៉ាងម៉េចដែរចំពោះប្រភេទប្រជាជនផ្សេងៗគ្នានេះ?

**ឆ៖** ចាស ពេលដែលខ្ញុំរស់នៅក្នុងរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃ នេះ អ្នក១៧មេសា ដូចជាខ្ញុំនេះរស់ក្នុងសភាពលំបាកវេទនាដោយហូបអាហារអត់គ្រប់គ្រាន់ គេចែកមានរបបចែក តែអ្នកមូលដ្ឋានអត់ទេ។ អ្នកមូលដ្ឋានត្រូវហូបរបបផ្សេង តែគេហូបបែបណាខ្ញុំអត់បានដឹងទេ គ្រាន់តែដឹងថា គេហូបមួយជួរផ្សេងទៅ មួយផ្នែកផ្សេងអ៊ីចឹងទៅ។ ពួកអ្នក១៧ មេសា ហូបផ្សេង។ ហើយការធ្វើការក៏អ៊ីចឹងដែរ អ្នក១៧មេសា ត្រូវធ្វើការផ្សេង។ អ្នកមូលដ្ឋានគេនឹងមើលថៃយើង គេនឹងបញ្ជាលើយើង គេអត់បានធ្វើដូចយើង

ទេ។ គេដើរបញ្ជាលើយើង ប្រាប់យើងអ៊ីចឹង តែគេក៏ធ្វើការដែរ តែគ្រាន់ថាមិនធ្វើដូចយើងអ៊ីចឹងទេ។

**ស៖** សូមអរគុណ។ លោកស្រីបានបញ្ជាក់ថា លោកបានចូលរួមក្នុងការប្រជុំស្វ័យទិតៀន ហើយប្រសិនបើបោកប្រាស់គេនោះ គេវាយ។ អ៊ីចឹងតើលោកស្រីអាចបញ្ជាក់បានទេ នៅពេលណាដែលលោកស្រីច្រឡំនោះ?

[១៥:២៥:១៨]

**ឆ៖** ចាសនៅកងច្រកជីគាំ ពេលយប់ឡើងដូចថាមកពីធ្វើការហេវហត់អ៊ីចឹងហើយ យប់ឡើងម៉ោងប្រាំបីហ្នឹងអត់ទាន់បានសម្រាកចូលដេកទេ គេឲ្យយើងប្រជុំអង្គុយតម្រៀបជួរគ្នាប្រជុំ ហើយមានប្រធានអ្នកឈរឲ្យយើងស្វ័យទិតៀន និងទិតៀន។ ពេលនោះដែរខ្ញុំតែងតែគេទិតៀនខ្ញុំ ត្បិតអីដូចថាខ្ញុំខ្លាចឈ្លើង ខ្ញុំធ្វើការអីដូចថាយឺតយ៉ាវអ៊ីចឹង គេតែងតែទិតៀនខ្ញុំ។ ហើយខ្ញុំអត់ដឹងថាគេធ្វើខុសមិនធ្វើខុសអីទេ ពេលខ្ញុំនៅក្មេង ខ្ញុំឃើញតែគេទិតៀនខ្ញុំ ខ្ញុំទិតៀនគេវិញ។ ពេលខ្ញុំទិតៀនខុសអ៊ីចឹង ប្រធានគេអាចវ៉ៃខ្ញុំ គេថាខ្ញុំនិយាយអត់ត្រឹមត្រូវ។

**ស៖** លោកស្រី សេង នេះជាសំណួរចុងក្រោយ។ តើលោកស្រីរំពឹងចង់បានអ្វីពីតុលាការនេះ?

**ឆ៖** ចាសនៅនាទីចុងក្រោយនេះ ខ្ញុំទន្ទឹងឲ្យតុលាការកាត់ក្ដីសាលាក្ដីខ្មែរក្រហមនេះសូមឲ្យបានលឿនជាទីបំផុត ហើយខ្ញុំក៏សប្បាយចិត្តដែរ ដែលខ្ញុំបានលើកឡើងមកសវនាការនេះ។ ហើយមួយទៀតខ្ញុំក៏ចង់បញ្ជាក់ថា ពេលដែលខ្ញុំធ្លាក់ខ្លួនពិការភ្នែក មើលអ្វីមិនឃើញនេះ ដោយក្នុងរបប៣ឆ្នាំ៨ខែ២០ថ្ងៃ។ ខ្ញុំចង់បញ្ជាក់ថា តើបានអ្នកណាជួយចិញ្ចឹមខ្ញុំ បើខ្ញុំរងទុក្ខលំបាកវេទនាដោយក្ដីលំបាករកទីបំផុតគ្មានបែបនេះ។

[១៥:២៧:២៤]

**លោក អេម៉ានូអ៊ែល ហ្យាកូមី៖**

សូមអរគុណលោកស្រី សេង ស៊ីវត្ថា។ ខ្ញុំអស់សំណួរហើយ ខ្ញុំដឹងថាជាការលំបាកណាស់ក្នុងការផ្ដល់សក្ខីកម្មនៅថ្ងៃនេះចំពោះលោកស្រីនោះ។

លោកប្រធានលោកស្រីគាត់ចង់សួរសំណួរពីរទៅកាន់ជនជាប់ចោទ។ ដូច្នេះសូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយលោកស្រី ស៊ីវត្ថា សូមលោកស្រីតាំងសំណួរដែលលោកស្រី

មានបំណងសួរនោះតាមរយៈរូបយើង ប្រធានអង្គជំនុំជម្រះ មិនអាចធ្វើផ្ទាល់សំដៅទៅគាត់ដោយផ្ទាល់តែម្តងបានទេ។ សូមអញ្ជើញ!

**លោកស្រី សេង ស៊ីវត្ថា៖**

ខ្ញុំចង់សួរសំណួរមានពីរ។ សំណួរទី១ ខ្ញុំចង់សួរថាហេតុអ្វីបានសម័យនោះ របបនោះត្រូវបង្ខំឲ្យក្មេងដែលមិនទាន់គ្រប់អាយុដូចជារូបខ្ញុំត្រូវធ្វើដូចមនុស្សចាស់? ហើយសំណួរទី២ ខ្ញុំចង់សួរថាហេតុអ្វីដែលភោគផលដែលធ្វើបាននោះ គឺច្រើនណាស់ តើយកទៅណាបានមិនឲ្យពួកយើងខ្ញុំហូប?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី។ អង្គជំនុំជម្រះសូមបញ្ជូននូវសំណួរនេះទៅជនជាប់ចោទ ដើម្បីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយជាដំបូងនេះបញ្ជូនសំណួរទៅលោក ខៀវ សំផន។ សូមអញ្ជើញលោក ខៀវ សំផន!

[១៥:២៩:០២]

**លោក ខៀវ សំផន៖**

បាទសូមគោរពលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព សូមគោរពអង្គសវនាការទាំងមូល។ សូមជម្រាបសួរលោកស្រី សេង ស៊ីវត្ថា។

រឿងរ៉ាវដែលលោកស្រីបានរៀបរាប់នេះ ធ្វើឲ្យខ្ញុំក្តុកក្តួលក្នុងចិត្តខ្លាំងណាស់។ ខ្ញុំមិនដឹងទាល់តែសោះថាគេប្រើកូនក្មេងឲ្យធ្វើការដូចលោកស្រីមានប្រសាសន៍យ៉ាងនេះ។ អាយុទើបតែ១១ឆ្នាំ គេឲ្យចុះទៅក្នុងរណ្តៅអាចម៍ជ្រូក រែកអាចម៍ជ្រូក រែកហើយដួល គេវ៉ៃៗទាល់តែលោកស្រីពិការភ្នែក។ ជើងលោកស្រីហើម ដើរបុាំងពៀចៗស្ទើរតែមិនរួចហើយ គេនៅតែបង្ខំឲ្យលោកស្រីធ្វើការទៀត។ ខ្ញុំនឹកស្មានមិនដល់ទាល់តែសោះហើយ។ ដូច្នេះ នេះជាចម្លើយទី១ ចំពោះសំណួរទី១របស់លោកស្រី។

លោកស្រីមានប្រសាសន៍ថា លោកស្រីខំធ្វើការបង្កបង្កើនផលបានស្រូវច្រើន ហេតុម៉េចក៏គេបង្អត់បាយលោកស្រីទៅវិញ? សភាពការណ៍មុនដំបូង វាលំបាកអ៊ីចឹងមែន ក៏ប៉ុន្តែពីមួយឆ្នាំទៅមួយឆ្នាំក៏សភាពការណ៍វាប្រែប្រួលមកល្អគ្រាន់បើដែរ គួរណាស់តែគេឲ្យ គេជូនលោកស្រីពិសាដូចប្រជាជនយើងផ្សេងទៀតដែលខំធ្វើការនោះ ពិសាឲ្យបានគ្រប់គ្រាន់។ អាម៉េចបានជាបង្អត់បាយប្រជាជនអ៊ីចឹងទៅវិញ ស្រូវហ្នឹងគេយកទៅណា? អានេះក៏ខ្ញុំឆ្លើយជូនលោកស្រីមិនរួចដែរ សូមលោកស្រីអធ្យាស្រ័យដល់ខ្ញុំផងចុះ។ សូមទោសលោកស្រី។ សូមអរគុណលោកប្រធាន។

[១៥:៣២:០៩]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ បាទ ជាបន្តនេះ អង្គជំនុំជម្រះសូមបញ្ជូននូវសំណួរនេះ ជូនទៅលោក នួន ជា ដើម្បីឆ្លើយតបទៅនឹងសំណួរនេះ។ សូមអញ្ជើញលោក នួន ជា។ លោក នួន ជា កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំបានជម្រាបថា គាត់មិនចង់ឆ្លើយនូវសំណួររបស់ -- សំណួរនេះទេ ដោយសារតែគាត់អស់កម្លាំងខ្លាំង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី វ៉ិចទ័រ កូប៉េ។

បាទ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងអយ្យការដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

បាទ ខ្ញុំសូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។

[១៥:៣៣:១៧]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ជម្រាបសួរលោកស្រី សេង ស៊ីវុត្ថា! ខ្ញុំឈ្មោះ ច័ន្ទ តារាស្មី ជាសហព្រះរាជអាជ្ញារងជាតិនៃអង្គជំនុំជម្រះក្នុងតុលាការកម្ពុជា ហៅថា សាលាក្តីខ្មែរក្រហមនៅទីនេះ។ ខ្ញុំសូមលោកស្រីនូវសំណួរមួយចំនួនក្នុងនាមតំណាងឲ្យសហព្រះរាអាជ្ញា។ សូមលោកស្រីជួយបញ្ជាក់ជូនអង្គសវនាការបន្ថែមទៀត ថានៅពេលដែលគេបញ្ជូនលោកស្រីទៅរស់នៅក្នុងសណ្ឋាគារកាំបូឌីយ៉ាណានៅភ្នំពេញ នៅចន្លោះឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ តើក្នុងការរស់នៅទីនោះ លោកស្រីជួបនូវស្ថានភាពបែបណាខ្លះបាទ?

**លោកស្រី សេង ស៊ីវុត្ថា៖**

**ឆ៖** ចាស ក្នុងឆ្នាំ១៩៧២ ខ្ញុំបានមករស់នៅក្នុងកាំបូឌីយ៉ាណា រស់ក្នុងលក្ខណៈជនភៀសខ្លួន

ប៉ុន្តែនៅពេលនោះ មានអង្គការសហប្រជាជាតិ អន្តរជាតិអាមេរិកាំងបានជួយចិញ្ចឹមពួកប្រជាជនដែលនៅក្នុងកាំបូឌីយ៉ាណាហ្នឹងទាំងអស់គ្នា មិនឲ្យពិបាក មិនឲ្យខ្វះការហូបចុកទេ ត្បិតអីពេលនោះ សូម្បីតែត្រៃ មុង ភួយ កន្ទេលអី គឺបើកសព្វគ្រប់ទាំងអស់ ខោអាវសម្លៀកបំពាក់អី គឺបើកទាំងអស់។ អង្ករ ត្រីងៀត អ្វីៗគ្រប់យ៉ាង គឺឲ្យតែរបស់ប្រើប្រាស់ របស់ត្រូវការ មនុស្សប្រើការហ្នឹងគឺមានសព្វគ្រប់ទាំងអស់មិនដែលឲ្យខ្វះទេ។ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅក្នុងកាំបូឌីយ៉ាណានេះ គឺមានសភាពធូរសប្បាយ ហើយអត់មានពិបាកទេ សូម្បីតែពួកបងស្រីខ្ញុំកាលនោះ ហើយនិងខ្ញុំនៅរៀន ក៏ខាងអង្គការហ្នឹងក៏ជួយដែរ ជួយចិញ្ចឹមហើយ ក៏ជួយផ្តល់ការសិក្សា តាំងពីសៀវភៅ កាតាប សម្លៀកបំពាក់សព្វបែបយ៉ាងទាំងអស់ គឺមិនឲ្យខ្វះខាតអ្វីទាំងអស់។ អ៊ីចឹងក្រុមគ្រួសារខ្ញុំរស់នៅក្នុងកាំបូឌីយ៉ាណានេះ ក្នុងសភាពសប្បាយរីករាយ ដោយមានអង្គការកាកបាទក្រហមអាមេរិកាំងជួយចិញ្ចឹម។

[១៥:៣៥:១៣]

**ស៖** បាទ សូមអរគុណ។ សូមលោកស្រីជួយបញ្ជាក់បន្ថែមថា បើប្រៀបធៀបជាមួយនឹងការរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការរស់នៅរបស់លោកស្រីនៅក្នុងសណ្ឋាគារកាំបូឌីយ៉ាណា តើលោកស្រីមានការចាប់អារម្មណ៍យ៉ាងដូចម្តេចជាមួយនឹងស្ថានភាពនៃការរស់នៅប្រៀបធៀបជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ចាស បើសិនជាខ្ញុំត្រូវប្រៀបធៀបកាលពីរបបមុនថ្ងៃ ១៧ មេសា និងរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃ បើតាមពិតទៅរបបទាំងពីរនេះខុសគ្នាដូចមេឃនឹងដីអត់មានក្បែរគ្នាបានទេ ត្បិតអីទៅដល់របបនោះយើងអត់បានទៅរៀន អត់បាននៅជាមួយឪពុកម្តាយ អត់មានការកក់ក្តៅពីឪពុកម្តាយ និងបងប្អូន។ ហើយមួយទៀតត្រូវអត់មានអីហូប បើគេឲ្យហូបក៏ហូបបបរលាយពោត លាយដំឡូង លាយអ្វីដែលអាចលាយបានដូចជា ព្រលិត ត្រកួនអ៊ីចឹង។ មិនអាចប្រៀបធៀបនឹងសម័យនោះបានទេ សម័យដើមបានទេ សម័យលន់នល់បានទេ។

[១៥:៣៦:២០]

**ស៖** បាទ សូមអរគុណ។ លោកស្រី ស៊ីវុត្ថា នៅពេលដែលគេឲ្យលោកស្រីចាកចេញពីទីក្រុងភ្នំពេញតាមរូបភាពនៃការជម្លៀស តើទាហានខ្មែរក្រហមបានដាក់បទបញ្ជាយ៉ាងដូចម្តេចខ្លះចំពោះ លោកស្រី? ហើយតើការបញ្ជានោះលោកស្រីអាចប្រកែកតវ៉ាបានដែរឬទេ ឬមួយក៏មានលក្ខណៈដាច់ខាតថាត្រូវតែអនុវត្តតាមបាទ? សូមលោកស្រីជួយបញ្ជាក់។

**ឆ៖** ចាស នៅពេលនោះដែរនាងខ្ញុំនៅតូចអត់សូវបានដឹងច្បាស់ពីរឿងហេតុការណ៍ហ្នឹងទេ។ គ្រាន់តែខ្ញុំបានឃើញរូបភាពពេលហ្នឹងដែរ។ ពេលព្រឹកមានកងទ័ព -- កាលនោះខ្ញុំអត់ស្គាល់ថាទ័ពខ្មែរក្រហមអីណា ខ្ញុំអត់ស្គាល់ទេ គ្រាន់តែឮសូរថាកងទ័ពរំដោះ មករំដោះពុកម៉ែឲ្យចេញផុតពីទីក្រុងភ្នំពេញ។ អីចឹងពុកម៉ែចេញពីភ្នំពេញមួយរយៈសិន ពួកកូនៗរំដោះពុកម៉ែចេញនេះដើម្បីបោសសម្អាតខ្មាំងសក្តិភូមិនាយទុន។ ខ្ញុំគ្រាន់តែដឹងថាប៉ុណ្ណឹង។ ហើយពេលហ្នឹងសុំឲ្យចេញមួយរយៈពេលបោសសម្អាតរួចហ្នឹងវិលត្រឡប់ចូលមកវិញ។

[១៥:៣៧:៣២]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលគេធ្វើការជម្លៀសលោកស្រីចេញពីទីក្រុងភ្នំពេញនៅតាមដងផ្លូវ តើទាហានខ្មែរក្រហមបានតាមដានឃ្លាំមើល ត្រួតពិនិត្យ ឬក៏គ្រប់គ្រងប្រជាជនដែលត្រូវធ្វើការជម្លៀសតាមដងផ្លូវហ្នឹងរហូតដល់គោលដៅចុងក្រោយដែរឬទេបាទ?

**ឆ៖** ចាស កាលហ្នឹងខ្ញុំមិនបានសង្កេតដឹងច្បាស់ទេត្បិតអីខ្ញុំនៅតូច។ ខ្ញុំគ្រាន់តែឃើញមានដាក់មីក្រូស្រែកតាមឡាន មានដាក់មីក្រូលើឡានអីចឹង ហើយស្រែកថា សូមឲ្យបងប្អូនប្រជាជនហ្នឹងធ្វើដំណើរ អ្នកណានៅច្រកណាចេញតាមច្រកហ្នឹងមិនអាចច្របូកច្របល់បញ្ច្រាសទិសគ្នាបានទេ។ ហើយពេលធ្វើដំណើរហ្នឹងយើងអត់ដឹងថាបែបណាទេ ខ្ញុំអត់បានដឹងដែរគ្រាន់តែថា ធ្វើដំណើរចេះតែទៅមុខអីចឹងរហូតមិនអាចឈប់បាន។ លុះដល់កន្លែងណាដែលយើងអាចឈប់បាន ដូចថាវាលអាចប្រជ្រៀតចេញទៅខាងក្រៅឈប់បាន ក៏ឈប់បានហ្នឹងសម្រាប់តែឈប់ដាំបាយធ្វើអីហូបមួយភ្លែតទេ យើងមិនអាចឈប់នៅទីនេះបាន។ មានមីក្រូហ្នឹងស្រែកឲ្យយើងធ្វើដំណើរតទៅមុខទៀត។

[១៥:៣៨:៤៧]

**ស៖** លោកស្រី ស៊ីវុត្ថា តើលោកស្រីធ្លាប់បានឮ ឬក៏លោកស្រីនៅចងចាំដែរឬទេ តើរបបខ្មែរក្រហម ឬក៏ទាហានខ្មែរក្រហមធ្លាប់ប្រើពាក្យថា សេរីកា ចក្រពត្តិនិយម សក្តិភូមិ ឬក៏ពួកនាយទុន ឬក៏ពួក១៧មេសាអី តើគេបានប្រើពាក្យនេះក្នុងន័យអ្វីដែរ ឬក៏លោកស្រីបានឮគេនិយាយក្នុងន័យផ្សេងទៀតបាទ?

**ឆ៖** ចាស ដូចថា កងទ័ពសេរីកាអីម៉េចៗហ្នឹង ខ្ញុំអត់ស្គាល់ទេ ខ្ញុំអត់បានដឹងទេ កាលនោះត្បិតអីខ្ញុំគ្រាន់តែបានពេលដែលនៅក្នុងរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃហ្នឹង ខ្ញុំបានឮគេនិយាយថា ពួកសក្តិភូមិនាយទុនប្រតិកិរិយា ហើយនិងពួក១៧មេសា គឺជាពួក គេថាពួកនាយទុន។ ហ្នឹងហើយខ្ញុំគ្រាន់តែដឹងតែ

ប៉ុណ្ណឹង គ្រាន់តែឮថាគេស្ដីឲ្យ និយាយទៅស្ដីឲ្យខ្ញុំផ្ទាល់តែម្ដង។ អ្នកចេញពីទីក្រុងភ្នំពេញទៅ គឺគេថាអ្នក ១៧ មេសា ហ្នឹងសុទ្ធតែពួកសក្ដិភូមិ។

**ស៖** អរគុណលោកស្រី។ លោកស្រីជួយបញ្ជាក់បន្ថែមថា ហេតុអ្វីបានជាគេបញ្ជូនលោកស្រីទៅតំបន់១០៩ នៅតាកែវ?

[១៥:៤០:១៧]

**ផ៖** កាលនោះខ្ញុំអត់បានដឹងដែរ ប៉ុន្តែគ្រាន់តែអ៊ីចេះ ប្រជាជនយើងដែលយើងចេញពីទីក្រុងភ្នំពេញទៅហ្នឹង បើអ្នកទៅតាមផ្លូវជាតិលេខ៣ គេតែងតែយកទៅខេត្តតាកែវ យកទៅដាក់នៅ១០៩។ តែបើអ្នកទៅខាងផ្លូវផ្សេងៗទៀត អាហ្នឹងគេយកទៅផ្សេងអ៊ីចឹងទៅទៀតអ៊ីចឹងទៅ។ ខ្ញុំអត់បានយល់ដឹងកន្លែងហ្នឹងទេ ដោយគ្រាន់ថាដើរទៅអ៊ីចឹង ដល់គោលដៅត្រឹមកន្លែងជិតទន្លេងបាទីហ្នឹង ឃើញមានឡានជេ.អឹម.សេ ច្រើនចតនៅតាមថ្នល់អ៊ីចឹង។ គេក៏បានបង្ខំឲ្យឡើងឡានៗថា ពុកម៉ែជញ្ជូនកូនចៅ នាំគ្នាឡើងឡាន ពួកយើងនឹងនាំយកពុកម៉ែទៅតាមជនបទ។

**ស៖** បាទសូមអរគុណ។ លោកស្រីបានឆ្លើយនៅក្នុងឯកសារថា លោកស្រីធ្លាប់បានគេបញ្ជូនទៅនៅតំបន់១០៥រស់នៅទីនោះបន្ថែមទៀត នៅក្នុងធ្វើការនៅទីនោះ។ តើតំបន់១០៥ និង១០៩ហ្នឹង តើវាខុសគ្នាយ៉ាងដូចម្ដេច?

**ផ៖** ចាស តំបន់១០៩ និង១០៥ហ្នឹង បើតាមពិតទៅ ដូចជាអត់មានខុសគ្នាកន្លែងណាទេ។ ដូចតែមួយ សភាពហេវហត់ អត់បាយអ្វី ធ្វើការធ្ងន់ធ្ងរអីហ្នឹងក៏ដូចតែគ្នា។ ការដែលគេឲ្យយើងហូបចុកហ្នឹង ក៏អត់មានៗ គេធ្វើអ៊ីចឹងដូចតែគ្នា ដូច១០៩ ហើយ១០៥ហ្នឹង បើតាមពិតទៅដូចជាគោលការណ៍តែមួយ។

[១៥:៤១:៥០]

**ស៖** បាទសូមអរគុណ។ លោកស្រីៗបានបញ្ជាក់ថា លោកស្រីបានបាត់បង់ជីដូន ជីតា។ តើការបាត់បង់ជីដូន ជីតានេះបណ្ដាលមកពីមូលហេតុអ្វីបានជាបាត់បង់ជីដូន ជីតានោះ?

**ផ៖** ចាស ការដែលខ្ញុំបាត់បង់ជីដូនជីតា សាច់ញាតិយ៉ាងច្រើន ក្រុមគ្រួសារ, បាត់បង់នោះ ខ្ញុំអត់បានដឹងថាគាត់បាត់បង់របៀបគេយកទៅសម្លាប់ ឬមួយក៏គេបង្អត់អាហារស្លាប់ទេ។ ប៉ុន្តែក្នុងឆ្នាំមួយពាន់ប្រាំបួនរយ -- មុនថ្ងៃរំដោះភ្នំពេញហ្នឹង បងប្អូនក្រុមគ្រួសារខ្ញុំហ្នឹង តែងតែជិះស៊ីក្លូទៅលេងគ្នាទៅវិញទៅមក បបួលគ្នាទៅមើលកុនអីអ៊ីចឹង ជុំគ្នា។ តែដល់ពេលថ្ងៃ១៧ មេសា ហ្នឹងមកដល់ ក៏រត់បែក

ខ្លាយគ្នាអស់អ៊ីចឹងទៅ។ ហើយក៏បែកគ្នារហូតអ៊ីចឹងទៅ រហូតដល់បីឆ្នាំប្រាំបីខែហ្នឹងផុតអ៊ីចឹងទៅ។ ដល់៧៩ ម៉ាក់យាយខ្ញុំ ខ្ញុំអីហ្នឹងក៏នៅឈរចាំមើលនៅស្រុកកំណើតហ្នឹង ឈរចាំនៅតាមថ្នល់ ឃើញបងប្អូនគេមកអ៊ីចឹង។ មានបងប្អូនគេមកខ្លះៗអ៊ីចឹង តែបងប្អូនក្រុមគ្រួសារខ្ញុំអត់ឃើញទេ បាត់រហូតដល់សព្វថ្ងៃតែម្តង។

[១៥:៤៣:០០]

**ស៖** ដោយសារតែមិនមានពេលវេលា ខ្ញុំសូមសួរលោកស្រីចុងក្រោយពីរសំណួរទៀតបាទ។ សូមលោកស្រីជួយបញ្ជាក់នៅក្នុងតំបន់ដែលលោកស្រីបានទៅរស់នៅ តើលោកស្រីនៅចងចាំទេថាមានការគោរសិទ្ធិសេរីភាពក្នុងឋានៈជាមនុស្សនៅទីនោះដែរឬទេ? តើរបបខ្មែរក្រហមបានផ្តល់ឲ្យលោកស្រូវនូវសិទ្ធិសេរីក្នុងការរស់នៅរបស់ប្រជាពលរដ្ឋយ៉ាងដូចម្តេចក្នុងស្ថានការជាក់ស្តែងបាទ?

**ឆ៖** ចាស ការរស់នៅមានសិទ្ធិសេរីភាពពេញលេញដូចមនុស្សម្នាកធម្មតា ដូចថាជាតិជាមនុស្សហ្នឹង អត់មានទេៗ។ ត្បិតអីពេលនោះ យើងដើរហើរទៅណាតែងតែគេតាមមើលឃ្លាំមើលយើងរហូត។ សូម្បីតែយើងដេកពេលយប់ឡើងក៏មានគេលូនចូលក្រោមគ្រែយើង តាមឃ្លាំស្តាប់មើលយើងដែរ។ ហើយពេលដែលយើងដើរហើរហ្នឹង ក៏ដើរអត់បានទេ។ ត្បិតអីគេឲ្យយើងរស់នៅក្នុងរបៀបប្រមូលផ្តុំ។ គេធ្វើផ្ទះតូចៗ ឲ្យយើងរស់នៅជួរៗអ៊ីចឹង បន្ទប់ជាប់ៗគ្នាអ៊ីចឹង។ ហើយគេឲ្យយើងនៅអ៊ីចឹង ហើយគេអត់ឲ្យយើងទៅណារហេតរហូតទេ។ ហើយនិយាយទៅ ការរស់នៅហ្នឹងគឺអត់មានសិទ្ធិសេរីភាពតែម្តង។

[១៥:៤៤:១១]

**ស៖** សូមអរគុណ សូមសួរសំណួរចុងក្រោយលោកស្រី។ ខ្ញុំឃើញឯកសារលោកស្រីបានបញ្ជាក់ថា មានការបង្កើតនៅកងកុមារ ហើយលោកស្រីបានធ្វើការងារនៅទីនោះ ហើយតើកងកុមារហ្នឹងមានន័យដូចម្តេច? ហើយម្យ៉ាងទៀត តើរបបខ្មែរក្រហមបានបន្សល់ទុកនូវការឈឺចាប់អ្វីខ្លះចំពោះលោកស្រីរហូតមកដល់ពេលបច្ចុប្បន្នចំពោះលោកស្រីផ្ទាល់ ក៏ដូចជាក្រុមគ្រួសាររបស់លោកស្រី? សូមអរគុណបាទ។

**ឆ៖** ការដែលគេប្រមូលផ្តុំជាកងកុមារហ្នឹង បើតាមពិតទៅខ្ញុំអត់យល់កន្លែងហ្នឹងដែរ ខ្ញុំគ្រាន់តែចង់ថា ហេតុដូចម្តេចបានជាគេប្រមូលកុមារតូចៗយកទៅដាក់កងឲ្យធ្វើការដូចមនុស្សចាស់។ ហើយសម្រាប់នៅភូមិក៏មានគេដាក់កងដែរ គេដាក់កងភូមិៗក៏គេឲ្យត្រូវធ្វើការ កងមុខក៏គេឲ្យត្រូវធ្វើការ។ គេមិនអាចឲ្យយើងនៅទំនេរបានទេ គេឲ្យយើងធ្វើការរហូត។ ហើយរបៀបដូចថាកងហ្នឹង បើតាមនិយាយ

ទៅគេសម្រាប់ប្រមូលផ្ដុំកុមារា កុមារីហ្នឹងឲ្យនៅផ្សេងៗគ្នា គេអត់ឲ្យច្របូកច្របល់ទេ សូម្បីតែធ្វើការក៏គេឲ្យធ្វើការផ្សេងៗពីគ្នាដែរ អត់ឲ្យធ្វើចូលគ្នាទេ។ ហ្នឹងរបៀបកង។ ហើយមួយទៀតខ្ញុំចង់បញ្ជាក់ថាដោយសាររបបពាន់ឆ្នាំ៨ខែ២០ថ្ងៃនេះហើយដែលបន្សល់ទុកទុក្ខសោកនាដកម្ម អនុស្សាវរីយ៍យ៉ាងជូរចត់បំផុតសម្រាប់ខ្ញុំគឺពិការភ្នែកទាំងពីរដោយលំបាកលំបិន អស់អនាគត និងអស់ព្រេងវាសនារបស់ខ្ញុំតែម្ដង។

[១៥:៤៥:៥២]

**លោក ច័ន្ទ តារាស្មី៖**

បាទ លោកស្រី សេង ស៊ីវុត្ថា ក្នុងនាមខ្ញុំតំណាងឲ្យសហព្រះរាជអាជ្ញា ក៏ដូចជាក្នុងនាមខ្ញុំផ្ទាល់ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកស្រី សេង ស៊ីវុត្ថា ដែលបានផ្ដល់ចម្លើយយ៉ាងក្បោះក្បាយនៅក្នុងសវនាការនាពេលនេះ។ ហើយខ្ញុំសង្ឃឹម និងជឿជាក់ថាចម្លើយរបស់លោកស្រីពិតជាអាចចូលរួមចំណែកក្នុងការស្វែងរកការពិត និងយុត្តិធម៌នៅក្នុងសំណុំរឿងក្ដីដែលកំពុងដំណើរការនៅសវនាការនៅថ្ងៃនេះ។ សូមអរគុណ ហើយសូមជូនពរលោកស្រីជួបតែសំណាងល្អ និងជួបតែសេចក្ដីសុខនៅក្នុងជីវិតជារៀងរហូត។ សូមអរគុណ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណបាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានជាទីគោរព យើងខ្ញុំពុំមានសំណួរនោះទេ។ សូមអរគុណ។

[១៥:៤៦:៤១]

**ប្រធានអង្គជំនុំ៖**

បាទ ជាចុងក្រោយនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញបាទ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំអត់មានសំណួរទេ។ សូមអរគុណលោកស្រី ដើមបណ្ដឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អរគុណលោកស្រី សេង ស៊ីវុត្ថា ការស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា អំពីផលប៉ះពាល់ និងសក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា ផលប៉ះពាល់ និងសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយសូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ ហើយមានសេចក្តីសុខសេចក្តីចម្រើន។ ហើយលោកស្រីអាចវិលត្រឡប់ទៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី -- ជូនលោកស្រី សេង ស៊ីវុត្ថា វិលត្រឡប់ទៅកាន់ទីកន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅ ឬទៅកាន់លំនៅដ្ឋានរបស់គាត់វិញបានហើយ។

ហើយក៏សូមអរគុណផងដែរដល់លោកស្រី ឆាយ ម៉ារីដែត បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយសម្រួលដល់ស្មារតីដើមបណ្តឹងរដ្ឋប្បវេណីកន្លងមក ដើម្បីឲ្យគាត់មានស្មារតីរឹងប៉ឹង ហើយនិងអាចធ្វើសេចក្តីថ្លែងរៀបរាប់ ហើយនិងឆ្លើយតបទៅនឹងសំណួរបានល្អ។

ហើយកិច្ចដំណើរការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៥ ខែមិថុនា ឆ្នាំ២០១៣ ដោយចាប់ផ្តើមធ្វើពីម៉ោងប្រាំបី និងសាមសិបនាទីព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីមួយរូប និងអ្នកជំនាញមួយរូប។ សាក្សីមួយរូបនឹងធ្វើសវនាការនៅពេលព្រឹកតាមមធ្យោបាយសោតទស្សន៍ពីសហរដ្ឋអាមេរិក ហើយនិងនៅពេលរសៀលស្តាប់សក្ខីកម្មអ្នកជំនាញដែលមានរហស្សនាម TCE-12 សូមភាគីនៃរឿងក្តី បុគ្គលិកគាំទ្រដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

[១៥:៤៩:០១]

បាទ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបីនិងសាមសិបនាទី។ ដោយឡែកលោក នួន ជា ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាច

ចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយ។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៤៩ នាទី)*